សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et Des Sciences Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# តួនាទីរបស់ចៅក្រមស៊ើបសួរ

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ លោក **ហេង ប៊ូប៊ីន**
កញ្ញា **រិន្ទ ទទ្យរចនា**

សាស្ត្រាចារ្យណែនាំ
លោក **ជួន ប៊ុនធី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧
ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ហេង មុនីន** និង **រិន្ទ ទេវ្យរចនា** ជានិស្សិតថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២១ ក្នុងឆ្នាំសិក្សា ២០២០-២០២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**យើងខ្ញុំសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុតជូនចំពោះ៖**

ជូនចំពោះអ្នកមានគុណគឺលោកឪពុក **ខៀម គឹមហេង** និងអ្នកម្តាយ **អៀ សុមុំ** និង អ្នកម្តាយ **សុខ ណាវី** និងលោកឪពុក **ម៉ុត អេងគ្រុយ** ដែលលោកអ្នកមានគុណរបស់យើងខ្ញុំបានផ្តល់កំណើត និងជីវិតដែលពោរពេញដោយអត្ថន័យដល់រូបខ្ញុំ លើសពីនេះលោកបានលះបង់ពេលវេលាកម្លាំងកាយចិត្តពុះពារគ្រប់ឧបសគ្គ និងចិញ្ចឹមបីបាច់ថែរក្សាប្រៀនប្រដៅដំបូន្មានល្អៗដើម្បីជាទុនក្នុងការរស់នៅក្នុងសង្គម ហើយលោកបានជួយផ្គត់ផ្គង់ដល់ការសិក្សាតាំងពីថ្នាក់មតេយ្យរហូតដល់ថ្នាក់បរិញ្ញាបត្រថែមទៀតផង។ តាមរយៈគុណរបស់លោកទាំងនេះហើយបានធ្វើឲ្យយើងខ្ញុំមានមោទនភាពគោរពកោតសរសើរចំពោះទង្វើដ៏ល្អប្រពៃយកមកធ្វើជាគម្រូ ជាពិសេសគុណូបការៈដ៏សែនធំធេងរកអ្វីប្រៀបប្រដូចពុំបាន ដែលយើងខ្ញុំមានថ្ងៃនេះក៏ព្រោះតែព្រហ្មវិហារធម៌របស់លោកឪពុក និងអ្នកម្តាយ ហើយកូននឹងចងចាំជារហូត។

យើងខ្ញុំសូមថ្លែងអំណរគុណដល់ **ឯកឧត្តមបណ្ឌិត លុយ ចន្ណា** ជាសាកលវិទ្យាធិការ ព្រមទាំង **សាកលវិទ្យាធិការរង ព្រឹទ្ធបុរស និងសាស្ត្រាចារ្យគ្រប់រូប** ដែលបានផ្តល់ចំណេះដឹងដំបូន្មានល្អៗបង្ហាត់បង្រៀនព្រមទាំងផ្តល់បទពិសោធល្អៗដល់រូបយើងខ្ញុំ តាំងពីចាប់ផ្តើមរហូតដល់បញ្ចប់ការសិក្សាបានយ៉ាងជោគជ័យ។ លើសពីនេះសូមថ្លែងអំណរគុណដល់គណៈគ្រប់គ្រងនៃបណ្ណាល័យនីតិសាស្ត្រ ដែលបានរៀបចំគ្រប់គ្រងឯកសារច្បាប់ សៀវភៅឯកសារស្រាវជ្រាវ ក៏ដូចជាជួយសម្រួលដល់ការស្រាវជ្រាវសារណារបស់យើងខ្ញុំផងដែរ។

ជាពិសេសជាងនេះទៅទៀតយើងខ្ញុំសូមថ្លែងអំណរគុណដល់ **លោកសាស្ត្រាចារ្យ ជួន ម៉ុនធី** ដែលលោកជាសាស្ត្រាចារ្យដ៏មានទេពកោសល្យ និងមានបទពិសោធន៍ផ្ទាល់នៅក្នុងសង្គមដែលបានចំណាយកម្លាំងកាយចិត្ត និងពេលវេលាដ៏មានតម្លៃក្នុងការណែនាំបង្ហាត់បង្ហាញផ្តល់នូវគំនិតយោបល់ដំបូន្មានវិធីសាស្ត្រល្អៗពាក់ព័ន្ធនឹងប្រធានបទ និងជួយកែលម្អលើចំណុចខ្វះខាតរបស់យើងខ្ញុំតាំងពីដើមរហូតដល់បានចងក្រងចេញជាស្នាដៃសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនេះបានដោយជោគជ័យ។

ជាទីបញ្ចប់យើងខ្ញុំសូមប្រសិទ្ធិពរជ័យជូនចំពោះលោកឪពុក អ្នកម្តាយ និងឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ថ្នាក់ដឹកនាំ សាស្ត្រាចារ្យគ្រប់រូប និងមិត្តនិស្សិតសូមជួបតែសេចក្តីសុខ សេចក្តីចម្រើន ជោគជ័យគ្រប់ភារកិច្ចការងារ និងសូមឲ្យជួបតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

យើងខ្ញុំជានិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ផ្នែកនីតិសាស្ត្រ ជំនាន់ទី២១ ក្នុងឆ្នាំសិក្សា ២០២០-២០២១។ ក្រោយពីបានឆ្លងកាត់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រអស់រយៈពេល៤ឆ្នាំមកនេះ ឃើញថាការសិក្សាបរិញ្ញាបត្រនីតិសាស្ត្រពិតជាបានផ្តល់សារៈសំខាន់យ៉ាងខ្លាំងសម្រាប់យើងខ្ញុំក្នុងនាមជាយុវជនជំនាន់ក្រោយ។ ការសិក្សាកន្លងមកនេះយើងខ្ញុំបានទទួលនូវចំណេះដឹង និងបទពិសោធន៍ជាច្រើនទោះបីជាកាលៈទេសៈខ្លះបានជួបប្រទះ ក៏យើងខ្ញុំនៅតែតស៊ូព្យាយាមក្រេបយកចំណេះវិជ្ជាដោយមិនលះបង់ឡើយក្នុងគោលបំណងដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនេះឲ្យបានជោគជ័យ។

ដោយឆ្លងកាត់ការសិក្សាកន្លងមកនូវមុខវិជ្ជាសំខាន់ៗជាច្រើនលើផ្នែកនីតិសាស្ត្រនេះ យើងមានការចាប់អារម្មណ៍យ៉ាងខ្លាំងលើមុខវិជ្ជានីតិវិធីព្រហ្មទណ្ឌ ព្រោះថាមុខវិជ្ជានេះគឺជាមុខវិជ្ជាដែលសិក្សាទាក់ទងនឹងនីតិវិធីព្រហ្មទណ្ឌដែលជាវិធានច្បាប់មួយដ៏សំខាន់ក្នុងចំណោមវិធានច្បាប់ផ្សេងៗទៀតសម្រាប់គ្រប់គ្រងសង្គម ដោយយើងបានសិក្សាទាក់ទងនឹងនីតិវិធីដែលត្រូវអនុវត្ត ពិសេសគឺបញ្ញត្តិដែលចែងអំពីនីតិវិធីនៃដំណាក់កាលទាំងបួនក្នុងរឿងព្រហ្មទណ្ឌ។ ហេតុនេះយើងបានសិក្សាដំណាក់កាលទី៣ ក្នុងនីតិវិធីព្រហ្មទណ្ឌ និយាយអំពីដំណាក់កាលស៊ើបសួរដែលដឹកនាំនីតិវិធីដោយចៅក្រមស៊ើបសួរ។

ក្នុងឱកាសដ៏មានតម្លៃនេះយើងខ្ញុំបានជ្រើសរើសប្រធានបទស្តីអំពី **តួនាទីរបស់ចៅក្រមស៊ើបសួរ** ដើម្បីយកមកសិក្សាស្រាវជ្រាវ និងចងក្រងជាសារណានេះឡើងក្នុងគោលបំណងដើម្បីទុកជាឯកសារសម្រាប់បំពេញតម្រូវការរបស់និស្សិតជំនាន់ក្រោយសម្រាប់យកទៅសិក្សាបន្ត។ ជាពិសេសយើងខ្ញុំចង់សិក្សាឲ្យស៊ីជម្រៅច្បាស់លាស់បន្ថែមទៀតទៅលើខ្លឹមសារនៃប្រធានបទនេះ ដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ដែលស្ថាប័នតុលាការកំពុងតែអនុវត្តសម្រាប់ប្រទេសកម្ពុជាយើងលើវិស័យយុត្តិធម៌។

នៅក្នុងការសិក្សាស្រាវជ្រាវ និងចងក្រងឯកសារនេះឡើងប្រាកដជាមានចំណុចខ្វះខាតទាំងផ្នែកខ្លឹមសារ និងមានកំហុសខុសឆ្គងផ្នែកអក្ខរាវិរុទ្ធជាក់ជាមិនខានដែលកើតមានឡើងក្នុងឯកសារនេះ។ យើងខ្ញុំសូមទទួលនូវការរិះគន់ និងការកែតម្រូវទាំងឡាយក្នុងន័យស្ថាបនាពីសំណាក់ឯកឧត្តម លោកជំទាវ លោក លោកស្រី និងមិត្តអ្នកអានទាំងអស់ដើម្បីកែលម្អស្នាដៃមួយនេះឲ្យកាន់តែប្រសើរឡើង។

ជាទីបញ្ចប់ខ្ញុំសូមសម្តែងនូវសេចក្តីគោរពជូនពរដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី សាស្ត្រាចារ្យ និងមិត្តអ្នកអានទាំងអស់សូមជួបតែប្រទះតែសំណាងល្អ និងជោគជ័យគ្រប់ភារកិច្ច ព្រមទាំងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

## សេចក្ដីផ្ដើម

ទំព័រ


១. លំនាំបញ្ហានៃការស្រាវជ្រាវ........................................................................................ ១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ ..................................................................................... ២

៣. គោលបំណងនៃការស្រាវជ្រាវ ....................................................................................... ២

៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ................................................................. ៣

៥. សារៈសំខាន់នៃការស្រាវជ្រាវ ....................................................................................... ៣

៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ.........................................................................................៤


## ជំពូកទី១
## កិច្ចនីតិវិធីនៃការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ


**ផ្នែកទី១៖ សញ្ញាណទូទៅនៃចៅក្រមស៊ើបសួរ**.................................................................៥

**កថាខណ្ឌទី១៖ លក្ខណៈសម្បត្តិក្នុងការក្លាយជាចៅក្រមស៊ើបសួរ**.......................................៥

ក. លក្ខន្តិកៈរបស់ចៅក្រមស៊ើបសួរ.................................................................................៥

ខ. ក្រមសីលធម៌ចៅក្រមស៊ើបសួរ....................................................................................៦

គ. វិសមិតភាពមុខងារ.....................................................................................................៦

**កថាខណ្ឌទី២៖ សមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ** .......................................................... ៧

ក. សមត្ថកិច្ចដែនដី ........................................................................................................ ៧

ខ. សមត្ថកិច្ចតាមរឿងក្ដី..................................................................................................៨

**កថាខណ្ឌទី៣៖ ការបើកការស៊ើបសួរ**................................................................................៨

ក. ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ..........................................................................៩

ខ. ការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី......................................................................... ១០

**កថាខណ្ឌទី៤៖ ការស្នើសុំឲ្យបំពេញកិច្ច**........................................................................១១

ក. ការស្នើសុំបំពេញកិច្ចដោយព្រះរាជអាជ្ញា......................................................................១១

ខ. ការស្នើសុំបំពេញកិច្ចដោយជនត្រូវចោទ ......................................................................១២

គ. ការស្នើសុំបំពេញកិច្ចដោយដើមបណ្ដឹងរដ្ឋប្បវេណី .......................................................១២

**ផ្នែកទី២៖ សិទ្ធិអំណាចរបស់ចៅក្រមស៊ើបសួរក្នុងការស៊ើបសួរ**....................................... ១២

**កថាខណ្ឌទី១៖ ការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ** .................... ១៣
ក. ការជូនដំណឹងអំពីការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យ.................... ១៣
ខ. ការសួរចម្លើយជនត្រូវចោទ .................... ១៥
គ. ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី .................... ១៦
ឃ. ការស្តាប់ចម្លើយសាក្សី .................... ១៨
ង. ការឆែកឆេរ និងការចាប់យកវត្ថុតាង .................... ១៩
ច. ការធ្វើកោសលវិច័យ .................... ២០
ឆ. ការស្តាប់ទូរស័ព្ទ.................... ២៣
**កថាខណ្ឌទី២៖ ការចាត់ឲ្យស៊ើបសួរជំនួស**.................... ២៤
ក. មូលហេតុនៃការចាត់ឲ្យបំពេញកិច្ចស៊ើបសួរជំនួស .................... ២៤
ខ. ការស៊ើបសួរជំនួសដោយចៅក្រមផ្សេងទៀត.................... ២៤
គ. ការស៊ើបសួរជំនួសដោយមន្ត្រីនគរបាលយុត្តិធម៌ .................... ២៥

## ជំពូកទី២
## វិធានការនិរន្តរាយ

**ផ្នែកទី១៖ ដីកា**.................... ២៧
**កថាខណ្ឌទី១៖ ដីកាបង្គាប់ឲ្យចូលខ្លួន** .................... ២៧
ក. អត្ថន័យនៃដីកាបង្គាប់ឲ្យចូលខ្លួន.................... ២៧
ខ. លក្ខខណ្ឌនៃការចេញដីកាបង្គាប់ឲ្យចូលខ្លួន.................... ២៨
គ. ការអនុវត្តដីកាបង្គាប់ឲ្យចូលខ្លួន .................... ២៩
**កថាខណ្ឌទី២៖ ដីកាបង្គាប់ឲ្យនាំខ្លួន**.................... ២៩
ក. អត្ថន័យនៃដីកាបង្គាប់ឲ្យនាំខ្លួន .................... ២៩
ខ. លក្ខខណ្ឌនៃការចេញដីកាបង្គាប់ឲ្យនាំខ្លួន .................... ២៩
គ. ការអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួន.................... ៣០
**កថាខណ្ឌទី៣៖ ដីកាបង្គាប់ឲ្យចាប់ខ្លួន** .................... ៣១
ក. អត្ថន័យនៃដីកាបង្គាប់ឲ្យចាប់ខ្លួន.................... ៣១
ខ. លក្ខខណ្ឌនៃការបង្គាប់ឲ្យចាប់ខ្លួន.................... ៣២
គ. ការអនុវត្តដីកាបង្គាប់ឲ្យចាប់ខ្លួន .................... ៣៣

**កថាខណ្ឌទី៤៖ ដីកាបង្គាប់ឲ្យឃុំខ្លួន**....................................................................................................៣៥
ក. អត្ថន័យនៃដីកាបង្គាប់ឲ្យឃុំខ្លួន ....................................................................................................៣៥
ខ. លក្ខខណ្ឌនៃការចេញដីកាបន្គាប់ឲ្យឃុំខ្លួន ....................................................................................៣៥
គ. ការអនុវត្តដីកាបង្គាប់ឲ្យឃុំខ្លួន.........................................................................................................៣៦
**ផ្នែកទី២៖ ការកំណត់សិទ្ធិទៅកាន់ជនត្រូវចោទ**..........................................................................................៣៦
**កថាខណ្ឌទី១៖ ការឃុំខ្លួនបណ្ដោះអាសន្ន** ......................................................................................... ៣៧
ក. លក្ខខណ្ឌនៃការឃុំខ្លួនបណ្ដោះអាសន្ន.......................................................................................... ៣៧
ខ. នីតិវិធីនៃការឃុំខ្លួនបណ្ដោះអាសន្ន...............................................................................................៣៩
គ. ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន.......................................................................................... ៤០
ឃ. ការជានាជនត្រូវចោទឲ្យនៅក្រៅឃុំ ............................................................................................ ៤២
**កថាខណ្ឌទី២៖ ការត្រួតពិនិត្យតាមផ្លូវតុលាការ** .........................................................................................៤៣
ក. លក្ខខណ្ឌសម្រេចដាក់ឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ........................................... ៤៤
ខ. នីតិវិធីនៃការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ............................................ ៤៥
គ. ការអនុវត្តនីតិវិធីដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ....................................... ៤៦
ឃ. តួនាទីចៅក្រមស៊ើបសួរក្នុងដំណាក់កាលត្រួតពិនិត្យតាមផ្លូវតុលាការ....................................... ៤៧

## ជំពូកទី៣
## ការបិទការស៊ើបសួរ

**ផ្នែកទី១៖ នីតិវិធីនៃការបិទការស៊ើបសួរ**.................................................................................................៤៩
**កថាខណ្ឌទី១៖ ការជូនព័ត៌មានដោយចៅក្រមស៊ើបសួរ**...............................................................................៤៩
**កថាខណ្ឌទី២៖ ការបញ្ជូនសំណុំរឿងដោយព្រះរាជអាជ្ញា** ............................................................................៤៩
**ផ្នែកទី២៖ ប្រភេទនៃដីកាដំណោះស្រាយ**.....................................................................................................៥០
**កថាខណ្ឌទី១៖ ដីកាបញ្ជូនរឿងទៅពិនិត្យរឿងទាំងមូល** ............................................................................. ៥១
**កថាខណ្ឌទី២៖ ដីកាលើកលែងការចោទប្រកាន់**.......................................................................................... ៥១
**សេចក្ដីសន្និដ្ឋាន** ......................................................................................................................................៥៣
**អនុសាសន៍** .................................................................................................................................................៥៥
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសមួយដែលកំពុងមានការអភិវឌ្ឍព្រមទាំងកំណើនសេដ្ឋកិច្ចមានការកើនឡើងគួរឲ្យកត់សំគាល់។ ប៉ុន្តែក៏ជាកត្តាមួយធ្វើឲ្យមានការប្រកួតប្រជែងដើម្បីដណ្តើមផលប្រយោជន៍គ្នាក្នុងគោលដៅបំពេញនូវសេចក្តីត្រូវការគតព្រំដែនរបស់ខ្លួន ដែលបានបង្កឲ្យមាននូវភាពអនាធិបតេយ្យគ្មានសណ្តាប់ធ្នាប់ និងបាត់បង់នូវតម្លៃសីលធម៌សង្គម ហើយបានបង្កឲ្យមានអំពើអសកម្មនានាដែលនាំឲ្យមានផលវិបាកនៅក្នុងសង្គមជាតិ។ វិធីសាស្ត្រដើម្បីទប់ស្កាត់នូវសកម្មភាពទាំងនោះ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានខិតខំប្រឹងប្រែង ក្នុងការតាក់តែងលិខិតបទដ្ឋានគតិយុត្តនានាដើម្បីផ្តន្ទាទោសលើបុគ្គលទាំងនោះ។ ជាក់ស្តែងក្នុងការរក្សាសណ្តាប់ធ្នាប់នៅក្នុងសង្គមខ្មែរ អង្គការនីតិបញ្ញតិបានបង្កើតច្បាប់ជាច្រើនក្នុងការបង្កើនការការពារ និងប្រឆាំងទប់ស្កាត់ការដាក់ទណ្ឌកម្មដល់ជនដែលប្រព្រឹត្តបទល្មើសដែលកើតមានក្នុងសង្គម ប៉ុន្តែវិធានច្បាប់ដែលមានអនុភាពអនុវត្តទៅលើជីវភាពរស់នៅទូទៅនោះ គឺវិធានច្បាប់ព្រហ្មទណ្ឌដែលមានចែងនូវប្រភេទបទល្មើសជាច្រើននៅក្នុងនោះ។ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានប្រកាសឲ្យប្រើនៅ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ដែលក្រមព្រហ្មទណ្ឌនេះបានកំណត់នូវគោលការណ៍ទូទៅដើម្បីអនុវត្ត និងបានចែងនូវបទល្មើសជាច្រើនចាប់ពីបទលហុ បទមជ្ឈិម និងបទឧក្រិដ្ឋ ដោយក្រមព្រហ្មទណ្ឌបានចែកចេញជា ៦គន្ថី និង ៦៧២មាត្រា សុទ្ធសឹងតែកំណត់នៃឈ្មោះបទល្មើសដែលកើតឡើងក្នុងជីវភាពរស់នៅ។

ទន្ទឹមនឹងនេះដែរ ដើម្បីជាភាពងាយស្រួលក្នុងការអនុវត្តរឿងក្តីព្រហ្មទណ្ឌឲ្យមានប្រសិទ្ធភាពល្អ អង្គការនីតិបញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជាបានបង្កើតឲ្យមានក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។ គោលបំណងនៃក្រមនីតិវិធីព្រហ្មទណ្ឌ គឺដើម្បីកំណត់អំពីវិធានទាំងឡាយដែលត្រូវគោរព និងប្រព្រឹត្តតាមយ៉ាងម៉ត់ចត់ដើម្បីកំណត់ឲ្យច្បាស់នូវអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌណាមួយ។[1] យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌសង្កេតឃើញថាមានការចែងទាក់ទងនឹងនីតិវិធីក្នុងការដោះស្រាយនៅពេលដែលមានបទល្មើសដែលកើតឡើង។

ក្រមនីតិវិធីព្រហ្មទណ្ឌ បានចងក្រងឡើងក្នុងគោលដៅសំខាន់ទាក់ទងទៅនឹង ដំណាក់កាលនៃការវិនិច្ឆ័យបទល្មើសដើម្បីជាភាពងាយស្រួលក្នុងការអនុវត្តនីតិវិធីនៅពេលមានបទល្មើសណាមួយកើតឡើង គឺត្រូវអនុវត្តតាមដំណាក់កាលដែលបានបែងចែកទៅតាមនីតិវិធីសំខាន់ៗចំនួនបួនដែលមានដូចជា ដំណាក់កាលស៊ើបអង្កេត ដំណាក់កាលចោទប្រកាន់ ដំណាក់កាលស៊ើបសួរ និងដំណាក់កាលជំនុំជម្រះ។ ទោះបីជានៅក្នុង

[1] មាត្រា១, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

ដំណើរការនីតិវិធីព្រហ្មទណ្ឌមានដំណាក់កាលជាច្រើនក៏ដោយ ដំណាក់កាលស៊ើបសួររបស់យុត្តាធិការស៊ើបសួរជានីតិវិធីស្វែងរកការពិតមួយដ៏មានសារៈសំខាន់ ដោយហេតុថាដំណាក់កាលនេះបង្ហាញអំពីស្មារតីនៃគោលការណ៍បែងចែកអំណាចក្នុងស្ថាប័នតុលាការក្នុងការស្វែងរក និងធានាយុត្តិធម៌ជូនប្រជាពលរដ្ឋឲ្យស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងបទប្បញ្ញត្តិច្បាប់នានា។

យ៉ាងណាមិញ ទោះបីជាដំណាក់កាលនៃនីតិវិធីព្រហ្មទណ្ឌសំខាន់ៗមានចំនួនបួនក៏ដោយប៉ុន្តែក្នុងបរិបទនៃកិច្ចការស្រាវជ្រាវនេះ គឺធ្វើការស្រាវជ្រាវត្រឹមតែដំណាក់កាលស៊ើបសួរ ពោលគឺស្រាវជ្រាវតែអំពីសិទ្ធិអំណាច និងតួនាទីដែលស្ថិតក្រោមសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរក្នុង ដំណាក់កាលស៊ើបសួរតែប៉ុណ្ណោះ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ជាការពិតណាស់ នៅក្នុងប្រព័ន្ធយុត្តាធិការនៃព្រះរាជាណាចក្រកម្ពុជាចំពោះរឿងព្រហ្មទណ្ឌបានបែងចែកចៅក្រមជាពីរដែលមានដូចជាទីមួយគឺ ចៅក្រមអយ្យការ ឬអាចហៅបានថាព្រះរាជអាជ្ញា និងទីពីរគឺ ចៅក្រមអាសនៈដែលក្នុងនោះមានដូចជាចៅក្រមស៊ើបសួរ និងចៅក្រមជំនុំជម្រះ។ នៅក្នុងដំណាក់កាលស៊ើបសួរតើចៅក្រមស៊ើបសួរគឺជាអ្នកណា? ចៅក្រមស៊ើបសួរ គឺជាចៅក្រមតែបំពេញការងារនៅក្នុងមន្ទីរស៊ើបសួរនៃតុលាការជាន់ទាបដែលជាតុលាការរាជធានីខេត្តក្រុង។ ដើម្បីជាការឆ្លើយតបទៅកាន់ចំណោទបញ្ហាខាងលើក្នុងការស្រាវជ្រាវយើងនឹងធ្វើការបកស្រាយអំពីចៅក្រមស៊ើបសួរ ដែលគាត់មានតួនាទីធ្វើការបើកការស៊ើបសួរដើម្បីធ្វើកិច្ចស៊ើបសួរស្រាវជ្រាវស្វែងរកភស្តុតាងទាំងដាក់បន្ទុក និងដោះបន្ទុកនៅក្នុងរឿងព្រហ្មទណ្ឌដែលធ្វើឡើងបន្ទាប់ពីទទួលបានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ ហើយចៅក្រមស៊ើបសួរនឹងធ្វើការបិទបញ្ចប់ការស៊ើបសួរនៅពេលបំពេញកិច្ចស៊ើបសួរចប់ដោយមានចេញនូវដីកាដំណោះស្រាយ។ ចំពោះការប្រតិបត្តិបំពេញការងាររបស់ខ្លួននេះចៅក្រមស៊ើបសួរត្រូវបានប្រធានសាលាដំបូងចាត់តាំងចៅក្រមយ៉ាងតិចពីររូបតាមដីកាសម្រេចឲ្យបំពេញតួនាទីជាចៅក្រមស៊ើបសួរនៅសភាស៊ើបសួរនៃតុលាការព្រហ្មទណ្ឌនៃសាលាដំបូង[2]។ ក្នុងន័យនេះគឺចៅក្រមស៊ើបសួរបំពេញកិច្ចការរបស់ខ្លួនតាមរយៈការចាត់ចែងប្រធានសាលាដំបូងដែលចៅក្រមនោះស្ថិតនៅ។

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវប្រធានបទ "តួនាទីរបស់ចៅក្រមស៊ើបសួរ" នេះគឺមានគោលបំណងចង់សិក្សាឲ្យច្បាស់ស៊ីជម្រៅពីតួនាទី សិទ្ធិអំណាចរបស់ចៅក្រមស៊ើបសួរក្នុងការបើកការស៊ើបសួរ និងការបិទការស៊ើបសួរដើម្បីស្វែងរកការពិតនៅក្នុងអង្គហេតុ។ ដោយសារតែដំណាក់កាលស៊ើបសួរជាដំណាក់កាលមួយមានលក្ខណៈស្មុគស្មាញ និងមានវិលាលភាពធំធេងជាងដំណាក់កាលផ្សេងៗទៀត។ ទាំងអស់នេះយើងនឹងធ្វើការបកស្រាយថាចៅក្រម

[2] មាត្រា ២០, ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ឆ្នាំ២០១៤។

ស៊ើបសួរមានវិធានការអ្វីខ្លះក្នុងការស្វែងរកការពិតដែលរួមមាន ការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យ ការឆែកឆេរ ការចាប់យកវត្ថុតាង ការធ្វើកោសល្យវិច័យ និងការស្តាប់ទូរស័ព្ទជាអាទិ៍ដែលសុទ្ធសឹងតែជាវិធានដែលបានកំណត់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌយ៉ាងតឹងរ៉ឹងក្នុងការប្រើប្រាស់វិធានការនីមួយៗនេះ។

## ៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ប្រធានបទស្រាវជ្រាវនេះគឺមានវិសាលភាពគ្របដណ្តប់ទៅលើទ្រឹស្តី និងទិដ្ឋភាពជាក់ស្តែងនៃតួនាទីភារកិច្ច និងសិទ្ធិអំណាចរបស់ចៅក្រមស៊ើបសួរក្នុងដំណាក់កាលស៊ើបសួរ ដែលបានបញ្ញត្តិនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧។ យ៉ាងណាមិញទោះបីជាដំណាក់កាលនៃនីតិវិធីព្រហ្មទណ្ឌមានចំនួនបួនសំខាន់ៗក៏ដោយ ប៉ុន្តែក្នុងបរិបទដែនកំណត់នៃការស្រាវជ្រាវនេះ គឺធ្វើការស្រាវជ្រាវត្រឹមតែដំណាក់កាលស៊ើបសួរតែប៉ុណ្ណោះដែលជាដំណាក់កាលសំខាន់ក្នុងចំណោមដំណាក់កាលទាំងបួន។ បានន័យថាការស្រាវជ្រាវនេះបានធ្វើឡើងចាប់ផ្តើមត្រឹមពីការបើកការស៊ើបសួររបស់ចៅក្រមស៊ើបសួរ និងបញ្ចប់ទៅវិញត្រឹមការបិទស៊ើបសួរដោយការចេញនូវដីការដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ។ សូមបញ្ជាក់ផងដែរថាកិច្ចការស្រាវជ្រាវមួយនេះគឺមិនបានលើកយកនូវនីតិវិធីស្តីពីមោឃៈភាពនៃការស៊ើបសួរ និងនីតិវិធីនៅក្នុងសភាស៊ើបសួរនៃសាលាឧទ្ធរណ៍យកមកសិក្សានោះទេ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ក្នុងការស្រាវជ្រាវប្រធាបទស្តីអំពី "តួនាទីរបស់ចៅក្រមស៊ើបសួរ" ពិតជាបានផ្តល់អត្ថប្រយោជន៍ជាច្រើនទាក់ទងនឹងការយល់ដឹងកាន់តែច្បាស់អំពីតួនាទី និងអំណាចរបស់ចៅក្រមស៊ើបសួរក្នុងដំណាក់កាលស៊ើបសួរពោល គឺទទួលបានចំណេះដឹងទាក់ទងនឹងការបើក ការបិទ និងវិធានការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរដែលធ្វើនៅក្នុងរឿងក្តីព្រហ្មទណ្ឌដែលមានដូចជាការសួរចម្លើយ ការស្តាប់ចម្លើយ ការចេញដីកា និងការប្រើប្រាស់វិធានការនិរន្តរាយផ្សេងៗ របស់ចៅក្រមស៊ើបសួរដើម្បីធ្វើឲ្យការប្រព្រឹត្តទៅនៃកិច្ចការរបស់ខ្លួនដំណើរការទៅយ៉ាងរលូន។ ជាងនេះទៅទៀតប្រធានបទនេះបានផ្តល់នូវចំណេះដឹងទាក់ទងនឹងការអនុវត្តជាក់ស្តែងមួយចំនួនកាន់តែច្បាស់អំពីដែនកំណត់ និងវិសាលភាពនៃកាតព្វកិច្ចរបស់ចៅក្រមស៊ើបសួរ។ ក្នុងដំណាក់កាលនេះតើការប្រព្រឹត្តទៅក្នុងកិច្ចរបស់ចៅក្រមស៊ើបសួរមានលក្ខណៈយ៉ាងដូចម្តេចខ្លះ? លើសពីនេះទៅទៀតនៅក្នុងចំណុចបញ្ចប់នៃកិច្ចការស្រាវជ្រាវនឹងទទួលបានការយល់ដឹងអំពីផលវិបាក និងចំណុចខ្វះខាតមួយចំនួនទាក់ទងនឹងការអនុវត្តនីតិវិធីរបស់ចៅក្រមស៊ើបសួរនៅក្នុងដំណាក់កាលស៊ើបសួរហើយបន្ថែមពីនេះនឹងមានឱកាសបញ្ចេញគំនិតដើម្បីកំណែទម្រង់ក្នុងន័យស្ថាបនា។

## ៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីឲ្យបានដឹងច្បាស់ទាក់ទងនឹងប្រធានបទ **តួនាទីរបស់ចៅក្រមស៊ើបសួរ** គឺបានតាក់តែងសារណានេះឡើងទៅតាមរចនាសម្ព័ន្ធមានដូចជា អារម្ភណ៍កថា សេចក្តីថ្លែងអំណរគុណ សេចក្តីផ្តើម និងខ្លឹមសារដែលបានបែងចែកចេញជា បី ជំពូកដូចខាងក្រោមះ

ជំពូកទី១៖ កិច្ចនីតិវិធីនៃការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ

ជំពូកទី២៖ វិធានការនិរន្តរាយ

ជំពូកទី៣៖ ការបិទការស៊ើបសួរ

ផ្នែកបញ្ចប់នៃសារណានេះយើងខ្ញុំបានរៀបចំដោយរួមមាន សេចក្តីសន្និដ្ឋាន និងអនុសាសន៍ និងរួមបញ្ចូលជាមួយឧបសម្ព័ន្ធផងដែរ។

# ជំពូកទី១
# កិច្ចនីតិវិធីនៃការស្រាវជ្រាវរបស់
# ចៅក្រមស៊ើបសួរ

# ជំពូកទី១

# កិច្ចនីតិវិធីនៃការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ

## ផ្នែកទី១៖ សញ្ញាណទូទៅនៃចៅក្រមស៊ើបសួរ

នៅក្នុងព្រះរាជាណាចក្រកម្ពុជា មានស្ថាប័នតុលាការដែលបម្រើឲ្យប្រជាពលរដ្ឋក្នុងការស្វែងរកយុត្តិធម៌ ដែលមាននៅតាមមូលដ្ឋាននៅគ្រប់រាជធានី-ខេត្តត្រូវបានបែងចែកចេញជាសាលាដំបូងរាជធានី-ខេត្ត។ ចំពោះអ្នកដែលមានអំណាចក្នុងការសម្រេចសេចក្តី ឬហៅជាចៅក្រមនោះត្រូវបានបែងចែកជាពីរដាច់ដោយឡែករួមមានចៅក្រមអាសនៈ និងចៅក្រមអយ្យការ។ ក្នុងនោះផងដែរចំពោះចៅក្រមអាសនៈក៏ត្រូវបានបែងចែកមុខងារជាពីរគឺតួអង្គដែលមានទាំងចៅក្រមជំនុំជម្រះ និងចៅក្រមស៊ើបសួរ។ តួអង្គទាំងពីរនេះស្ថិតនៅក្នុងស្ថាប័នយុត្តាធិការជំនុំជម្រះ និងយុត្តាធិការស៊ើបសួរ។ ដោយឡែកចៅក្រមអយ្យការវិញគឺស្ថិតនៅក្នុងស្ថាប័នអយ្យការអមសាលាដំបូងរាជធានី-ខេត្តដែលមានតួអង្គព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង ជាអ្នកទាមទារឲ្យតុលាការអនុវត្តច្បាប់ និងតំណាងអយ្យការឲ្យផលប្រយោជន៍សាធារណៈក្នុងសង្គម។

### កថាខណ្ឌទី១៖ លក្ខណៈសម្បត្តិក្នុងការក្លាយជាចៅក្រមស៊ើបសួរ

ដើម្បីក្លាយជាចៅក្រមស៊ើបសួរមួយរូប អ្នកត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោមជាមុន៖

- ត្រូវមានសញ្ជាតិខ្មែរតាំងពីកំណើត

- មានអាយុ ៣៥ ឆ្នាំ យ៉ាងច្រើនចំពោះបេក្ខជនជានិស្សិត និងមានអាយុ ៤០ ឆ្នាំចំពោះបេក្ខជនជាមន្ត្រីរាជការគិតដល់ថ្ងៃប្រឡង

- ត្រូវមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រច្បាប់ទៅ

- មិនដែលមានទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋ

- ត្រូវមានកាយសម្បទាគ្រប់គ្រាន់អាចបំពេញការងារបាន។[3]

បេក្ខជនដែលប្រឡងជាប់ជាសិស្សចៅក្រមនឹងត្រូវទទួលបាននូវការបណ្តុះបណ្តាលវិជ្ជាជីវៈដែលរៀបចំដោយក្រសួងយុត្តិធម៌ដែលត្រូវបានកំណត់ដោយការប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។[4]

#### ក. លក្ខន្តិកៈរបស់ចៅក្រមស៊ើបសួរ

ស្ថាប័នតុលាការ ជាអំណាចឯករាជ្យ។ តុលាការធានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ។ ចៅក្រមនៃតុលាការគ្រប់ជាន់ថ្នាក់ត្រូវបំពេញភារកិច្ចនេះដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ និងឲ្យអស់ពី

[3] មាត្រា ១៩, ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា, លេខ នស/រកម/០៧១៤/០១៦, ១៦ កក្កដា ២០១៤។

[4] មាត្រា ២១, ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា, លេខ នស/រកម/០៧១៤/០១៦, ១៦ កក្កដា ២០១៤។

ដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន។[5] ចៅក្រមស៊ើបសួរមិនខុសពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា និងការរៀបចំអង្គការតុលាការនៅឡើយ។

មន្ទីរស៊ើបសួរនៃសាលាដំបូង គឺជាផ្នែកមួយនៃតុលាការព្រហ្មទណ្ឌដែលអនុលោមតាមបទប្បញ្ញត្តិស្តីពីនីតិព្រហ្មទណ្ឌ។ ប្រធានសាលាដំបូងត្រូវចាត់តាំងចៅក្រមយ៉ាងតិច ០២ (ពីរ) រូបតាមដីកាសម្រេចឲ្យបំពេញតួនាទីជាចៅក្រមស៊ើបសួរនៅមន្ទីរស៊ើបសួរនៃតុលាការព្រហ្មទណ្ឌនៃសាលាដំបូង[6]។ ដីកាសម្រេចនេះដែរត្រូវកំណត់អំពីលំដាប់លេខរៀងសម្រាប់ការបំពេញការងារ។ ករណីពុំមានចៅក្រមស៊ើបសួរ ឬខ្វះចៅក្រមស៊ើបសួរ ប្រធានសាលាដំបូងត្រូវចាត់តាំងពីចៅក្រម នៃតុលាការជំនាញផ្សេងដើម្បីបំពេញការងារស៊ើបសួរបាន។

**ខ. ក្រមសីលធម៌ចៅក្រមស៊ើបសួរ**

ក្រមសីលធម៌ចៅក្រមស៊ើបសួរ គឺជាការតម្រូវឲ្យចៅក្រមស៊ើបសួរដែលបំពេញកិច្ចទាំងឡាយដោយផ្អែកទៅលើគោលការណ៍ទាំងប្រាំគឺ គោលការណ៍ឯករាជ្យ គោលការណ៍អនាគតិ (ភាពមិនលម្អៀង) គោលការណ៍ភាពសុចរិត គោលការណ៍សេចក្តីថ្លៃថ្នូរ និងគោលការណ៍វិរិយភាព (សេចក្តីព្យាយាម ឬប្រឹងប្រែង)។[7]

ក្រមសីលធម៌ក៏មានគោលបំណងពង្រឹកនូវឯករាជភាព និងសេចក្តីថ្លៃថ្នូររបស់ចៅក្រមស៊ើបសួរទាំងអស់ក្នុងការអនុវត្តកិច្ចការតុលាការ ឬអយ្យការ ក៏ដូចជាការប្រកាន់នូវឥរិយាបថរបស់ខ្លួននៅក្រៅតុលាការ។ នៅក្នុងក្រមសីលធម៌នេះចៅក្រមមានន័យថាចៅក្រមអាសនៈ និង ចៅក្រមអយ្យការ។ ក្រមសីលធម៌នេះក៏ជាការបំពេញបន្ថែមពីលើច្បាប់ និងសេចក្តីណែនាំផ្សេងៗទៀតចំពោះចៅក្រមដើម្បីបង្កើននូវជំនឿទុកចិត្តពីសាធារណៈជនលើប្រព័ន្ធតុលាការ និងការពារកេរ្តិ៍ឈ្មោះរបស់ចៅក្រម។[8]

**គ. វិសមិតភាពមុខងារ**

ការស្ថិតនៅក្រោមឈ្មោះរួមជាចៅក្រម គឺគេប្រមូលផ្តុំជនទាំងអស់ដែលមានលក្ខន្តិកៈជាចៅក្រមដែលបំពេញមុខងារផ្សេងៗគ្នាក្នុងប្រព័ន្ធយុត្តាធិការ ភាពខុសគ្នានូវតួនាទីទាំងនេះនាំឲ្យមានបុព្វសិទ្ធិ និងកាតព្វកិច្ចនៅពេលបំពេញមុខងាររបស់ខ្លួន។ ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថាចៅក្រមណាដែលបានបំពេញមុខងារក្នុងឋានៈជាព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង ឬចៅក្រមស៊ើបសួរលើរឿងក្តីណាមួយមិនអាចចូលរួមក្នុងការជំនុំជម្រះរឿងក្តីនោះបានទេ បើមិនដូច្នេះទេសាលក្រមនឹងត្រូវចាត់ទុកជាមោឃៈ។[9] ក្នុងន័យនេះដែរព្រះរាជអាជ្ញាជាមជ្ឈដ្ឋានកណ្តាលក្នុងការទទួលរាល់គ្រប់ព័ត៌មានទាំងអស់តាមគ្រប់មធ្យោបាយ ដែលបង្កើតបានជាបទល្មើស

---

[5] មាត្រា ១២៩ថ្មី, រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៣។

[6] មាត្រា ២០, ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៦, ១៦ កក្កដា ២០១៤។

[7] ក្រមសីលធម៌ចៅក្រម, ២២ កុម្ភៈ ២០១៤។

[8] ប្រការ ១, ក្រមសីលធម៌ចៅក្រម, ២២ កុម្ភៈ ២០១៤។

[9] មាត្រា ២៨៨, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

ព្រហ្មទណ្ឌ ទោះបីព្រះរាជអាជ្ញាពុំមានសិទ្ធិអំណាចក្នុងការស៊ើបសួរក៏ដោយប៉ុន្តែក្នុងនីតិវិធីព្រហ្មទណ្ឌបានផ្តល់អំណាចដល់ព្រះរាជអាជ្ញានូវសិទ្ធិក្នុងការស៊ើបអង្កេតដោយមានជំនួយពីមន្ត្រីនគរបាលយុត្តិធម៌ផងដែរ។ ក្នុងស្មារតីនៃមាត្រានេះដែរ គឺចង់បង្ហាញថាប្រសិនបើចៅក្រមស៊ើបសួរ ឬព្រះរាជអាជ្ញាបានទទួលនូវសំណុំរឿង ឬចាត់ការលើសំណុំរឿងហើយជាការស្វែងរកនូវភស្តុតាងចំពោះព្រះរាជអាជ្ញា គឺស្វែងរកតែភស្តុតាងដាក់បន្ទុកខុសពីចៅក្រមស៊ើបសួរ គឺស្វែងរកភស្តុតាងដាក់បន្ទុកនិងភស្តុតាងដោះបន្ទុក ដូចនេះហើយប្រសិនជាព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរទៅធ្វើជាចៅក្រមជំនុំជម្រះទៀតនោះ ច្បាស់ណាស់ប្រាកដជាមានបុរេនិច្ឆ័យដែលធ្វើឲ្យមានភាពអយុត្តិធម៌ទៅលើជនល្មើស ហើយសាលក្រមនោះគឺចាត់ទុកគ្មានបានការហើយគ្មានអានុភាពទៅលើផ្លូវច្បាប់ឡើយ។ ដូច្នេះដើម្បីធានានូវសេចក្តីសម្រេចប្រកបដោយភាពយុត្តិធម៌ និងស្វែងរកការពិតកាន់តែមានភាពសុក្រឹតភាព។

**កថាខណ្ឌទី២៖ សមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ**

នៅក្នុងសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរត្រូវបានបែងចែកជាពីរប្រភេទគឺ៖ សមត្ថកិច្ចដែនដី និងសមត្ថកិច្ចតាមរឿងក្តី។

**ក. សមត្ថកិច្ចដែនដី**

ចៅក្រមស៊ើបសួរស្ថិតនៅជាមួយសាលាដំបូង ដូច្នេះគាត់មានសមត្ថកិច្ចនៅក្នុងដែនសមត្ថកិច្ចរបស់តុលាការនោះចំពោះគ្រប់បទល្មើសដែលត្រូវបានប្រព្រឹត្តនៅក្នុងដែនសមត្ថកិច្ចនោះ និងចំពោះបទល្មើសដែលកើតឡើងនៅក្រៅដែនកិច្ចប្រសិនបើជនសង្ស័យម្នាក់បានចូលរួមប្រព្រឹត្តបទល្មើសទាំងអស់ ឬក៏ត្រូវបានចាប់ខ្លួនក្នុងដែនសមត្ថកិច្ចរបស់គាត់ទោះបីជាត្រូវបានចាប់ខ្លួនដោយមូលហេតុផ្សេងក៏ដោយ។

សមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរមាន៖

- ចៅក្រមស៊ើបសួរមានទីកន្លែងប្រព្រឹត្តបទល្មើស។
- ចៅក្រមស៊ើបសួរមានទីលំនៅឋាន ឬទីសំណាក់របស់បុគ្គលដែលសង្ស័យថាបានប្រព្រឹត្តបទល្មើស។
- ចៅក្រមស៊ើបសួរនាទីកន្លែងចាប់ខ្លួនបុគ្គលដែលសង្ស័យថាបានប្រព្រឹត្តបទល្មើស។

ក្នុងករណីដែលមានទំនាស់រវាងចៅក្រមស៊ើបសួរច្រើនរូបនៅសាលាដំបូងខុសៗគ្នាហើយទទួលបណ្តឹងទាំងអស់ដូចគ្នាអំពីរឿងព្រហ្មទណ្ឌតែមួយទំនាស់នេះត្រូវបញ្ជូនទៅប្រធានសភាស៊ើបសួរដើម្បីសម្រេច។

ចំពោះវិវាទសមត្ថកិច្ចដែនដីរវាងសភាស៊ើបសួរច្រើន ត្រូវសម្រេចដោយប្រធានតុលាការកំពូលហើយការសម្រេចរបស់ប្រធានតុលាការកំពូលជាសាលដីកាសម្រេចបិទផ្លូវតវ៉ា។[10] បទប្បញ្ញត្តិនេះចែងអំពីសមត្ថកិច្ចដែរ

[10] មាត្រា ១២៣, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

ចៅក្រមស៊ើបសួរមានសមត្ថកិច្ច ហើយនឹងកំណត់អំពីបញ្ហាក្នុងការដោះស្រាយនៅពេលដែលមានទំនាស់រវាងចៅក្រមស៊ើបសួរច្រើនទៅលើបណ្តឹងតែមួយក៏ដូចជាវិវាទចំពោះសមត្ថកិច្ចសាលាដំបូងជាន់គ្នាផងដែរ។ បញ្ហាត្រង់ថាតើចៅក្រមស៊ើបសួរអាចប្រើប្រាស់អំណាចស្រាវជ្រាវបទល្មើសបានឬទេ ប្រសិនបើជនត្រូវចោទមិនមានវត្តមានក្នុងដែនដីរបស់ខ្លួន។

ជាងនេះទៅទៀត ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាក៏បានផ្តល់នូវសិទ្ធិពន្លាតសមត្ថកិច្ចជូនទៅចៅក្រមស៊ើបសួរបន្ថែមទៀត។ ចំពោះសមត្ថកិច្ចនេះដែរចៅក្រមស៊ើបសួរក៏អាចប្រើប្រាស់អំណាចទៅលើសមត្ថកិច្ចដែនដីដទៃទៀតបានប្រសិនបើជនត្រូវចោទមិនមានវត្តមាននៅលើដែនដីរបស់ខ្លួន។ ចៅក្រមស៊ើបសួរក៏អាចត្រូវបានប្រើប្រាស់អំណាចនេះដោយចេញដីកាចាត់ឲ្យស៊ើបសួរជំនួស ចំពោះដីកាចាត់ឲ្យស៊ើបសួរជំនួសនេះគឺត្រូវបានបែងចែកជាពីរ គឺការចាត់ឲ្យស៊ើបសួរសួរជំនួសចាត់ឲ្យចៅក្រមស៊ើបសួរផ្សេង និងដីកាចាត់ឲ្យស៊ើបសួរដែលចាត់ឲ្យមន្រ្តីនគរបាលយុត្តិធម៌។

### ខ. សមត្ថកិច្ចតាមរឿងក្តី

ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ បានកំណត់សមត្ថកិច្ចរបស់ស្ថាប័នអយ្យការ និងតុលាការតាមដំណាក់កាលនីមួយៗដោយឈរលើស្មារតីនៃគោលការណ៍បែងចែកមុខងាររបស់ស្ថាប័នតុលាអយ្យការ និងតុលាការដែលជាផលវិបាកចេញពីគោលការណ៍បែងចែកអំណាច។ ស្ថាប័នតុលាការពុំអាចប្តឹងមកដោយខ្លួនឯងផ្ទាល់ដើម្បីស៊ើបសួរ ឬវិនិច្ឆ័យបទល្មើសព្រហ្មទណ្ឌឡើយទោះបីជាតុលាការនោះបានដឹងដោយខ្លួនឯងផ្ទាល់នូវបទល្មើសនោះក៏ដោយ។ ដូច្នេះចៅក្រមស៊ើបសួរអាចស៊ើបសួរបានលុះត្រាតែត្រូវបានប្តឹងពីរឿងព្រហ្មទណ្ឌដោយព្រះរាជអាជ្ញា ឬជនរងគ្រោះដែលអាចបើកការស៊ើបសួរដោយតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទៅចៅក្រមស៊ើបសួរ *(មានចង្អុលបង្ហាញក្នុងផ្នែកទី១ កថាខណ្ឌទី៣ ការបើកការស៊ើបសួរ)*។ ប៉ុន្តែការបើកស៊ើបសួរមិនមានលក្ខណៈចាំបាច់ចំពោះការវិនិច្ឆ័យបទល្មើសនោះទេ។ ហេតុដូច្នេះការស៊ើបសួររបស់ចៅក្រមស៊ើបសួរចំពោះបទល្មើសទាំងបីប្រភេទអាស្រ័យលើការប្តឹងពីព្រះរាជអាជ្ញាតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ អន្តរាគមន៍របស់គាត់ត្រូវធ្វើដោយខានមិនបានចំពោះបទឧក្រិដ្ឋ រីឯចំពោះបទមជ្ឈិម ការស៊ើបសួរអាចធ្វើក៏បាន ឬមិនធ្វើក៏បាន។[11] ចៅក្រមស៊ើបសួរមានសមត្ថកិច្ចទៅលើគ្រប់បុគ្គលទាំងអស់លើកលែងតែរឿងព្រហ្មទណ្ឌជាសមត្ថកិច្ចរបស់តុលាការ។

## កថាខណ្ឌទី៣៖ ការបើកការស៊ើបសួរ

ការបើកការស៊ើបសួរ គឺមានគោលបំណងសំខាន់ដើម្បីស្រាវជ្រាវរកភស្តុតាងឲ្យបានគ្រប់គ្រាន់តាមរយៈការសាកសួរ។ ជាធម្មតានៅក្នុងរឿងព្រហ្មទណ្ឌការស៊ើបអង្កេតរបស់មន្រ្តីនគរបាលយុត្តិធម៌ និងការសាកសួរនៅ

[11] មាត្រា ១២២, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

ក្នុងដំណាក់កាលអយ្យការពុំទាន់អាចប្រមូលបាននូវអង្គហេតុ និងភស្តុតាងគ្រប់ជ្រុងជ្រោយបានឡើយដែលអាចបញ្ជូនជនសង្ស័យនោះទៅជំនុំជម្រះបាន ពីព្រោះគេចាត់ទុកថាចំណាត់ការចោទនេះជាដំណាក់កាលបឋម ហេតុដូចនេះ ទើបនីតិវិធីច្បាប់តម្រូវឲ្យមានការបើកការស៊ើបសួរនៅចំពោះមុខចៅក្រមស៊ើបសួរដើម្បីធ្វើយ៉ាងណាស្វែងរកការពិតចាំបាច់សម្រាប់ធានាដល់ការចោទប្រកាន់ និងធានានូវនិរន្តរភាពសម្រាប់ដំណើរការកាត់សេចក្តី។ ជាទូទៅសំណួរជាច្រើនបានលេចឡើងក្នុងដំណាក់កាលមួយនេះ ហើយក៏ត្រូវបានយកមកស៊ើបសួរជនត្រូវចោទនិងជនដែលមានការជាប់ពាក់ព័ន្ធដោយការចោទសួរនោះ គឺដើម្បីចង់ដឹងថាតើជននោះពិតជាបានប្រព្រឹត្តបទល្មើសមែន ឬមិនមែន។

### ក. ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

ការស៊ើបសួរត្រូវបានបើកដោយដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។ ក្នុងករណីបទឧក្រិដ្ឋ ព្រះរាជអាជ្ញាត្រូវបើកការស៊ើបសួរ។ ការបើកការស៊ើបសួរត្រូវបានបើកតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដែលត្រូវប្តឹងទៅចៅក្រមស៊ើបសួរ។ ការស៊ើបសួរអាចបើកប្រឆាំងនឹងបុគ្គលម្នាក់ ឬច្រើននាក់ដោយមានចង្អុលប្រាប់ឈ្មោះ ឬប្រឆាំងនឹងអញ្ញាតជន។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររួមមាន៖[12]

- សេចក្តីសង្ខេបនៃអង្គហេតុ
- ការកំណត់ឈ្មោះបទល្មើស
- ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស និង
- ឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរប្រសិនបើអាចកំណត់បាន។

ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខា។[13] ការបើកការស៊ើបសួរក្នុងករណីបទមជ្ឈិមជាជម្រើសនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញា។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរត្រូវបញ្ជាក់ឲ្យច្បាស់ពីអង្គហេតុដែលបញ្ជូនទៅចៅក្រមស៊ើបសួរ។

ក្នុងការអនុវត្តជាក់ស្តែង សេចក្តីសន្និដ្ឋានត្រូវមានភ្ជាប់មកជាមួយនូវលិខិតផ្សេងៗដែលកំណត់អំពីអង្គហេតុ។ ករណីនេះគ្រាន់តែចុះហត្ថលេខាដល់ទិដ្ឋការលើនិទ្ទេសទាំងនោះវាគ្រប់គ្រាន់ទៅហើយព្រោះវាមានតម្លៃស្មើនឹងការវិភាគនៃលិខិតនេះ។ លិខិតភ្ជាប់ត្រូវបានសន្មត់ថាមានបន្ទុកនូវគ្រប់ការចង្អុលបង្ហាញដែលចាំបាច់នានាសម្រាប់បំភ្លឺចៅក្រមស៊ើបសួរ និងដើម្បីអនុញ្ញាតឲ្យចៅក្រមស៊ើបសួរកំណត់ពីកម្មវត្ថុពិតប្រាកដព្រមទាំងវិសាលភាពនៃបណ្តឹង ដោយផ្អែកទៅលើការចង្អុលបង្ហាញក្នុងលិខិតភ្ជាប់នោះ។ ជាទូទៅលិខិតភ្ជាប់ គឺជាលិខិតដែលចេញក្នុងពេលស៊ើបអង្កេតជាក់ស្តែង ឬពេលស៊ើបអង្កេតបឋម។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរជា

[12] មាត្រា ៤៤, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។
[13] គម្រូនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ មានកំណត់ក្នុងឧបសម្ព័ន្ធទី១

និច្ចកាលជាលិខិតលាយលក្ខណ៍អក្សរដែលត្រូវបានចុះកាលបរិច្ឆេទ និងហត្ថលេខា បើពុំនោះទេនឹងនាំឲ្យមាន មោឃភាពទាំងដីកា និងលិខិតផ្សេងៗទៀតដែលចេញក្រោយមកទៀត។

**ខ. ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី**

បណ្តឹងរបស់ជនរងគ្រោះ គឺជាបណ្តឹងដែលជនរងគ្រោះធ្វើឡើងដើម្បីទទួលបានការជួសជុលព្យសនកម្ម ផ្ទាល់ខ្លួននៅពេលបច្ចុប្បន្ន។ ព្យសនកម្មអាចជាព្យសនកម្មខាងសម្ភារៈរូបរាងកាយ និងផ្លូវចិត្ត។[14]

ចៅក្រមស៊ើបសួរតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលធ្វើឡើងខ្លួនឯងផ្ទាល់ ឬក៏មានអ្នកតំណាង។ ទោះបីជាចៅក្រមស៊ើបសួរទទួលពាក្យបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក៏ដោយក៏ចៅក្រម ស៊ើបសួរត្រូវតែទទួលបាននូវដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរពីអយ្យការជាមុនសិន ទើបអាចធ្វើការស៊ើបសួរ បាន។ ក្នុងន័យនេះដែរក្រោយពីបានទទួលពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចៅក្រម ស៊ើបសួរធ្វើការកត់សម្គាល់ការដាក់ពាក្យបណ្តឹង ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមដីកា ហើយបញ្ជូនបណ្តឹងនេះទៅព្រះរាជអាជ្ញា។[15] នៅពេលដែលទទួលបានការបញ្ជូននេះព្រះរាជអាជ្ញាត្រូវប្តឹងទៅ ចៅក្រមស៊ើបសួរតាមដីកាបញ្ជូនរឿងក្តីឲ្យស៊ើបសួរ ប៉ុន្តែព្រះរាជអាជ្ញាក៏សុំដល់ចៅក្រមស៊ើបសួរកុំឲ្យស៊ើបសួរ ប្រសិនបើបណ្តឹងអាជ្ញាត្រូវផុតរលត់ ឬប្រសិនបើអំពើនោះមិនមែនជាបទល្មើសព្រហ្មទណ្ឌទេ។

ក្នុងករណីដែលព្រះរាជអាជ្ញាបានស្នើសុំឲ្យចៅក្រមស៊ើបសួរធ្វើការស៊ើបសួរ នោះចៅក្រមស៊ើបសួរអាច មានជម្រើសពីរយ៉ាងគឺ៖

- មិនធ្វើការស៊ើបសួរ ដោយចេញដីកាសម្រេចភ្ជាប់ជាមួយសំអាងហេតុ បញ្ជាក់ពីមូលហេតុដែលខ្លួន សម្រេចមិនធ្វើការស៊ើបសួរ ដើម្បីធ្វើការជូនដំណឹងទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណីជាបន្ទាន់។
- ធ្វើការស៊ើបសួរ ដោយចេញដីកាសម្រេចភ្ជាប់ជាមួយសំអាងហេតុ ហើយជូនដំណឹងទៅព្រះរាជអាជ្ញា។

គួរតែកត់សម្គាល់ដែរថា បណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលជាដើមបណ្តឹងរដ្ឋ ប្បវេណីមួយថ្មីដែលទើបតែបញ្ចូលក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនេះឯង ហើយដើមបណ្តឹងរដ្ឋប្បវេណីត្រូវបង់ប្រាក់ តម្កល់ទុកតាមការកំណត់របស់ចៅក្រមស៊ើបសួរតាមដីកាសម្រេច ដោយផ្អែកលើធនធានរបស់ដើមបណ្តឹងរដ្ឋប្ប វេណីនិងទៅលើការលំបាកនៃរឿងក្តីដែលអាចមើលឃើញជាមុន តែចៅក្រមស៊ើបសួរក៏អាចលើកលែងមិនឲ្យបង់ ប្រាក់បានដែរ។ ប្រសិនបើចៅក្រមស៊ើបសួរតម្រូវឲ្យមានការបង់ប្រាក់តម្កល់ទុកតែដើមបណ្តឹងរដ្ឋប្បវេណីមិនព្រម បង់ក្នុងរយៈពេលកំណត់ដោយចៅក្រមទេ នោះចៅក្រមស៊ើបសួរត្រូវប្រកាសថាមិនអាចទទួលពាក្យបណ្តឹងនេះ បាន។ ការតម្រូវឲ្យមានការបង់ប្រាក់តម្កល់ទុកគឺដើម្បីធានាការបង់ប្រាក់ពិន័យរដ្ឋប្បវេណីប្រសិនបើចៅក្រមស៊ើប

[14] មាត្រា ១៣, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។
[15] មាត្រា ១៣៩, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

សួរយល់ឃើញថានីតិវិធីធ្វើឡើងដោយរំលោភ ឬដោយអូសបន្លាយពេលវេលា ចៅក្រមស៊ើបសួរចេញដីកាសម្រេចឲ្យបង់ប្រាក់ពិន័យរដ្ឋប្បវេណី[16] តែប្រាក់ពិន័យនេះពុំអាចលើសពីចំនួនទឹកប្រាក់តម្កល់ទុកបានឡើយ។ ផ្ទុយទៅវិញប្រសិនបើពុំត្រូវបានបង់ប្រាក់ពិន័យរដ្ឋប្បវេណីទេ ប្រាក់តម្កល់ទុកនេះត្រូវបង្វិលទៅឲ្យសាមីខ្លួនវិញនៅពេលបញ្ចប់នីតិវិធី។[17]

**កថាខណ្ឌទី៤៖ ការស្នើសុំឲ្យបំពេញកិច្ច**

ជាគោលការណ៍ស៊ើបសួរជាតួនាទីរបស់ចៅក្រមស៊ើបសួរ ដែលច្បាប់តម្រូវឲ្យចៅក្រមស៊ើបសួរអាចបំពេញភារៈកិច្ចរបស់ខ្លួនតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។ បន្ថែមពីនេះចៅក្រមស៊ើបសួរក៏អាចបើកកិច្ចស៊ើបសួរតាមរយៈការស្នើសុំឲ្យបំពេញកិច្ចដោយជនត្រូវចោទ និងដោយដើមបណ្តឹងរដ្ឋប្បវេណីផងដែរ នេះបញ្ជាក់ឲ្យឃើញថាទាំងព្រះរាជអាជ្ញាក្តី ជនត្រូវចោទក្តី និងដើមបណ្តឹងរដ្ឋប្បវេណីក្តី គឺមានសិទ្ធិអនុញ្ញាតដោយច្បាប់យ៉ាងពេញលេញ ក្នុងការសម្រេចចិត្តស្នើសុំទៅចៅក្រមស៊ើបសួរស្វែងរកការពិតដែលខ្លួនគិតថាមានប្រយោជន៍ដល់រឿងក្តីព្រហ្មទណ្ឌ។ ប៉ុន្តែក្នុងករណីដែលចៅក្រមស៊ើបសួរមានភារៈកិច្ចណាមួយដែលជាឧបសគ្គរាំងស្ទះដល់ការស៊ើបសួរស្វែងរកការពិតនោះ តាមក្រមនីតិវិធីព្រហ្មទណ្ឌក៏បានអនុញ្ញាតឲ្យចៅក្រមស៊ើបសួរអាចចាត់ឲ្យចៅក្រមផ្សេងទៀត ឬមន្ត្រីនគរបាលយុត្តិធម៌ឲ្យបំពេញភារកិច្ចស្រាវជ្រាវជំនួសឲ្យខ្លួនបានផងដែរ។

**ក. ការស្នើសុំបំពេញកិច្ចដោយព្រះរាជអាជ្ញា**

ជាគោលការណ៍នៅគ្រប់ពេលវេលានៃការស៊ើបសួរ ព្រះរាជអាជ្ញាមានសិទ្ធិស្នើសុំឲ្យចៅក្រមធ្វើកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថាមានផលប្រយោជន៍។ ជាធម្មតាការស្នើសុំឲ្យបំពេញកិច្ចរបស់ព្រះរាជអាជ្ញាភាគច្រើន គឺមានគោលបំណងក្នុងការបំពេញបន្ថែមនូវចំណុចខ្វះខាតដែលចៅក្រមស៊ើបសួរបានបំពេញដើម្បីឲ្យកាន់តែមានភាពច្បាស់លាស់។ ដូច្នេះនៅគ្រប់ពេលវេលានៃការស៊ើបសួរ ព្រះរាជអាជ្ញាអាចស្នើសុំឲ្យចៅក្រមស៊ើបសួរធ្វើកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថាមានប្រយោជន៍។ ករណីនេះដែរបើចៅក្រមស៊ើបសួរមិនព្រមធ្វើតាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាទេ នោះចៅក្រមស៊ើបសួរត្រូវចេញដីកាបដិសេធនៅក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីខ្លួនបានទទួល។ ហើយដីកាដែលចៅក្រមស៊ើបសួរសម្រេចចេញត្រូវមានសំអាងហេតុ និងត្រូវជូនដំណឹងជាបន្ទាន់ទៅព្រះរាជអាជ្ញាក្នុងចិរវេលាយ៉ាងឆាប់បំផុត។ ប៉ុន្តែក្នុងករណីដែលចៅក្រមស៊ើបសួរមិនបានធ្វើការសម្រេចនៅក្នុងចិរវេលា ១៥ (ដប់ប្រាំ) ថ្ងៃទេ ព្រះរាជអាជ្ញាអាចប្តឹងដោយផ្ទាល់ទៅសភាស៊ើបសួរតាម

[16] មាត្រា ១៤១, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[17] មាត្រា ១៤០, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

រយៈពាក្យសុំដើម្បីឲ្យសភាស៊ើបសួរសម្រេចជំនួសចៅក្រមស៊ើបសួរ។[18]

### ខ. ការស្នើសុំបំពេញកិច្ចដោយជនត្រូវចោទ

នៅគ្រប់ពេលវេលានៃការស៊ើបសួរ ជនត្រូវចោទមានសិទ្ធិស្នើសុំឲ្យចៅក្រមស៊ើបសួរ សួរចម្លើយខ្លួន សួរតទល់គ្នា ស្តាប់ចម្លើយសាក្សី ឬចុះទៅទីកន្លែងបានដោយពាក្យសុំត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយមានសំអាងហេតុ។ ក្នុងករណីដែលចៅក្រមស៊ើបសួរមិនព្រមធ្វើតាមពាក្យសុំទេ ចៅក្រមស៊ើបសួរត្រូវចេញដីកាបដិសេធក្នុងចិរវេលា ១ (មួយ) ខែក្រោយពីទទួលពាក្យសុំ។ ដីកាត្រូវមានសំអាងហេតុហើយត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញានិងជនត្រូវចោទ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងចិរវេលា ១ (មួយ) ខែនោះទេជនត្រូវចោទអាចប្តឹងដោយផ្ទាល់សុំសភាស៊ើបសួរតាមរយៈពាក្យសុំដើម្បីឲ្យសភាស៊ើបសួរសម្រេចជំនួសចៅក្រមស៊ើបសួរ។[19]

### គ. ការស្នើសុំបំពេញកិច្ចដោយដើមបណ្តឹងរដ្ឋប្បវេណី

នៅគ្រប់វេលានៃការស៊ើបសួរ ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិស្នើសុំឲ្យចៅក្រមស៊ើបសួរ សួរចម្លើយខ្លួន ស្តាប់ចម្លើយសាក្សី សួរចម្លើយជនត្រូវចោទ សួរតទល់គ្នា ឬចុះទៅទីកន្លែងបានដោយពាក្យសុំត្រូវធ្វើជាលាយលក្ខណ៍អក្សរហើយមានសំអាងហេតុ។ ក្នុងករណីដែលចៅក្រមស៊ើបសួរមិនព្រមធ្វើតាមពាក្យសុំទេ ចៅក្រមស៊ើបសួរត្រូវចេញដីកាបដិសេធក្នុងចិរវេលា ១ (មួយ) ខែ ក្រោយពីទទួលពាក្យសុំ។ ដីការត្រូវមានសំអាងហេតុ ហើយត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញានិងដើមបណ្តឹងរដ្ឋប្បវេណី។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងចិរវេលា១ (មួយ) ខែទេដើមបណ្តឹងរដ្ឋប្បវេណីអាចប្តឹងដោយផ្ទាល់សុំសភាស៊ើបសួរតាមរយៈពាក្យសុំដើម្បីឲ្យសភាស៊ើបសួរសម្រេចជំនួសចៅក្រមស៊ើបសួរ។[20]

## ផ្នែកទី២៖ សិទ្ធិអំណាចរបស់ចៅក្រមស៊ើបសួរក្នុងការស៊ើបសួរ

នៅក្នុងដំណាក់កាលស៊ើបសួរ ចៅក្រមស៊ើបសួរមានតួនាទីសំខាន់ក្នុងការស៊ើបសួរស្វែងរកភស្តុតាងដាក់បន្ទុកផង និងដោះបន្ទុកផងដើម្បីស្វែងរកការពិត ឬអត្ថិភាពនៃបទល្មើសមុននឹងបញ្ជូនរឿងទៅជំនុំជម្រះ។ ជាមួយគ្នានេះដែរ ចៅក្រមស៊ើបសួរនៅពេលបំពេញកិច្ចស៊ើបសួររបស់ខ្លួនក្នុងដំណាក់កាលស៊ើបសួរត្រូវតែមានក្រឡាបញ្ជីអមជាមួយជានិច្ច។[21] ដោយផ្អែកតាមស្មារតីនៃក្រមនីតិវិធីព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរទទួលបានសិទ្ធិអំណាចក្នុងការស្វែងរកពិរុទ្ធភាពដែលក្នុងនោះចៅក្រមស៊ើបសួរ គឺអាចស្វែងរកភស្តុតាងតាមរយៈពីររបៀប

---

[18] មាត្រា ១៣២, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[19] មាត្រា ១៣៣, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[20] មាត្រា ១៣៤, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[21] មាត្រា ១២៨, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

ដែលមានដូចជា៖ ទី១ ការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ និងទី២ ការចាត់ឲ្យស៊ើបសួរជំនួស។

**កថាខណ្ឌទី១៖ ការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ**

ជាការពិតណាស់ចៅក្រមស៊ើបសួរអាចធ្វើការស្រាវជ្រាវដោយខ្លួនឯងដើម្បីស្វែងរកភស្តុតាងឲ្យឃើញនូវការពិតពោលគឺជាការស្វែងរកនូវពិរុទ្ធភាពនៃបទល្មើសដែលមានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។ ម្យ៉ាងវិញទៀតនៅក្នុងសមត្ថកិច្ចរបស់ខ្លួនចៅក្រមស៊ើបសួរអាចធ្វើការបើកការស៊ើបសួរដោយខ្លួនឯងបាន ប្រសិនបើគាត់យល់ឃើញថាការបើកការស៊ើបសួរនោះមានសារៈសំខាន់ដើម្បីស្វែងរកការពិតដោយមិនចាំបាច់មានការស្នើសុំឬមានបណ្តឹងស្នើសុំពីភាគីឡើយ នៅក្នុងករណីដែលគាត់បានរកឃើញថានៅក្នុងបទល្មើសដែលត្រូវបានចោទប្រកាន់ដោយព្រះរាជអាជ្ញា នោះមានលេចនូវមុខសញ្ញានៃការចូលរួមប្រព្រឹត្តបទល្មើសពីសំណាក់បុគ្គលថ្មីផ្សេងទៀត។[22] ក្នុងចំណុចនេះគឺចង់មានន័យថាចៅក្រមស៊ើបសួរមានឆន្ទានុសិទ្ធិពេញលេញក្នុងការពិចារណាឬការសម្រេចឲ្យធ្វើការស៊ើបសួរដោយខ្លួនឯង ប្រសិនបើគាត់យល់ឃើញថាមានអត្ថប្រយោជន៍ក្នុងការស្វែងរកការពិតបាន។ ទន្ទឹមនឹងនេះដែរចៅក្រមស៊ើបសួរអាចធ្វើការស៊ើបសួរដើម្បីស្វែងរកការពិតតាមរយៈកម្មវត្ថុពីរដែលក្នុងនោះរួមមាន៖

ទី១. ការស្រាវជ្រាវទាក់ទងនឹងបុគ្គលមានដូចជា៖ ការជូនដំណឹងអំពីការដោយឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យ ការសួរចម្លើយជនត្រូវចោទ ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងការស្តាប់ចម្លើយសាក្សី។

ទី២. ការស្រាវជ្រាវទាក់ទងនឹងវត្ថុមានដូចជា៖ ការឆែកឆេរចាប់យកវត្ថុតាង ការធ្វើកោសលវិច័យ និងការស្តាប់ទូរស័ព្ទ។

**ក. ការជូនដំណឹងអំពីការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យ**

ដីកាសម្រេចដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ គឺជាវិធានការនៃសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរជំនួសឲ្យការឃុំខ្លួនបណ្តោះអាសន្ន ក្នុងកម្មវត្ថុរឹតបន្តឹងនូវសេរីភាពលើជនត្រូវចោទដែលត្រូវបានចោទប្រកាន់អំពីបទល្មើសដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ។ ចៅក្រមស៊ើបសួរអាចសម្រេចដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការតាមគំនិតផ្តួចផ្តើមផ្ទាល់របស់ខ្លួន ឬតាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា (ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ)។ នៅក្នុងដីកាសម្រេចរបស់ខ្លួន ចៅក្រមស៊ើបសួរត្រូវបញ្ជាក់អំពីកាតព្វកិច្ចដែលតម្រូវទៅលើជនត្រូវចោទ។[23]

ជាធម្មតាចៅក្រមស៊ើបសួរមានសិទ្ធិចេញដីកាសម្រេចដាក់ជនត្រូវចោទ និងបុគ្គលដែលស្ថិតក្នុងឋានៈជាចារី ជាអ្នកផ្តើមគំនិត ឬជាអ្នកសមគំនិត ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការត្រូវជូនដំណឹងក្នុង

[22] កើត រិទ្ធ, បទសម្ភាសដោយពិធីការិនីនៃទូរទស្សន៍ជាតិកម្ពុជា, ទូរទស្សន៍ជាតិកម្ពុជា, ០៨ មករា ២០០៨។

[23] មាត្រា ២២៦, វាកខណ្ឌទី១, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

រយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។ ផ្ទុយទៅវិញប្រសិនបើចៅក្រមស៊ើបសួរបានទទួលបណ្តឹងសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ដែលសុំឲ្យដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការតែខ្លួនបដិសេធមិនព្រមសម្រេចតាមការសុំទេ គាត់ត្រូវចេញដីកាបដិសេធការសុំនេះក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ។ ដីកាសម្រេចនេះត្រូវជូនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានចេញសេចក្តីសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃទេ ព្រះរាជអាជ្ញាអាចធ្វើពាក្យប្តឹងទៅសភាស៊ើបសួរដែលជាអ្នកសម្រេចជំនួស។[24]

នៅពេលដែលជនត្រូវចោទចូលបង្ហាញខ្លួនលើកដំបូង ចៅក្រមស៊ើបសួរត្រូវតែពិនិត្យមើលអត្តសញ្ញាណជនត្រូវចោទ ហើយប្រាប់ជននោះឲ្យបានដឹងពីរឿងរ៉ាវដែលខ្លួនចោទប្រកាន់ និងប្រាប់អំពីឈ្មោះបទល្មើសដែលកំណត់ដោយច្បាប់។ ចៅក្រមស៊ើបសួរប្រាប់ជនត្រូវចោទថាខ្លួនអាចឆ្លើយ ឬមិនឆ្លើយបានដោយសេរី។ និទ្ទេសស្តីពីការប្រាប់នេះត្រូវបានចុះនៅក្នុងកំណត់ហេតុនៅពេលចូលបង្ហាញខ្លួនលើកដំបូង។

ប្រសិនបើជនត្រូវចោទចង់ឆ្លើយនោះចៅក្រមស៊ើបសួរត្រូវទទួលចម្លើយនោះភ្លាម មានន័យថាខណៈពេលជនត្រូវចោទបានចូលបង្ហាញខ្លួនដំបូងចៅក្រមស៊ើបសួរមានកិច្ចសំខាន់បីគឺ ការធ្វើកំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូង[25] កំណត់ហេតុស្តីពីការពិភាក្សាដេញដោលចំពោះមុខ[26] និងកំណត់ហេតុស្តីពីការសួរចម្លើយជនត្រូវចោទ។ ក្រោយមកទៀតចៅក្រមស៊ើបសួរប្រាប់ជនត្រូវចោទឲ្យបានដឹងអំពីសិទ្ធិរបស់ខ្លួនក្នុងការជ្រើសរើសមេធាវី ឬការសុំឲ្យចាត់តាំងមេធាវីឲ្យខ្លួនដោយអនុវត្តតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។ ចំពោះជនត្រូវចោទជាអនីតិជនត្រូវតែមានមេធាវីអមជានិច្ច បើគ្មានការជ្រើសរើសដោយជនត្រូវចោទទេមេធាវីត្រូវបានចាត់តាំងនៅក្នុងលក្ខខណ្ឌដែលចែងដោយច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។ ក្រោយពីការចូលខ្លួនចូលបង្ហាញខ្លួនលើកទីមួយជនត្រូវចោទដែលនៅក្រៅឃុំត្រូវប្រកាសប្រាប់ដល់ចៅក្រមស៊ើបសួរអំពីអាសយដ្ឋានរបស់ខ្លួន។ ជនត្រូវចោទនោះត្រូវបានដំណឹងថា៖

- ខ្លួនត្រូវតែជូនព័ត៌មានដល់ចៅក្រមស៊ើបសួរនៅពេលណាដែលខ្លួនប្តូរអាសយដ្ឋាន
- គ្រប់ការឲ្យដំណឹងដែលបានធ្វើឡើងតាមអាសយដ្ឋានចុងក្រោយ ដែលប្រកាសឡើងដោយជនត្រូវចោទនោះត្រូវបានចាត់ទុកថាបានធ្វើឡើងដល់សាមីខ្លួនផ្ទាល់។[27]

---

[24] មាត្រា ២២៦, វាក្យខណ្ឌទី៣ និងទី៤, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[25] គម្រូនៃកំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូង មានកំណត់ក្នុងឧបសម្ព័ន្ធទី២

[26] គម្រូនៃកំណត់ហេតុស្តីពីការពិភាក្សាដេញដោលចំពោះមុខ មានកំណត់ក្នុងឧបសម្ព័ន្ធទី៣

[27] មាត្រា ១៤៣, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

ការឲ្យដំណឹងព្រមទាំងការប្រកាសស្តីពីការផ្លាស់ប្តូរអាសយដ្ឋាននោះ ត្រូវចុះនៅក្នុងកំណត់ហេតុនៅពេលចូលបង្ហាញខ្លួនលើកដំបូង។

ក្នុងករណីចាំបាច់ចៅក្រមស៊ើបសួរត្រូវហៅអ្នកបកប្រែ។ អ្នកបកប្រែត្រូវស្បថតាមជំនឿសាសនារបស់ខ្លួនថានឹងជួយដល់តុលាការ និងបកប្រែឲ្យបានត្រឹមត្រូវតាមចម្លើយទាំងឡាយ។ ក្នុងករណីណាក៏ដោយអ្នកបកប្រែមិនអាចត្រូវជ្រើសរើសក្នុងចំណោមចៅក្រម ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ ភាគី ឬសាក្សីទេ។[28]

### ខ. ការសួរចម្លើយជនត្រូវចោទ

នៅពេលចូលបង្ហាញខ្លួនលើកដំបូង ចៅក្រមស៊ើបសួរពិនិត្យអត្តសញ្ញាណរបស់ជនត្រូវចោទប្រាប់ជននេះឲ្យដឹងពីរឿងរ៉ាវដែលត្រូវបានចោទប្រកាន់ និងប្រាប់អំពីឈ្មោះនៃបទល្មើស។ ហើយចៅក្រមស៊ើបសួរប្រាប់ជនត្រូវចោទថាខ្លួនអាចឆ្លើយ ឬមិនឆ្លើយដោយសេរី។ ប៉ុន្តែត្រូវតែនិទ្ទេសស្តីពីការប្រាប់នេះត្រូវចុះក្នុងកំណត់ហេតុនៅពេលចូលបង្ហាញខ្លួនដំបូង។ ការសួរចម្លើយជនត្រូវចោទ គឺដើម្បីទទួលបានព័ត៌មានពាក់ព័ន្ធនឹងបទល្មើស ហើយវាជាដំណាក់កាលមួយក្នុងការបំភ្លឺឲ្យឃើញកាន់តែច្បាស់នូវអង្គហេតុណាមួយ ឬបុគ្គលិកលក្ខណៈរបស់ជនត្រូវចោទផងដែរ។

ក្នុងការសួរចម្លើយនេះ កាលណាជនត្រូវចោទមានមេធាវីអម ចៅក្រមស៊ើបសួរត្រូវកោះហៅមេធាវីយ៉ាងតិចបំផុត ៥ (ប្រាំ) ថ្ងៃមុនពេលសួរចម្លើយ។ ក្នុងចិរវេលានេះមេធាវីអាចពិនិត្យមើលសំណុំរឿងនីតិវិធី។ ជនត្រូវចោទអាចត្រូវសួរចម្លើយដោយចៅក្រមស៊ើបសួរបានតែនៅចំពោះមុខមេធាវីរបស់ខ្លួនតែប៉ុណ្ណោះ។ ប៉ុន្តែប្រសិនជាមេធាវីត្រូវបានកោះហៅ[29] យ៉ាងត្រឹមត្រូវហើយមិនចូលបង្ហាញខ្លួននៅថ្ងៃនិងម៉ោងកំណត់ទេ នោះចៅក្រមស៊ើបសួរអាចសួរចម្លើយជនត្រូវចោទដោយគ្មានវត្តមានមេធាវី។ និទ្ទេសស្តីពីអវត្តមានមេធាវីនេះត្រូវបានចុះនៅក្នុងកំណត់ហេតុសួរចម្លើយជនត្រូវចោទឲ្យបានត្រឹមត្រូវ។

ក្នុងករណីពិសេស ចៅក្រមស៊ើបសួរក៏អាចសួរចម្លើយជនត្រូវចោទដោយមិនបាច់កោះហៅមេធាវីបានប្រសិនបើជនត្រូវចោទបោះបង់ចោលយ៉ាងជាក់លាក់នូវវត្តមានរបស់មេធាវីខ្លួន។ ការបោះបង់ចោលនេះត្រូវបានចុះក្នុងកំណត់ហេតុផ្សេងស្តីពីកំណត់ហេតុសួរចម្លើយ និងចុះហត្ថលេខាដោយជនត្រូវចោទផ្ទាល់។[30]

ក្នុងករណីបន្ទាន់ចៅក្រមស៊ើបសួរក៏អាចសួរចម្លើយដោយមិនចាំបាច់កោះហៅមេធាវីផងបានដែរ។ ភាពបន្ទាន់នេះត្រូវតែបណ្តាលមកពីគ្រោះថ្នាក់រហូតដល់ស្លាប់ ឬបណ្តាលមកពីការភ័យខ្លាចពីការបាត់បង់តម្រុយនៃ

[28] មាត្រា ១៤៤, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[29] គម្រូនៃដីកាកោះ (ជនត្រូវចោទ) មានកំណត់ក្នុងឧបសម្ព័ន្ធទី៤

[30] គម្រូនៃកំណត់ហេតុស្តីពីការសួរចម្លើយជនត្រូវចោទ មានកំណត់ក្នុងឧបសម្ព័ន្ធទី៥

ភស្តុតាង ហើយប្រភេទនៃភាពបន្ទាន់ត្រូវតែចុះនិទ្ទេសនៅក្នុងកំណត់ហេតុ។[31] ចៅក្រមស៊ើបសួរអាចហៅរកអ្នកបកប្រែដើម្បីធ្វើការបកប្រែឲ្យជនត្រូវចោទបាន។

នៅពេលសួរចម្លើយជនត្រូវចោទ ព្រះរាជអាជ្ញា និងមេធាវី អាចលើកសំណួរផ្សេងៗដែលមានប្រយោជន៍ដល់បទល្មើសបានដែរដោយមានការអនុញ្ញាតពីចៅក្រមស៊ើបសួរ[32]។ ក្នុងករណីមិនអនុញ្ញាតត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ។[33]

កាលណាចិរវេលា ៤ (បួន) ខែ បានកន្លងផុតទៅចាប់ពីពេលសួរចម្លើយនៅពេលបង្ហាញខ្លួនលើកដំបូង ជនត្រូវចោទមិនត្រូវបានសួរចម្លើយ ឬសួរតទល់ទេ ចៅក្រមស៊ើបសួរត្រូវតែទទួលចម្លើយប្រសិនបើជនត្រូវចោទបានស្នើសុំ។ បើចៅក្រមស៊ើបសួរមិនព្រមកោះហៅជនត្រូវចោទក្នុងចិរវេលា ១ (មួយ) ខែ បន្ទាប់ពីការសុំទេនោះ ជនត្រូវចោទអាចប្តឹងផ្ទាល់ទៅសភាស៊ើបសួរដែលទទួលចម្លើយនេះដោយខ្លួនឯងបាន បន្ទាប់មកកំណត់ហេតុត្រូវបញ្ជូនទៅចៅក្រមស៊ើបសួរ។[34]

ក្រៅពីនេះមេធាវីរបស់ជនត្រូវចោទដែលជាប់ឃុំ ក៏អាចប្រាស្រ័យទាក់ទងដោយសេរីជាមួយកូនក្តីរបស់ខ្លួននៅក្នុងពន្ធនាគារ ឬនៅក្នុងមណ្ឌលឃុំខ្លួន។ ការសន្ទនារបស់មេធាវី និងជនត្រូវចោទមិនអាចត្រូវគេស្តាប់ ឬថតបានទេ។ មេធាវីអាចអានលិខិតនៃសំណុំរឿងក្តីឲ្យកូនក្តីស្តាប់ ផ្ទុយទៅវិញមេធាវីមិនអាចឲ្យលិខិតថតចម្លងពីលិខិតសំណុំរឿងដល់កូនក្តីរបស់ខ្លួនបានឡើយ។[35]

### គ. ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

ចំពោះគោលបំណងនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី គឺដើម្បីទទួលបាននូវព័ត៌មានផ្សេងៗពាក់ព័ន្ធជាមួយនឹងបទល្មើសក៏ដូចជាអំពើព្យសនកម្មផ្សេងៗ ដែលជាហេតុបណ្តាលមកពីការប្រព្រឹត្តបទល្មើស និងការទាមទារសំណងការខូចខាត។ ដើមបណ្តឹងរដ្ឋប្បវេណីអាចជាជនរងគ្រោះ ឬជាជនទាំងឡាយណាដែលទទួលរងនូវអំពើល្មើសហើយព្យសនកម្មនៃការខូចខាតមានពិតប្រាកដ ឬអាចជាអាណាព្យាបាលរបស់ជនរងគ្រោះ។ ប្រសិនបើក្នុងករណីដើមបណ្តឹងរដ្ឋប្បវេណីជាជនរងគ្រោះនៃបទល្មើស ដូច្នេះការស្តាប់ចម្លើយនេះវាពិតជាមានប្រយោជន៍ជាច្រើនក្នុងការស្រាវជ្រាវពីជនរងគ្រោះ ដែលជាជនជួបហេតុការណ៍ផ្ទាល់ខ្លួនដោយបានការរំលោភបំពានពីសំណាក់ចារី ដែលចម្លើយនេះអាចចង្អុលបង្ហាញមុខ ឬឈ្មោះចារី ឬជនពាក់ព័ន្ធអាចជាសហចារី អ្នកផ្តើមគំនិត អ្នកសមគំនិត ឬសាក្សីផ្សេងទៀត។ ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានរៀបរាប់អំពីថ្ងៃ ខែ ឆ្នាំ

---

[31] មាត្រា ១៤៥, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[32] មាត្រា ១៤៦, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[33] គម្រូនៃកំណត់ហេតុស្តីពីការសួរចម្លើយតទល់ មានកំណត់ក្នុងឧបសម្ព័ន្ធទី៦

[34] មាត្រា ១៤៨, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[35] មាត្រា ១៤៩, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

ដែលខ្លួនទទួលរងអំពើល្មើសច្បាប់របស់ពិរុទ្ធជន។ ចម្លើយនេះត្រូវបានរៀបរាប់អំពីទំនាក់ទំនងរវាងអ្នកទាំងពីរ (ជនរងគ្រោះ និងជនត្រូវចោទ) ក្នុងរយៈកាលមុនពេលកើតហេតុហើយរៀបរាប់ដល់សកម្មភាពរបស់ជនត្រូវចោទដែលធ្វើមកលើខ្លួន។ ទន្ទឹមនឹងយកចម្លើយពីដំណើររឿងហេតុដែលកើតមានឡើង ចៅក្រមស៊ើបសួរក៏ត្រូវសួរបន្ថែមនូវសំណូមពររបស់ជនរងគ្រោះទៀតផងដែរ គឺដើម្បីឈានដល់ការវិនិច្ឆ័យបាននូវអំពើរបស់អ្នកប្រព្រឹត្តបទល្មើស និងថែមទាំងផ្តល់នូវភាពយុត្តិធម៌ជូនជនរងគ្រោះ។

ដើមបណ្តឹងរដ្ឋប្បវេណីអាចពឹងពាក់មេធាវីបានដើម្បីការពារប្រយោជន៍របស់ខ្លួនបាន។ ក្នុងករណីនេះ ចៅក្រមស៊ើបសួរត្រូវបានកោះហៅមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីយ៉ាងតិចបំផុត ៥ (ប្រាំ) ថ្ងៃ មុនពេលស្តាប់ចម្លើយដើម្បីទុកចិរវេលានេះឲ្យមេធាវីអាចពិនិត្យសំណុំរឿងបាន។ ដើមបណ្តឹងរដ្ឋប្បវេណីអាចត្រូវបានគេស្តាប់ចម្លើយនៅតែចំពោះមុខមេធាវីរបស់ខ្លួនប៉ុណ្ណោះ។ ប៉ុន្តែបើមេធាវីដែលត្រូវបានកោះហៅយ៉ាងត្រឹមត្រូវហើយមិនបានចូលបង្ហាញខ្លួននៅថ្ងៃ និងម៉ោងតាមកំណត់ទេ ចៅក្រមស៊ើបសួរក៏អាចស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីដោយគ្មានវត្តមានមេធាវី។ និទ្ទេសស្តីពីអវត្តមានត្រូវបានចុះក្នុងកំណត់ហេតុស្តាប់ចម្លើយ។

ក្នុងករណីពិសេស ចៅក្រមស៊ើបសួរអាចស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីបានដោយមិនចំបាច់កោះហៅមេធាវី ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីបោះបង់ចោលយ៉ាងជាក់លាក់នូវវត្តមានមេធាវីរបស់ខ្លួន។[36] ការបោះបង់នេះត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុមួយដោយឡែកពីកំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងត្រូវចុះហត្ថលេខាដោយដើមបណ្តឹងរដ្ឋប្បវេណី។[37]

ក្នុងករណីបន្ទាន់ ចៅក្រមស៊ើបសួរក៏អាចស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីដោយមិនចាំបាច់កោះហៅមេធាវីបានដែរ។ ភាពបន្ទាន់ត្រូវបណ្តាលមកពីគ្រោះថ្នាក់ដល់ស្លាប់ ឬបណ្តាលមកពីភ័យខ្លាចបាត់បង់តម្រុយភស្តុតាង។ ប្រភេទនៃភាពបន្ទាន់ត្រូវតែចុះនិទ្ទេសនៅក្នុងកំណត់ហេតុ។[38] ចៅក្រុមស៊ើបសួរក៏អាចស្វែងរកអ្នកបកប្រែបានក្នុងករណីជនរងគ្រោះត្រូវការជាចាំបាច់។ ម្យ៉ាងវិញទៀតនៅក្នុងពេលស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ព្រះរាជអាជ្ញា និងមេធាវីអាចលើកសំណួរមកសួរ និងពិភាក្សាដេញដោលបានដោយមានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។ ក្នុងករណីមិនអនុញ្ញាតករណីនោះត្រូវបានចុះនិទ្ទេសនៅក្នុងកំណត់ហេតុ។[39]

---

[36] គម្រូនៃដីកាកោះដើមបណ្តឹងរដ្ឋប្បវេណី មានកំណត់ក្នុងឧបសម្ព័ន្ធទី៧

[37] គម្រូនៃកំណត់ហេតុស្តីការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី មានកំណត់ក្នុងឧបសម្ព័ន្ធទី៨

[38] មាត្រា ១៥០, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[39] មាត្រា ១៥១, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

**ឃ. ការស្តាប់ចម្លើយសាក្សី**

សាក្សី គឺជារូបវន្តបុគ្គលដែលបានដឹងពីរឿងរ៉ាវពីអតីតកាល ឬហេតុការណ៍ដែលបានកើតឡើងពីមុនទាក់ទងនឹងព្រឹត្តិការណ៍បទល្មើសដែលត្រូវបានតុលាការ ឬអាជ្ញាធរបានកោះអញ្ជើញមកបំភ្លឺពីរឿងរ៉ាវដែលបានកើតឡើងនៅចំពោះមុខ។ សាក្សីគឺមានពីរប្រភេទគឺសាក្សីដាក់បន្ទុក និងសាក្សីដោះបន្ទុក។

នៅក្នុងដំណាក់កាលស៊ើបសួរ ការស្តាប់ចម្លើយសាក្សីរបស់ចៅក្រមស៊ើបសួរអាចស្តាប់ចម្លើយបុគ្គលគ្រប់រូបដែលចម្លើយនោះអាចមានប្រយោជន៍ក្នុងការសម្តែងឲ្យឃើញការពិត។ ចៅក្រមស៊ើបសួរអាចស្តាប់ចម្លើយសាក្សីដាច់ពីគ្នាដោយគ្មានវត្តមានជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។ម្យ៉ាងវិញទៀតចៅក្រមស៊ើបសួរក៏អាចសួរតទល់គ្នារវាងជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីផងបានដែរ។ បុគ្គលគ្រប់រូបដែលត្រូវបានចៅក្រមស៊ើបសួរកោះហៅក្នុងឋានៈជាសាក្សីត្រូវតែមកបង្ហាញខ្លួន។[40] ក្នុងករណីសាក្សីនៅរឹងទទឹងនោះ ចៅក្រមស៊ើបសួរអាចសុំឲ្យកងកម្លាំងសាធារណៈបង្ខំសាក្សីនេះឲ្យចូលមកបង្ហាញខ្លួនបាន។ ចៅក្រមស៊ើបសួរចេញបញ្ជាឲ្យចូលមកបង្ហាញខ្លួនដោយបញ្ជានេះត្រូវតែមានអត្តសញ្ញាណរបស់សាក្សី និងចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរព្រមទាំងមានបោះត្រាផងដែរ។[41] រាល់ចម្លើយរបស់សាក្សីគឺមានប្រយោជន៍ក្នុងការសម្តែងឲ្យឃើញការពិតនៃអង្គហេតុ កាលណាចម្លើយនោះស៊ីចង្វាក់គ្នាទៅនឹងចម្លើយរបស់ជនត្រូវចោទ ឬជនរងគ្រោះ ហើយវាក៏ជាមូលដ្ឋានមួយផ្នែកសម្រាប់វិនិច្ឆ័យរបស់ចៅក្រមស៊ើបសួរ។ ប៉ុន្តែរាល់ចម្លើយរបស់សាក្សីទាំងអស់ចៅក្រមស៊ើបសួរមានសិទ្ធិសម្រេចថា គួរជឿ ឬមិនគួរជឿ។

មុននឹងអនុញ្ញាតឲ្យសាក្សីបំភ្លឺ គឺច្បាប់តម្រូវឲ្យសាក្សីម្នាក់ៗត្រូវស្បថតាមសាសនា ឬជំនឿរបស់ខ្លួនថានិយាយការពិត[42] ដែលទម្រង់នៃការស្បថត្រូវធ្វើដូចមានក្នុងឧបសម្ព័ន្ធនៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ប្រសិនបើសាក្សីមិនចេះភាសាខ្មែរ (និយាយ អាន ស្តាប់) នោះទេ ចៅក្រមស៊ើបសួរអាចស្វែងរកអ្នកបកប្រែម្នាក់ដើម្បីស្តាប់ចម្លើយសាក្សី។ ចំពោះការសម្បថនេះសាក្សីមួយចំនួនត្រូវបានច្បាប់អនុញ្ញាតឲ្យរួចផុតពីសម្បថមានដូចជា៖

- ឳពុក ម្តាយ និងបុព្វជនគ្រប់រូបរបស់ជនត្រូវចោទ។
- កូនប្រុស កូនស្រី និងបច្ឆាជនគ្រប់រូបផ្សេងទៀតរបស់ជនត្រូវចោទ។
- បង ប្អូនប្រុស ស្រីរបស់ជនត្រូវចោទ។
- បង ប្អូនថ្លៃប្រុស ស្រីរបស់ជនត្រូវចោទ។
- ប្តី ឬ ប្រពន្ធរបស់ជនត្រូវចោទ ទោះបីបានលែងលះគ្នាហើយក៏ដោយ។

---

[40] គម្រូនៃដីកាកោះហៅសាក្សី មានកំណត់ក្នុងឧបសម្ព័ន្ធទី៩

[41] មាត្រា ១៥៣, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[42] គម្រូនៃកំណត់ហេតុស្តីការធ្វើសម្បថ មានកំណត់ក្នុងឧបសម្ព័ន្ធទី១០

- កុមារអាយុតិចជាង ១៤ (ដប់បួន) ឆ្នាំ។[43]

ដើម្បីគោរពសិទ្ធិការពារខ្លួន ចៅក្រមស៊ើបសួរមិនអាចស្តាប់ចម្លើយក្នុងឋានៈជាសាក្សី និងបុគ្គលណាមួយដែលមានតម្រុយពិរុទ្ធភាពថាបានប្រព្រឹត្តបទល្មើសនោះទេ គ្រាន់តែជូនដំណឹងអំពីការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានហើយ។ ប្រសិនបើសាក្សីឈឺ ឬមិនអាចធ្វើដំណើរបានចៅក្រមស៊ើបសួរ និងក្រឡាបញ្ជីអាចចុះទៅកាន់លំនៅឋាន ឬទីកន្លែងដែលសាក្សីនោះនៅដើម្បីទទួលចម្លើយ។[44] អ្វីដែលសំខាន់នោះគឺគ្រប់រាល់ពេលស្តាប់ចម្លើយសាក្សី ចៅក្រមស៊ើបសួរដែលមានក្រឡាបញ្ជីអមត្រូវធ្វើកំណត់ហេតុជាចាំបាច់។[45]

### ខ. ការឆែកឆេរ និងការចាប់យកវត្ថុតាង

ការឆែកឆេរ និងចាប់យកវត្ថុតាង គឺជាវិធានការមួយដែលចៅក្រមស៊ើបសួរអនុវត្តដើម្បីស្វែងរកការពិតនៃពិរុទ្ធភាពរបស់ជនល្មើសទាំងឡាយណាដែលប្រព្រឹត្តបទល្មើសបង្កគ្រោះថ្នាក់ដល់សង្គមជាតិ និងប៉ះពាល់ដល់ប្រយោជន៍របស់ប្រជាពលរដ្ឋ។ តាមក្រមនីតិវិធីព្រហ្មទណ្ឌចៅក្រមស៊ើបសួរមានសិទ្ធិក្នុងការឆែកឆេរ និងចាប់យកវត្ថុតាងដើម្បីជាប្រយោជន៍ក្នុងការស្រាវជ្រាវ។

ការឆែកឆេរលំនៅឋាន ជាវិធានការបង្ខិតបង្ខំរបស់អាជ្ញាធរមានសមត្ថកិច្ចក្នុងការស្វែងរកវត្ថុតាងនានាសម្រាប់បំភ្លឺការពិតនៃអំពើអ្វីមួយដើម្បីធានាការដោះស្រាយបណ្តឹងណាមួយឲ្យបានត្រឹមត្រូវតាមច្បាប់។ អំណាចនៃការឆែកឆេរលំនៅឋានបណ្តាលឲ្យប៉ះពាល់ដល់សិទ្ធិស្របច្បាប់របស់បុគ្គលឯកជន សិទ្ធិខាងលំនៅឋាន ទ្រព្យសម្បត្តិ សេរីភាព កិត្តិយស និងសេចក្តីថ្លៃថ្នូរ។ ដូច្នេះអាជ្ញាធរមានសមត្ថកិច្ចត្រូវតែធ្វើឲ្យបានត្រឹមត្រូវតឹងរ៉ឹងបំផុតដោយមានសំអាងច្បាស់លាស់ដែលជាមូលដ្ឋានពិត និងស្របតាមបញ្ញត្តិច្បាប់។

ក្នុងការអនុវត្តការឆែកឆេរ ចៅក្រមស៊ើបសួរអាចធ្វើការឆែកឆេរបាននៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទេត្រូវធ្វើនៅចំពោះមុខសាក្សី ២ (ពីរ) នាក់ ដែលខ្លួនចាត់តាំង និងអាជ្ញាធរមូលដ្ឋានដូចជាប៉ុស្តិ៍ ចៅសង្កាត់ មេភូមិ។ ត្រូវចាំថាសាក្សីមិនអាចជានគរបាល ឬជាកងរាជអាវុធហត្ថដែលជាកងកម្លាំងចូលរួមប្រតិបត្តិការក្នុងការឆែកឆេរបាននោះឡើយ។

ចៅក្រមស៊ើបសួរមិនអាចផ្តើមឆែកឆេរមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) ល្ងាចបានទេ លើកលែងតែក្នុងករណីឆែកឆេរនៅគ្រប់ទីកន្លែងការផលិត រក្សាទុក ជួញដូរ ចែកចាយ ឬប្រើប្រាស់គ្រឿងញៀន។ ចៅក្រមស៊ើបសួរក៏អាចធ្វើការឆែកឆេរនៅក្នុងការិយាល័យមេធាវីផងដែរ ប៉ុន្តែត្រូវធ្វើនៅចំពោះមុខប្រធានគណៈមេធាវី ឬប្រតិភូរបស់ប្រធានគណៈមេធាវីនោះ។

---

[43] មាត្រា ១៥៦, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[44] មាត្រា ១៥៨, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[45] គម្រូនៃកំណត់ហេតុស្តីការស្តាប់ចម្លើយសាក្សី មានកំណត់ក្នុងឧបសម្ព័ន្ធទី១១

ក្នុងការឆែកឆេរចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុ ស្ដីអំពីការឆែកឆេរដោយមានចុះហត្ថលេខារបស់ខ្លួន និងក្រឡាបញ្ជីជាមួយអ្នកកាន់កាប់ទីកន្លែង ឬសាក្សី ២ (ពីរ) នាក់។ កំណត់ហេតុនេះត្រូវចុះនិទ្ទេសអំពីអត្តសញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែងទាំងអស់ ឬសាក្សីនីមួយៗ។ ការឆែកឆេរប្រព្រឹត្តទៅក្នុងការិយាល័យមេធាវី កំណត់ហេតុនេះត្រូវចុះនិទ្ទេសអំពីវត្តមានរបស់ប្រធានគណៈមេធាវី ឬ របស់ប្រតិភូនៃកម្រិតនៃប្រធានគណៈមេធាវីនេះ។[46]

នៅពេលប្រតិបត្តិការនៃការឆែកឆេរ ចៅក្រមស៊ើបសួរអាចចាប់យកវត្ថុតាងដែលចាប់បាន និងមានបិទស្លាកបោះត្រាលើវត្ថុតាងនោះ។ ក្រោយពីបានបង្ហាញវត្ថុដែលចាប់ដល់អ្នកកាន់កាប់ទីកន្លែង ឬដល់សាក្សីទាំង ២ (ពីរ) នាក់រួចមកចៅក្រមស៊ើបសួរធ្វើកំណត់ហេតុស្ដីពីការចាប់ដែលរួមមានបញ្ជីសារពើភ័ណ្ឌនៃវត្ថុដែលចាប់យក។ កំណត់ហេតុស្ដីពីការចាប់នេះត្រូវមានចុះហត្ថលេខារបស់ចៅក្រមស៊ើបសួរ និងក្រឡាបញ្ជីរួមជាមួយអ្នកកាន់កាប់ទីកន្លែង ឬសាក្សី ២ (ពីរ) នាក់។ កំណត់ហេតុត្រូវមានចុះនិទ្ទេសអំពីអត្តសញ្ញាណនៃអ្នកកាន់កាប់ទីកន្លែង ឬសាក្សីនីមួយៗ។[47]

បន្ទាប់ពីចាប់យកវត្ថុតាងនៅពេលដែលមិនទាន់ចេញដីកាដំណោះស្រាយរឿងនៅឡើយទេ ចៅក្រមស៊ើបសួរមានសមត្ថកិច្ចគ្រប់គ្រងសងទៅម្ចាស់ដើមវិញនូវវត្ថុតែចាប់បាន កាលណាកម្មសិទ្ធិនេះគ្មានការជំទាស់អ្វីប្រាកដប្រជាទេ។ លើសពីនេះចៅក្រមស៊ើបសួរត្រូវធ្វើការសម្រេចតាមដីកាដែលមានសំអាងហេតុក្រោយពីបានទទួលមតិពីព្រះរាជអាជ្ញា។ ដីកាសម្រេចនេះត្រូវឲ្យដំណឹងជាបន្ទាន់ដល់អ្នកប្ដឹង និងមេធាវីរបស់អ្នកប្ដឹងប្រសិនបើមាន។ ប៉ុន្តែវត្ថុតាងដែលចាប់យកមិនគួរប្រគល់សងទៅឲ្យអ្នកប្ដឹងសុំទេ កាលណាវិធានការនេះអាចបង្កជាឧបសគ្គដល់ការសម្រេចឲ្យឃើញការពិត។ ចំពោះវត្ថុដែលមានគ្រោះថ្នាក់ដល់បុគ្គល ឬទ្រព្យសម្បត្តិ ដូចជាអាវុធ ឬជាតិផ្ទុះ ព្រមទាំងវត្ថុដែលការកាន់កាប់មិនស្របច្បាប់មិនអាចប្រគល់សងទៅឲ្យសាមីខ្លួនបានទេ ហើយវត្ថុនេះត្រូវរឹបអូសជាកម្មសិទ្ធិរបស់រដ្ឋ។[48]

**ច. ការធ្វើកោសលវិច័យ**

នៅក្នុងដំណាក់កាលនៃការស៊ើបសួរ ដើម្បីជាផលប្រយោជន៍ដល់ការស្រាវជ្រាវរកការពិតច្បាប់បានអនុញ្ញាតឲ្យចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យអ្នកជំនាញធ្វើកោសលវិច័យដោយធ្វើការវិភាគ និងបញ្ជាក់លទ្ធផលដោយអ្នកជំនាញប្រសិនករណីខ្លះចៅក្រមស៊ើបសួរមិនអាចធ្វើការវាយតម្លៃខ្លួនឯងបានដូចជា ប្រភេទគ្រឿងញៀន សាកសព ប្រភេទឈាម ប្រភេទអាវុធ ឬឧបករណ៍ផ្សេងៗដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស។ ភាព

[46] មាត្រា ១៥៩, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។
[47] មាត្រា ១៦០, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។
[48] មាត្រា ១៦១, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

ចាំបាច់នៃការធ្វើកោសលវិច័យធ្វើឲ្យយើងអាចរកឃើញ ឬអាចឲ្យយើងប្រើប្រាស់សញ្ញាសម្គាល់មួយចំនួន ឬភស្តុតាងផ្សេងៗដោយសារមធ្យោបាយបច្ចេកទេស និងវិទ្យាសាស្ត្រមួយចំនួន។

នៅក្នុងករណីដែលមានបញ្ហាបច្ចេកទេសចោទឡើង ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យធ្វើកោសលវិច័យដោយឯកឯង ឬតាមពាក្យសុំរបស់ព្រះរាជអាជ្ញារបស់ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី។ កាលណាចៅក្រមស៊ើបសួរបដិសេធមិនព្រមធ្វើតាមពាក្យសុំធ្វើកោសលវិច័យ ចៅក្រមស៊ើបសួរត្រូវសម្រេចតាមដីកាដោយមានសំអាងហេតុ។ ដីកាត្រូវសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ប្រសិនបើពាក្យសុំនោះចេញមកពីព្រះរាជអាជ្ញា និង១ (មួយ) ខែ ប្រសិនបើពាក្យនោះចេញមកពីជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី។ ដីកាសម្រេចនេះត្រូវជូនដំណឹងឲ្យដល់អ្នកប្តឹងសុំជាបន្ទាន់។[49] ការធ្វើកោសលវិច័យក្នុងរឿងព្រហ្មទណ្ឌត្រូវបានបង្កើតឲ្យមានបញ្ជីថ្នាក់ជាតិមួយនៃអ្នកជំនាញ បញ្ជីនេះត្រូវបានរៀបចំឡើងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ប៉ុន្តែបែបបទនៃការចុះឈ្មោះ ឬលុបឈ្មោះចេញពីបញ្ជីត្រូវកំណត់ដោយប្រកាសរបស់ក្រសួងយុត្តិធម៌។ អ្នកជំនាញដែលត្រូវបានចុះឈ្មោះនៅក្នុងបញ្ជីថ្នាក់ជាតិត្រូវស្បថនៅមុខសាលាឧទ្ធរណ៍ភ្នំពេញស្របតាមសាសនា ឬជំនឿរបស់ខ្លួនថានឹងផ្តល់ជំនួយដោយស្មោះត្រង់ដល់ការស្វែងរកយុត្តិធម៌។ អ្នកជំនាញត្រូវបានចុះឈ្មោះក្នុងបញ្ជីមិនចាំបាច់ស្បថសាជាថ្មីទៀតទេនៅពេលណាខ្លួនត្រូវបានចាត់តាំងឲ្យធ្វើកោសលវិច័យ។[50]

ចៅក្រមស៊ើបសួរ តាមធម្មតាត្រូវជ្រើសរើសអ្នកជំនាញដែលត្រូវបានចុះឈ្មោះក្នុងបញ្ជីថ្នាក់ជាតិនៃអ្នកជំនាញ។ ចៅក្រមស៊ើបសួរ តាមដីកាដោយមានសំអាងហេតុពិសេសអាចចាត់តាំងអ្នកជំនាញដែលគ្មានឈ្មោះនៅក្នុងបញ្ជីថ្នាក់ជាតិបាន។ ករណីនេះអ្នកជំនាញត្រូវស្បថតាមសាសនា ឬជំនឿរបស់ខ្លួនថា ខ្លួននឹងផ្តល់ជំនួយដោយស្មោះត្រង់ដល់ការស្វែងរកយុត្តិធម៌។[51] អ្នកជំនាញត្រូវបានចាត់តាំងតាមដីការបស់ចៅក្រមស៊ើបសួរ។[52] ដីកាត្រូវបញ្ជាក់អំពីបេសកកម្មរបស់អ្នកជំនាញព្រមទាំងរយៈពេលដែលត្រូវបំពេញបេសកកម្មនេះ បេសកកម្មអាចទាក់ទងទៅនឹងបញ្ហាដែលមានលក្ខណៈបច្ចេកទេសតែប៉ុណ្ណោះ។ ប្រសិនបើជាការគួរ ចៅក្រមស៊ើបសួរប្រគល់វត្ថុដែលចាប់បានមួយផ្នែក ឬទាំងអស់នោះជូនអ្នកជំនាញ។ ចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុស្តីពីការប្រគល់ដែលចាប់បាន។ អ្នកជំនាញអាចបំបែកស្លាកដែលបិទដើម្បីធ្វើកោសលវិច័យបានប្រសិនបើកោសលវិច័យនេះអាចធ្វើឲ្យខូចខាត ឬវិនាសដល់វត្ថុដែលចាប់បាននោះអ្នកជំនាញត្រូវជូនព័ត៌មានដល់ចៅក្រមស៊ើបសួរ

[49] មាត្រា ១៦២, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[50] មាត្រា ១៦៣, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[51] មាត្រា ១៦៤, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[52] គម្រូនៃដីកាចាត់តាំងអ្នកជំនាញ មានកំណត់ក្នុងឧបសម្ព័ន្ធទី១២

និងសុំការអនុញ្ញាតពីចៅក្រមនេះមុននឹងចាប់ផ្តើមប្រតិបត្តិការរបស់ខ្លួន។[53]

អ្នកជំនាញបំពេញបេសកកម្មរបស់ខ្លួនក្រោយការត្រួតពិនិត្យរបស់ចៅក្រមស៊ើបសួរ។ អ្នកជំនាញត្រូវជូនព័ត៌មានដល់ចៅក្រមស៊ើបសួរអំពីការប្រព្រឹត្តនៃបេសកកម្មការលំបាករបស់ខ្លួនដែលអាចជួបប្រទះ។ ប្រសិនបើអ្នកជំនាញមិនគោរពរយៈពេលដែលកំណត់ដោយចៅក្រមស៊ើបសួរទេ ចៅក្រមស៊ើបសួរអាចចាត់អ្នកជំនាញផ្សេងទៀតជំនួសអ្នកជំនាញនោះ។ ប៉ុន្តែប្រសិនបើកាលៈទេសៈតម្រូវនោះចៅក្រមស៊ើបសួរអាចអនុញ្ញាតតាមដីកាសម្រេចឲ្យធ្វើការពន្យាររពេលបាន។[54] ដើម្បីបំពេញបេសកកម្មរបស់ខ្លួនអ្នកជំនាញអាចស្តាប់ចម្លើយបុគ្គលគ្រប់រូបក្រៅពីជនត្រូវចោទ ចម្លើយដែលអ្នកជំនាញបានទទួលនោះមានតម្លៃត្រឹមតែជាព័ត៌មានធម្មតា។ បុគ្គលដែលអ្នកជំនាញស្តាប់ចម្លើយនោះមិនបាច់ស្បថទេ។ ប្រសិនបើខ្លួនយល់ឃើញថាចាំបាច់ត្រូវស្តាប់ចម្លើយជនត្រូវចោទអ្នកជំនាញត្រូវសុំការអនុញ្ញាតពីចៅក្រមស៊ើបសួរ។ ជនត្រូវចោទអាចសុំឲ្យអ្នកជំនាញស្តាប់ចម្លើយរបស់ខ្លួននៅចំពោះមុខមេធាវី។ ប៉ុន្តែកាលណាចៅក្រមស៊ើបសួរចាត់តាំងគ្រូពេទ្យ ឬអ្នកចិត្តសាស្ត្រពិនិត្យជនត្រូវចោទនោះ ការពិនិត្យវេជ្ជសាស្ត្រ ឬចិត្តសាស្ត្រត្រូវធ្វើដោយគ្មានវត្តមានមេធាវី។[55]

កាលណារបាយការណ៍នៃការធ្វើកោសលវិច័យត្រូវបានបញ្ចប់ហើយ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញាដើម្បីដាក់ចូលក្នុងសំណុំរឿងស៊ើបសួរ បន្ទាប់មកចៅក្រមស៊ើបសួរកោះហៅជនត្រូវចោទ និងមេធាវីដើម្បីប្រាប់ឲ្យដឹងពីសេចក្តីសន្និដ្ឋាននៃកោសលវិច័យនេះ។ ចៅក្រមស៊ើបសួរអាចកោះហៅដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីផងដែរដើម្បីប្រាប់ឲ្យដឹងពីសេចក្តីសន្និដ្ឋាននៃកោសលវិច័យ។

ចៅក្រមស៊ើបសួរត្រូវតែកំណត់រយៈពេលដែលអនុញ្ញាតឲ្យព្រះរាជអាជ្ញា ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីដាក់ពាក្យសុំធ្វើកោសលវិច័យបន្ថែម ឬប្រតិកោសលវិច័យ ដែលរយៈពេលនេះមិនអាចតិចជាង ១០ (ដប់) ថ្ងៃនោះទេ។ ក្នុងរយៈពេលនេះសំណុំរឿងដែលរួមមានរបាយការណ៍កោសលវិច័យអាចត្រូវបានពិនិត្យមើលដោយមេធាវី។ គ្រប់ពាក្យសំដីកោសលវិច័យបន្ថែម ឬប្រតិកោសល្យវិច័យត្រូវតែមានសំអាងហេតុ និងធ្វើឡើងជាលាយលក្ខណ៍អក្សរ។

កាលណាចៅក្រមស៊ើបសួរមិនព្រមធ្វើតាមពាក្យសុំធ្វើកោសលវិច័យបន្ថែម ឬប្រតិកោសលវិច័យទេ ចៅក្រមស៊ើបសួរត្រូវសម្រេចតាមដីកាដោយមានសំអាងហេតុ។ ដីកាត្រូវសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ប្រសិនបើពាក្យសុំចេញមកពីព្រះរាជអាជ្ញា និង ១ (មួយ) ខែ ប្រសិនបើពាក្យនេះចេញពីជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី។ ដីកាត្រូវឲ្យដំណឹងជាបន្ទាន់ដល់អ្នកប្តឹងសុំ។ គ្រប់ពាក្យសុំធ្វើកោសលវិច័យបន្ថែម ឬប្រតិ

[53] មាត្រា ១៦៥, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[54] មាត្រា ១៦៦, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[55] មាត្រា ១៦៧, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

កោសលវិច័យ ដែលធ្វើឡើងក្រោយផុតរយៈពេល ដែលកំណត់ដោយចៅក្រមស៊ើបសួរត្រូវដាក់បញ្ចូលក្នុងសំណុំរឿង។ បើចៅក្រមស៊ើបសួរបានទទួលពាក្យសុំធ្វើកោសលវិច័យ ធ្វើកោសលវិច័យបន្ថែម ឬប្រតិកោសលវិច័យ មិនព្រមសម្រេចក្នុងរយៈពេលនេះ អ្នកដែលសុំអាចធ្វើពាក្យប្តឹងដោយផ្ទាល់តាមរយៈពាក្យសុំដល់សភាស៊ើបសួរ ដែលសម្រេចជំនួសដោយចៅក្រមស៊ើបសួរ។[56]

ចំណែកឯសោហ៊ុយសម្រាប់ធ្វើកោសលវិច័យជាបន្ទុករបស់អ្នកស្នើសុំ។ កាលណាចៅក្រមស៊ើបសួរ ព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ស្នើសុំឲ្យធ្វើកោសលវិច័យ កោសលវិច័យបន្ថែម ឬធ្វើប្រតិកោសលវិច័យ សោហ៊ុយទាំងនេះជាបន្ទុករបស់រដ្ឋ។[57]

**ឆ. ការស្តាប់ទូរស័ព្ទ**

ការស្តាប់ទូរស័ព្ទជាអាទិ៍ដែលបង្គាប់ដោយចៅក្រមស៊ើបសួរ ត្រូវធ្វើឡើងដើម្បីតម្រូវការចាំបាច់ក្នុងការសម្តែងឲ្យឃើញនូវការពិត ឬជាប្រយោជន៍ចំពោះបទល្មើសទាំងឡាយណាដែលមានពាក់ព័ន្ធនឹងបណ្តាញទូរស័ព្ទ ដែលចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យស្តាប់ និងថតការសន្ទនាតាមទូរស័ព្ទបាន។ លើសពីនេះចៅក្រមស៊ើបសួរក៏អាចបង្គាប់ឲ្យចាប់ និងថតគ្រប់ការឆ្លើយឆ្លងគ្នាតាមមធ្យោបាយទូរគមនាគមន៍ផងដែរដូចជា សារតាមរយៈទូរសារ ឬសារតាមអិនធើណែតជាអាទិ៍។ *ឧទាហរណ៍៖* ករណីការស៊ើបអង្កេតពីបទល្មើសគម្រាមថានឹងសម្លាប់ ដែលជនរងគ្រោះអះអាងថាជនត្រូវចោទបានទូរស័ព្ទមកគម្រាមខ្លួនជាច្រើនដង។ ករណីនេះចៅក្រមស៊ើបសួរមានសិទ្ធិបង្គាប់ឲ្យមន្ត្រីមានជំនាញធ្វើការថតយកការសន្ទនាតាមទូរស័ព្ទសម្រាប់ទុកជាភស្តុតាង។

ចៅក្រមស៊ើបសួរ អាចសុំឲ្យគ្រប់អង្គភាពសាធារណៈគ្រប់ជាន់ថ្នាក់ទាំងអស់ ឬគ្រប់មន្ត្រីរាជការជំនាញតាំងឧបករណ៍បច្ចេកទេស និងធ្វើការថតដោយតម្រូវឲ្យចៅក្រមស៊ើបសួរបញ្ជាក់នៅក្នុងដីកាសម្រេចរបស់ខ្លួន អំពីប្រភេទនៃទំនាក់ទំនងដែលត្រូវចាប់ព្រមទាំងអំពីរយៈពេលនៃបេសកកម្មរបស់ខ្លួន។

គ្រប់អង្គភាពសាធារណៈមន្ត្រីរាជការ ដែលចាត់តាំងត្រូវបំពេញតាមពាក្យសុំរបស់ចៅក្រមស៊ើបសួរនៅក្នុងពេលអនុវត្តបេសកកម្មអង្គភាពសាធារៈ ឬគ្រប់មន្ត្រីរាជការដែលចាត់តាំងត្រូវតែជូនព័ត៌មានដល់ចៅក្រមស៊ើបសួរអំពីការប្រព្រឹត្តទៅនៃបេសកកម្មអំពីការលំបាកជាយថាហេតុ។ កាលណាបេសកកម្មត្រូវបានបំពេញរួចហើយអង្គភាពសាធារណៈ ឬគ្រប់មន្ត្រីរាជការត្រូវចម្លងជាលាយលក្ខណ៍អក្សរនូវសម្លេងដែលថតបាន។ ការធ្វើឲ្យទៅជាលាយលក្ខណ៍អក្សរនេះត្រូវឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនូវខ្លឹមសារនៃសម្លេងដែលថតបាន។ សម្លេងដែលថតបាននេះត្រូវប្រគល់ជូនចៅក្រមស៊ើបសួរ និងបិទស្លាក។

---

[56] មាត្រា ១៧០, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[57] មាត្រា ១៧១, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

គ្រប់ពេលវេលាចៅក្រមស៊ើបសួរអាចចុះទៅកាន់ទីកន្លែងដែលធ្វើការចាប់ និងថតចូលទៅកាន់ទីកន្លែងទាំងនោះមិនអាចត្រូវហាមឃាត់ដល់ចៅក្រមស៊ើបសួរដោយសំអាងលើមូលហេតុអ្វីបានទេ ទោះបីជាកន្លែងឃោធាក៏ដោយ។ ម្យ៉ាងទៀតចៅក្រមស៊ើបសួរអាចធ្វើកិច្ចការនេះតាមដីកាចាត់ឲ្យស៊ើបសួរជំនួសបានផងដែរ។[58]

**កថាខណ្ឌទី២៖ ការចាត់ឲ្យស៊ើបសួរជំនួស**

**ក. មូលហេតុនៃការចាត់ឲ្យបំពេញកិច្ចស៊ើបសួរជំនួស**

ជាការពិតណាស់ ចៅក្រមស៊ើបសួរមានតួនាទីយ៉ាងសំខាន់ក្នុងដំណើរនេះក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌតាមរយៈការស៊ើបសួររបស់គាត់ពីព្រោះថាដំណើរការនៃការស៊ើបសួរនេះ គឺជាចំណាត់ការមួយដែលបង្ហាញថាជនណាបានប្រព្រឹត្តបទល្មើស ឬមិនបានប្រព្រឹត្តបទល្មើស។ អាស្រ័យហេតុនេះភារៈកិច្ចរបស់ចៅក្រមស៊ើបសួរដែលសំខាន់បែបនេះ តុលាការមិនអាចអនុវត្តនីតិវិធីផ្សេងដោយរំលងពីដំណាក់កាលស៊ើបសួរនេះបានឡើយ ទោះបីជាកាលៈទេសៈណាក៏ដោយឲ្យតែស្ថិតនៅក្នុងប្រភេទនៃបទល្មើសឧក្រិដ្ឋ។ ប៉ុន្តែយ៉ាងណាក្តីប្រសិនបើមានមូលហេតុមួយចំនួនដែលជាហេតុបណ្តាលឲ្យចៅក្រមស៊ើបសួរមិនអាចបំពេញតួនាទីរបស់ខ្លួនបាន ដូចជាបញ្ហាជម្ងឺ ឬមានធុរៈចាំបាច់ផ្សេងៗ ការដំណើរការផ្លូវឆ្ងាយ។ល។ ដូច្នេះដោយសារតែកិច្ចការនោះត្រូវធ្វើជាបន្ទាន់ហើយចៅក្រមស៊ើបសួរមិនអាចបំពេញកិច្ចនោះ ទើបក្រមនីតិវិធីព្រហ្មទណ្ឌសម្រេចអនុញ្ញាតឲ្យមានលក្ខខណ្ឌអាចឲ្យចៅក្រមស៊ើបសួរចាត់អ្នកបំពេញកិច្ចស៊ើបសួរជំនួសបាន។

**ខ. ការស៊ើបសួរជំនួសដោយចៅក្រមផ្សេងទៀត**

នៅពេលដែលចៅក្រមស៊ើបសួរណាម្នាក់ដីកាចាត់ឲ្យស៊ើបសួរជំនួសដល់ចៅក្រមផ្សេងទៀត ចៅក្រមនោះត្រូវទទួលកិច្ចដែលត្រូវធ្វើតាមដីកាឲ្យស៊ើបសួរពីចៅក្រមដើមនោះ។ ជាក់ស្តែងនៅក្នុងដីកាចាត់ឲ្យស៊ើបសួរជំនួសត្រូវបញ្ជាក់ពីកិច្ចតែត្រូវធ្វើដែលមានលក្ខណៈច្បាស់លាស់។ យោងតាមស្មារតីនៃក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តិថាកិច្ចដែលចៅក្រមស៊ើបសួរផ្សេងធ្វើត្រូវបញ្ជាក់ក្នុងដីកាចាត់ឲ្យស៊ើបសួរជំនួស ដែលការបញ្ជាក់នោះត្រូវតែមានទំនាក់ទំនងដោយផ្ទាល់ជាមួយបទល្មើសដែលចោទប្រកាន់។ ជាមួយនេះដែរ ដីកានោះត្រូវតែណែនាំឲ្យច្បាស់លាស់ដោយមិនអាចមានលក្ខណៈទូទៅទេទាក់ទងនឹងកិច្ចដែលបង្គាប់ឲ្យស៊ើបសួរ។[59]

ចៅក្រមស៊ើបសួរបានចេញដីកាចាត់ឲ្យស៊ើបសួរជំនួសទៅកាន់ចៅក្រមស៊ើបសួរផ្សេង នៃតុលាការផ្សេងទៀត ហើយគាត់បានកំណត់នៅក្នុងដីកានោះអំពីការចាត់ឲ្យមានការសួរចម្លើយជនត្រូវចោទ ឬការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីផងដែរ។ កាន់តែពិសេសជាងនេះទៅទៀត ដីកាចាត់ឲ្យស៊ើបសួរជំនួសក៏ត្រូវតែកំណត់ថិរវេលាសម្រាប់ធ្វើការចាត់ឲ្យស៊ើបសួរផងដែរ។ ពោលគឺមានចុះរយៈពេលដើម្បីឲ្យចៅក្រមស៊ើបសួរអនុវត្តនូវកិច្ច

[58] មាត្រា ១៧២, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[59] មាត្រា ១៧៤, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

របស់ខ្លួន។ ជាក់ស្តែង ដីកានេះត្រូវតែមានចុះកាលបរិច្ឆេទ ហត្ថលេខា និងបោះត្រាដោយចៅក្រមស៊ើបសួរ (ចៅក្រមដើម) ដើម្បីឲ្យដីកានោះមានអនុភាពត្រឹមត្រូវ។ ដូច្នេះប្រសិនបើក្នុងករណីដែលលើសរយៈពេលដែលបានកំណត់ក្នុងដីកាចាត់ឲ្យស៊ើបសួរជំនួស ចៅក្រមដែលទទួលភារកិច្ចតាមដីកាត្រូវស្នើសុំពន្យាររពេល ឬអាចបញ្ចប់តាមកាលកំណត់ក្នុងដីកានោះតែម្តង។ ម្យ៉ាងទៀតចៅក្រមស៊ើបសួរអាចដកហូតដីកាចាត់ឲ្យស៊ើបសួរជំនួសបានគ្រប់ពេល ប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថាកិច្ចនោះគ្រប់គ្រាន់ហើយ ឬក៏បានប្រមូលតាមតម្រុយគ្រប់គ្រាន់ហើយ។ គួរបញ្ជាក់ផងដែរថា កាលណាដីកាចាត់ឲ្យស៊ើបសួរជំនួសត្រូវបានចេញដល់ចៅក្រមស៊ើបសួរណាម្នាក់ ចៅក្រមស៊ើបសួរនោះប្រើប្រាស់អំណាចទាំងអស់របស់ចៅក្រមដែលបានផ្ទេរឲ្យខ្លួន។ ចំពោះសិទ្ធិអំណាចដែលបានតាមរយៈដីកាចាត់ឲ្យស៊ើបសួរជំនួសទៅលើចៅក្រមស៊ើបសួរម្នាក់ទៀតនេះមានលក្ខណៈទូលាយជាងការចាត់ឲ្យស៊ើបសួរជំនួសដោយមន្ត្រីនគរបាលយុត្តិធម៌ទៅទៀត ទាក់ទងនឹងវិធានការស្រាវជ្រាវ ឬអំណាចរបស់ស៊ើបរបស់ចៅក្រមស៊ើបសួរជាអាទិ៍។

### គ. ការស៊ើបសួរជំនួសដោយមន្ត្រីនគរបាលយុត្តិធម៌

ចៅក្រមស៊ើបសួរ អាចប្រើប្រាស់វិធានការបង្គាប់ឲ្យស៊ើបសួរជំនួសនូវកិច្ចមួយចំនួនដល់មន្ត្រីនគរបាលយុត្តិធម៌ដែលបានចង្អុលបង្ហាញក្នុងដីកាបង្គាប់ឲ្យស៊ើបសួរជំនួស[60] ដោយការអនុវត្តដីកាស៊ើបសួរជំនួសមន្ត្រីនគរបាលយុត្តិធម៌ត្រូវស្ថិតក្នុងអំណាចរបស់ចៅក្រមស៊ើបសួរ ហើយត្រូវរាយការណ៍ជូនចៅក្រមរូបនោះតែម្នាក់គត់។[61] មន្ត្រីនគរបាលយុត្តិធម៌អាចបំពេញកិច្ចបានតែក្នុងករណីដែលមានចែងក្នុងដីកាឲ្យស៊ើបសួរជំនួសនៅក្នុងរង្វង់សមត្ថកិច្ចដែនដីរបស់ខ្លួន លើកលែងតែចៅក្រមស៊ើបសួរអនុញ្ញាតឲ្យធ្វើប្រតិបត្តិការបន្ទាន់លើវិសាលភាពដែនដីជាតិទាំងមូល ប៉ុន្តែត្រូវមានជំនួយពីមន្ត្រីនគរបាលយុត្តិធម៌ដែលមានសមត្ថកិច្ចដែនដី។[62] ចៅក្រមស៊ើបសួរត្រូវចាត់ឲ្យមន្ត្រីនគរបាលយុត្តិធម៌ណាម្នាក់ដើម្បីបំពេញកិច្ចមួយចំនួនជំនួសខ្លួនដូចជា សិទ្ធិអំណាចក្នុងការធ្វើកំណត់ហេតុស្តីពីការស្រាវជ្រាវ និងពិនិត្យអំណាចក្នុងការឆែកឆេរ ការចាប់យកវត្ថុតាង ការឃាត់ខ្លួននៅក្នុងក្របខ័ណ្ឌនៃដីកាចាត់ឲ្យស៊ើបសួរជំនួស ការស្តាប់ទូរស័ព្ទ និងការធ្វើកំណត់ហេតុផ្សេងៗដែលសាងដោយមន្ត្រីនគរបាលយុត្តិធម៌ក្នុងក្របខ័ណ្ឌនៃការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួសចេញពីចៅក្រមស៊ើបសួរ។

លើសពីនេះមន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្តាប់ចម្លើយសាក្សីប៉ុន្តែមុននឹងឆ្លើយចំពោះសំណួរ សាក្សីម្នាក់ៗត្រូវស្បថតាមជំនឿសាសនារបស់ខ្លួនថានិយាយតែការពិត។ ដើម្បីគោរពសិទ្ធិការពារខ្លួនមន្ត្រីនគរបាលយុត្តិធម៌មិនអាចស្តាប់ចម្លើយក្នុងឋានៈជាសាក្សីនូវបុគ្គលណាមួយ ដែលមានតម្រុយនៃពិរុទ្ធភាពលើបុគ្គលនោះ

---

[60] គម្រូនៃដីកាបង្គាប់ឲ្យស៊ើបសួរជំនួស មានកំណត់ក្នុងឧបសម្ព័ន្ធទី១៣

[61] មាត្រា ១៧៦, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[62] មាត្រា ១៧៧, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

ទេ។ កាលណាស្ដាប់ចម្លើយសាក្សីណាម្នាក់បានធ្វើឲ្យលេចតម្រុយនៃពិរុទ្ធភាពសាក្សីនោះមន្ត្រីនគរបាលត្រូវបញ្ឈប់ការស្ដាប់ ហើយត្រូវរាយការណ៍ជូនទៅចៅក្រមស៊ើបសួរ។ មន្ត្រីនគរបាលយុត្តិធម៌អាចហៅរកអ្នកបកប្រែដែលបានស្បថតាមជំនឿសាសនារបស់ខ្លួនថាខ្លួននឹងជួយបកប្រែជូនតុលាការឲ្យបានត្រឹមត្រូវក្នុងករណីសាក្សីមិនចេះភាសាខ្មែរ។

បុគ្គលដែលបានកោះហៅក្នុងឋានៈជាសាក្សីត្រូវចូលមកបង្ហាញខ្លួន។ ក្នុងករណីរឹងទទឹងមន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ជូនចៅក្រមស៊ើបសួរដើម្បីចេញបញ្ជាឲ្យចូលខ្លួន ដោយក្នុងបញ្ជានោះត្រូវមានចុះអត្តសញ្ញាណសាក្សី។ បញ្ជានេះមានត្រូវមានចុះកាលបរិច្ឆេទ និងហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង។ បញ្ជាឲ្យចូលបង្ហាញខ្លួនអនុញ្ញាតឲ្យមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់កម្លាំងជាសាធារណៈដើម្បីបង្ខំឲ្យសាក្សីចូលបង្ហាញខ្លួនចំពោះមុខខ្លួន។[63]

ការសាកសួរចម្លើយរបស់ជនត្រូវចោទ ឬដើមបណ្ដឹងរដ្ឋប្បវេណី មន្ត្រីនគរបាលយុត្តិធម៌មិនអាចធ្វើកិច្ចការនេះបានឡើយ។

សម្គាល់៖ ក្នុងក្របខ័ណ្ឌនេះមន្ត្រីនគរបាលយុត្តិធម៌ពុំអាចសួរចម្លើយជនត្រូវចោទ ឬស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីទេ។ ប៉ុន្តែមន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរ និងចាប់យកវត្ថុតាង នៅក្នុងលក្ខខណ្ឌដែលមានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។ ដើម្បីឆ្លើយតបនឹងតម្រូវការចាំបាច់មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការហាមឃាត់ជនត្រូវចោទតែត្រូវមានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។

[63] មាត្រា ១៧៩, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

# ជំពូកទី២

# វិធានការនិរន្តរាយ

# ជំពូកទី២
# វិធានការនិរន្តរាយ

និរន្តរាយ មានន័យថាការមិនមានអន្តរាយដំណើរដែលគ្មានគ្រោះថ្នាក់។[64] វិធានការនេះសម្តៅដល់ការចេញដីកាចាប់ខ្លួន ការចោទប្រកាន់ ការឃុំខ្លួន ឬការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការដោយចៅក្រមស៊ើបសួរ។

ដើម្បីធានាដល់កិច្ចស៊ើបសួរឲ្យប្រព្រឹត្តទៅដោយមានប្រសិទ្ធិភាព ក្រមនីតិវិធីព្រហ្មទណ្ឌបានប្រគល់អំណាចក្នុងការចាប់បង្ខំតាមរយៈវិធានការនិរន្តរាយទៅឲ្យចៅក្រមស៊ើបសួរ។ យ៉ាងណាវិញដោយផ្អែកលើមូលដ្ឋានគ្រឹះនៃការចាត់ការនិរន្តរាយទៅដល់ចៅក្រមស៊ើបសួរ មានអំណាចប្រើប្រាស់នូវដីកាជាច្រើនដើម្បីស្វែងឡើងពីសកម្មភាពរបស់ខ្លួន។ នេះជាគោលការណ៍នៅក្នុងក្រមព្រហ្មទណ្ឌដើម្បីជាការងាយស្រួលស្វែងរកភស្តុតាងពិតប្រាកដសម្រាប់ដាក់បន្ទុក ដោះបន្ទុក ទៅដល់ចៅក្រមស៊ើបសួរក្នុងរឿងក្តីព្រហ្មទណ្ឌ។

## ផ្នែកទី១៖ ដីកា

ដីកា ជាបញ្ជាជាលាយល័ក្ខអក្សរចេញពីអាជ្ញាធរមានសមត្ថកិច្ចដែលបង្គាប់ឲ្យចាត់ការនូវអំពើណាមួយមួយវិញទៀត បញ្ជាដែលបង្គាប់ឲ្យចាប់ខ្លួនជនណាម្នាក់ ឬច្រើននាក់ជាការចេញដីកាដោយអង្គការតុលាការ ឬមន្ត្រីរាជការណាមួយ។ ជាទូទៅគេអាចទាយយកតាមអត្ថន័យច្បាប់បានន័យថា ដីកាជាសេចក្តីសម្រេចរបស់ចៅក្រមដើម្បីអនុញ្ញាតធ្វើការបង្គាប់ឲ្យធ្វើកិច្ចការអ្វីមួយ ឬជាសេចក្តីបង្គាប់ជាលាយល័ក្ខអក្សរដែលចេញដោយចៅក្រមម្នាក់។

ចំពោះវិធានការនិរន្តរាយនេះចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឲ្យចូលខ្លួន ដីកាបង្គាប់ឲ្យនាំខ្លួនដីកាបង្គាប់ឲ្យចាប់ខ្លួន និងដីកាបង្គាប់ឲ្យឃុំខ្លួន។[65]

### កថាខណ្ឌទី១៖ ដីកាបង្គាប់ឲ្យចូលខ្លួន

#### ក. អត្ថន័យនៃដីកាបង្គាប់ឲ្យចូលខ្លួន

ដីកាបង្គាប់ឲ្យចូលខ្លួន គឺជាបញ្ជាដល់បុគ្គលណាម្នាក់ឲ្យចូលទៅបង្ហាញខ្លួននៅមុខចៅក្រមស៊ើបសួរ។ ដីកានេះអាចចេញទៅលើជនត្រូវចោទ ឬទៅលើបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាពប៉ុណ្ណោះ។[66] ដីកានេះត្រូវឲ្យដំណឹងដល់ជនពាក់ព័ន្ធដោយមន្ត្រីនគរបាលយុត្តិធម៌ ឬអាជ្ញាសាលា។[67]

---

[64] សម្តេច ជួន ណាត, វចនានុក្រមខ្មែរ, (ភ្នំពេញ៖ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ១៩៦៧)។

[65] មាត្រា ១៨៥, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[66] មាត្រា ១៨៦, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[67] មាត្រា ១៨៨, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

## ខ. លក្ខខណ្ឌនៃការចេញដីកាបង្គាប់ឲ្យចូលខ្លួន

កម្មវត្ថុនៃការចេញដីកាបង្គាប់ឲ្យនាំខ្លួន គឺដើម្បីបញ្ជាក់ឲ្យបុគ្គលដែលត្រូវចោទចូលមកបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ ដើម្បីឲ្យចៅក្រមស៊ើបសួរធ្វើការសាកសួរព័ត៌មានសួររកចម្លើយ ឬស្តាប់ចម្លើយអំពីរឿងហេតុពាក់ព័ន្ធនឹងបទចោទប្រកាន់របស់ព្រះរាជអាជ្ញា។

នៅក្នុងចំណាត់ការវិធានការនិរន្តរាយ ដើម្បីឲ្យការស៊ើបសួរស្វែងរកការពិតនៃរឿងមួយដែលប្រព្រឹត្តទៅបានដោយរលូនរបស់ចៅក្រមស៊ើបសួរត្រូវតែមានការសហការពីព្រះរាជអាជ្ញា ប៉ុន្តែការចេញដីកាបង្គាប់ឲ្យចូលខ្លួនមិនអាចអនុវត្តបានដោយភ្លាមៗឡើយទោះបីជាមានការសន្និដ្ឋានពីព្រះរាជអាជ្ញាក៏ដោយ។ មូលហេតុមកពីនៅក្នុងសេចក្តីសន្និដ្ឋានបង្គាប់ឲ្យនាំចូលខ្លួន បានធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ទៅលើបុគ្គលដែលមិនទាន់ស្គាល់អត្តសញ្ញាណច្បាស់លាស់ ហេតុដូច្នេះការចេញដីកាបង្គាប់ឲ្យចូលខ្លួនគ្មានប្រសិទ្ធិភាព។ ដោយឡែកចំណាត់ការដើម្បីឆ្លើយតបទៅនឹងករណីនេះ ជាដំបូងចៅក្រមស៊ើបសួរធ្វើការស៊ើបសួរស្រាវជ្រាវរកសវតាជាតិរបស់បុគ្គលនោះជាមុនសិនតាមរយៈដីកាស៊ើបសួរជំនួស ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឲ្យចូលខ្លួន។

ចំពោះដីកាបង្គាប់ឲ្យចូលខ្លួន ត្រូវចុះនិទ្ទេសដូចជា ៖

- អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ
- បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសនេះ
- ថ្ងៃ ខែ ឆ្នាំ ម៉ោង និងទីកន្លែងដែលត្រូវបង្ហាញខ្លួននៅមុខចៅក្រមស៊ើបសួរ
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា។

ដីកាបង្គាប់ឲ្យចូលខ្លួនត្រូវចុះកាលបរិច្ឆេទ ហើយចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង។[68] មួយវិញទៀត ដីកាឲ្យចូលខ្លួនមិនមានវិធានការចាប់បង្ខំដល់ជនដែលចៅក្រមបានកំណត់ឈ្មោះនៅក្នុងដីកានោះទេ មានន័យថាជនដែលត្រូវទទួលបានដំណឹងនៃដីកានេះរួចហើយបុគ្គលនេះអាចចូលខ្លួន ឬមិនចូលបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរដោយសេរី។ ប៉ុន្តែទោះបីបែបណាក៏ដោយ ដីកាបង្គាប់ឲ្យចូលខ្លួនមិនមានអនុភាពដោយផ្ទាល់ ក្នុងការចាប់បង្ខំបុគ្គលនោះត្រូវតែចូលបង្ហាញខ្លួនចំពោះមុខចៅក្រមស៊ើបសួរក៏ពិតមែនតែវាមានតម្លៃជាការជម្រុញទៅលើយន្តការនៃនីតិវិធីបន្ត ក្នុងករណីដែលបុគ្គលនោះបដិសេធមិនព្រមចូលខ្លួនតាមដីកាបង្គាប់ឲ្យចូលខ្លួនដោយគ្មានមូលហេតុត្រឹមត្រូវ។ ចំណាត់ការបន្តចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឲ្យនាំខ្លួន។

[68] មាត្រា ១៨៧, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

### គ. ការអនុវត្តដីកាបង្គាប់ឲ្យចូលខ្លួន

ការអនុវត្តដីកាបង្គាប់ឲ្យចូលខ្លួននេះ ត្រូវបានចេញដោយចៅក្រមស៊ើបសួរជូនទៅកាន់មន្ត្រីនគរបាលយុត្តធម៌ ឬមន្ត្រីអាជ្ញាសាលា ដោយក្រឡាបញ្ជីឲ្យដីកាបង្គាប់ឲ្យចូលខ្លួនទៅដល់បុគ្គលដែលពាក់ព័ន្ធ គឺត្រូវបញ្ជាក់ប្រាប់ទៅបុគ្គលនោះអំពីកម្មវត្ថុនៃដីកានេះឲ្យទទួលយកចុងដីកា ហើយត្រូវចុះហត្ថលេខា ឬផ្តិតម្រាមដៃនៅលើដើមដីកានោះផង។ ប្រសិនបើបុគ្គលនោះមិនព្រមយកដីកានេះត្រូវបញ្ជាក់ពីមូលហេតុនៃការមិនព្រមយកដីកានោះ។[69] បន្ទាប់មកទៀតមន្ត្រីមានសមត្ថកិច្ចត្រូវបញ្ជូនដីកានោះត្រលប់មកជូនចៅក្រមស៊ើបសួរឲ្យបានរហ័សតាមដែលខ្លួនអាចធ្វើទៅបាន។

## កថាខណ្ឌទី២៖ ដីកាបង្គាប់ឲ្យនាំខ្លួន

### ក. អត្ថន័យនៃដីកាបង្គាប់ឲ្យនាំខ្លួន

ដីកាបង្គាប់ឲ្យនាំខ្លួន គឺជាបញ្ជាដល់កម្លាំងសាធារណៈឲ្យចាប់ និងនាំខ្លួនបុគ្គលណាម្នាក់ទៅចំពោះមុខចៅក្រមស៊ើបសួរ។ ដីកានេះអាចត្រូវចេញតែទៅលើជនត្រូវចោទ ឬទៅបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាពប៉ុណ្ណោះ។[70] ក្រៅពីលក្ខខណ្ឌនេះ ក្រមនីតិវិធីព្រហ្មទណ្ឌពុំបានកំណត់នូវលក្ខខណ្ឌណាផ្សេងទៀតដើម្បីឲ្យចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់នាំខ្លួននោះទេ។ ហេតុនេះចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យនាំខ្លួនភ្លាមដោយមិនចាំបាច់ចេញដីកាឲ្យនាំខ្លួនជាមុនទេក្នុងករណីដែលចៅក្រមយល់ឃើញថាជាការចាំបាច់។

### ខ. លក្ខខណ្ឌនៃការចេញដីកាបង្គាប់ឲ្យនាំខ្លួន

ប្រសិនបើជនត្រូវចោទមិនបានចូលខ្លួនតាមដីកាបង្គាប់ឲ្យចូលខ្លួនទេ នោះចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឲ្យនាំខ្លួនជនត្រូវចោទបានករណីដែលជនត្រូវចោទមិនបានរត់គេចទៅទីណានោះ។ ចំណុចនេះមានន័យថាប្រសិនបើជនត្រូវចោទកំពុងរស់នៅជាធម្មតានៅមូលដ្ឋានដោយគ្មានការរត់គេចខ្លួន គឺចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឲ្យនាំខ្លួនជនត្រូវចោទតែម្តង។

ប្រសិនបើករណី ចៅក្រមស៊ើបសួរយល់ឃើញថាការចេញដីកាបង្គាប់ឲ្យចូលខ្លួនទៅជនត្រូវចោទពីបទឧក្រិដ្ឋ ឬបទមជ្ឈិមធ្វើឲ្យជនត្រូវចោទមានបំណងរត់គេចខ្លួន នោះចៅក្រមស៊ើបសួរមានសិទ្ធិចេញដីកាបង្គាប់ឲ្យនាំខ្លួនតែម្តង។

ម្យ៉ាងទៀតក្នុងករណីចៅក្រមបានចេញដីកាបង្គាប់ឲ្យចូលខ្លួន ប៉ុន្តែជនត្រូវចោទនៅតែរឹងទទឹងមិនព្រមចូលបង្ហាញខ្លួនចំពោះមុខតុលាការ នោះចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឲ្យនាំខ្លួនដែលមានអនុភាពដើម្បីធ្វើការនាំខ្លួនជននោះមកស៊ើបសួរដើម្បីស្វែងរកការពិត។

[69] គម្រូនៃដីកាបង្គាប់ឲ្យចូលខ្លួន មានកំណត់ក្នុងឧបសម្ព័ន្ធទី១៤

[70] មាត្រា ១៩០, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

ដើម្បីឲ្យដីកាបង្គាប់ឲ្យនាំខ្លួនមានអនុភាពត្រូវចុះនិទ្ទេសដូចតទៅ៖

- លេខ ថ្ងៃ ខែ ឆ្នាំ សំណុំរឿង
- អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ
- បទល្មើសដែលបានចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា
- ដីកានេះត្រូវចុះលេខរៀងនៃការចេញដីកា ស្របតាមលេខរៀងនៃសៀវភៅចុះលេខដីកាបង្គាប់ឲ្យនាំខ្លួន

ដីកាបង្គាប់ឲ្យនាំខ្លួនត្រូវតែចុះកាលបរិច្ឆេទ និងនិទ្ទេសដូចដែលបានចង្អុលបង្ហាញខាងលើទើបដីកានេះមានប្រសិទ្ធិភាព។

ដីកាបង្គាប់ឲ្យនាំខ្លួនត្រូវចុះកាលបរិច្ឆេទ ចុះហត្ថលេខា និងមានបោះត្រារបស់ចៅក្រមស៊ើបសួរផង។[71]

### គ. ការអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួន

ដីកាបង្គាប់ឲ្យនាំខ្លួន ត្រូវប្រគល់ដល់មន្ត្រីនគរបាលយុត្តិធម៌ដែលជាអ្នកទទួលបន្ទុកក្នុងការអនុវត្ត ប្រសិនបើចាំបាច់ដីកាបង្គាប់ឲ្យនាំខ្លួនត្រូវផ្សព្វផ្សាយដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថតាមរយៈគ្រប់មធ្យោបាយដូចជាព័ត៌មានកាសែត វិទ្យុ ទូរទស្សន៍ ឬប្រព័ន្ធអ៊ីនធើណែតជាអាទិ៍។[72] មានន័យថាដីកាបង្គាប់ឲ្យនាំខ្លួនអាចជាកម្មវត្ថុក្នុងការធ្វើការផ្សព្វផ្សាយលើវិភាពដែនដីនៃព្រះរាជាណាចក្រកម្ពុជាទាំងមូល ការផ្សព្វផ្សាយបែបនេះចំពោះភាពបន្ទាន់នៃការអនុវត្តដីកា ដើម្បីបង្កាជនត្រូវចោទកុំឲ្យព្យាយាមរត់គេចខ្លួនចេញពីព្រំដែនដីប្រទេសកម្ពុជា។ ដីកានេះត្រូវប្រគល់ជូនជាបន្ទាន់ដល់មន្ត្រីនគរបាលយុត្តិធម៌ដែលទទួលបន្ទុកតាមរយៈក្រឡាបញ្ជី។ ចំពោះដីកាត្រូវមានបោះត្រាក្រហមដែលមិនមែនជាសន្លឹកថតចម្លងមិនថាស្ថិតក្នុងកាលៈទេសៈបែបណាទេមន្ត្រីនគរបាលយុត្តិធម៌ត្រូវតែគោរពសិទ្ធិលំនៅដ្ឋាន បើទោះជាស្ថិតក្នុងលក្ខខណ្ឌបន្ទាន់ក្នុងការអនុវត្តដីកាយ៉ាងណាក៏ដោយ មានន័យថាមន្ត្រីនគរបាលយុត្តិធម៌មិនអាចចូលទៅនាំខ្លួនជនត្រូវចោទមុនម៉ោង ៦ព្រឹក និងក្រោយម៉ោង ១៨ ល្ងាចបានជាដាច់ខាត។ ម្យ៉ាងវិញទៀតប្រសិនបើស្ថិតនៅក្នុងបេសកកម្មនៃការអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួន មន្ត្រីនគរបាលយុត្តិធម៌ជួបនូវការលំបាកផ្សេងៗ មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹងស្តីអំពីការលំបាករបស់ខ្លួនទៅកាន់ចៅក្រមស៊ើបសួរ។[73] ក្រោយពីធ្វើការនាំខ្លួនជនដែលជាប់ពាក់ព័ន្ធបានមន្ត្រីនគរបាលយុត្តិធម៌ត្រូវតែនាំជននោះទៅបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរដើម្បីធ្វើការសួរចម្លើយ ឬស្តាប់ចម្លើយដែលពាក់ព័ន្ធ។ ប្រសិនបើមានកាលៈទេសៈណាមួយដែលជាហេតុនាំឲ្យមន្ត្រីនគរបាលយុត្តិធម៌មិនអាចនាំខ្លួន

[71] មាត្រា ១៩១, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។
[72] គម្រូនៃដីកាបង្គាប់ឲ្យនាំខ្លួន មានកំណត់មានកំណត់ក្នុងឧបសម្ព័ន្ធទី១៥
[73] មាត្រា ១៩២, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

បុគ្គលដែលជាប់ពាក់ព័ន្ធទៅបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរក្រោយពេលចាប់ខ្លួនបានទេ បុគ្គលនេះត្រូវនាំខ្លួនយ៉ាងយូរបំផុតថ្ងៃបន្ទាប់ដល់ចៅក្រមស៊ើបសួរ ឬអ្នកជំនួសប្រសិនបើការបង្ហាញខ្លួននៅថ្ងៃបន្ទាប់ទេ បុគ្គលពាក់ព័ន្ធត្រូវបានដោះលែងឲ្យមានសេរីភាពវិញ។[74] នេះមានន័យថាចិរវេលានៃការឃាត់ខ្លួន (ឃុំខ្លួន) ជនណាម្នាក់មិនអាចលើសពីរយៈពេល ៤៨ ម៉ោងនោះទេ។ កាលណាបុគ្គលជាប់ពាក់ព័ន្ធត្រូវបាននាំខ្លួនដល់ចៅក្រមស៊ើបសួររួចមកដោយស្ថិតនៅក្នុងជម្រើសរបស់ខ្លួន ចៅក្រមស៊ើបសួរអាចធ្វើការឃុំខ្លួន ឬមិនឃុំខ្លួន (ដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ) ទៅលើបុគ្គលនោះ។ យោងតាមការអនុវត្តជាក់ស្ដែង ចៅក្រមស៊ើបសួរតែងតែសម្រេចធ្វើការឃុំខ្លួន ក្នុងករណីដែលបទល្មើសដែលចោទប្រកាន់ទៅលើបុគ្គលនោះជាប្រភេទបទល្មើសធ្ងន់ធ្ងរ (បទឧក្រិដ្ឋ) ឬអាស្រ័យលើបុគ្គលិកលក្ខណៈនៃបុគ្គលនោះផ្ទាល់តែម្ដង។

*ឧទាហរណ៍៖* លោក ក ត្រូវបានគេចាប់ខ្លួនដោយការអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួននៅថ្ងៃទី២០ ខែមករា ឆ្នាំ២០១៤។ ប៉ុន្តែដោយសារតែមិនអាចបញ្ជូនលោក ក មកចំពោះមុខចៅក្រមស៊ើបសួរភ្លាម ដោយសារតែបញ្ហាដឹកជញ្ជូនផ្លូវឆ្ងាយ លោក ក ត្រូវបានឃុំខ្លួនមួយយប់នៅប៉ុស្ដិ៍នគរបាល។

ដូច្នេះបានសេចក្ដីថានៅថ្ងៃទី២១ ខែមករា ឆ្នាំ២០១៤ ទើបលោក ក ត្រូវបាននាំយកមកបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ។ ហើយបន្ទាប់មកលោក ក ក៏ត្រូវបានឃុំខ្លួននៅថ្ងៃនោះតែម្ដង។

ហេតុដូចនេះយោងតាមមាត្រា ១៩៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវចាត់ទុកថារយៈពេល ១ ថ្ងៃ ខាងលើនេះស្ថិតនៅក្នុងចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នដែរ។ ជាលទ្ធផល ចិរវេលានេះត្រូវគិតបញ្ចូលទាំងស្រុងទៅក្នុងចិរវេលានៃទោសដែលបានប្រកាស (មាត្រា ៥០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

ឧបមាថា ក្រោយមកតុលាការបានសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារលោក ក ចំនួន ៣ ខែ។ ដូច្នេះចិរវេលា ៣ ខែ ត្រូវចាប់ផ្ដើមគិតចាប់ពីថ្ងៃទី២០ ខែមករា ឆ្នាំ២០១៤ មិនមែនគិតពីថ្ងៃទី២១ ខែមករា ឆ្នាំ២០១៤ ឡើយ។[75]

### កថាខណ្ឌទី៣៖ ដីកាបង្គាប់ឲ្យចាប់ខ្លួន

#### ក. អត្ថន័យនៃដីកាបង្គាប់ឲ្យចាប់ខ្លួន

ដីកាបង្គាប់ឲ្យចាប់ខ្លួន ជាបញ្ជារបស់ចៅក្រមស៊ើបសួរបង្គាប់ឲ្យកម្លាំងសាធារណៈទាំងអស់ស្រាវជ្រាវរកការចាប់ខ្លួនជនត្រូវចោទ ឬបុគ្គលដែលពាក់ព័ន្ធមានពិរុទ្ធភាពមកចំពោះមុខចៅក្រមស៊ើបសួរដើម្បីនាំខ្លួនជននោះទៅពន្ធនាគា ឬមណ្ឌលឃុំខ្លួន និងបញ្ជាដល់ប្រធានពន្ធនាគារឬមណ្ឌលឃុំខ្លួនបុគ្គលនោះចំពោះបុគ្គល

---

[74] មាត្រា ១៩៣, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[75] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត, "នីតិវិធីព្រហ្មទណ្ឌ", (មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៤, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១៧), ៤៥។

ដែលបានគេចខ្លួនដោយមិនដឹងស្ថិតនៅទីណា។ ទោះបីជាដីកាបង្គាប់ឲ្យចាប់ខ្លួនត្រូវបានចេញដោយចៅក្រមស៊ើបសួរក៏ពិតមែន ប៉ុន្តែដើម្បីធានាឲ្យមានប្រសិទ្ធិភាពក្រមនីតិវិធីព្រហ្មទណ្ឌតម្រូវឲ្យមុននឹងចេញដីកាបង្គាប់ឲ្យចាប់ខ្លួនចៅក្រមស៊ើបសួរត្រូវតែទទួលយោបល់ពីព្រះរាជអាជ្ញាក្នុងដីកានេះជាមុនសិន ដើម្បីសម្រេចនូវមូលហេតុក្រោយពីទទួលយោបល់ពីព្រះរាជអាជ្ញា។ យ៉ាងណាមិញដីកាបង្គាប់ឲ្យចាប់ខ្លួន គឺធ្វើឡើងដោយមានការកំណត់ពីនិទ្ទេសនិងមានកាលបរិច្ឆេទ ហើយចុះហត្ថលេខាដោយចៅក្រមស៊ើបសួរដោយមានបោះត្រាផងគ្រាន់ជាបញ្ជារបស់ចៅក្រមស៊ើបសួរ បញ្ជាឲ្យកងកម្លាំងសាធារណៈស្វែងរកជនត្រូវចោទ ឬជនដែលជាប់ពាក់ព័ន្ធ ឬជនដែលមានពិរុទ្ធភាពមកចំពោះមុខចៅក្រមស៊ើបសួរដើម្បីធ្វើការសាកសួរយកចម្លើយ ឬស្តាប់ចម្លើយពាក់ព័ន្ធនឹងបទចោទប្រកាន់របស់ព្រះរាជអាជ្ញា។

### ខ. លក្ខខណ្ឌនៃការបង្គាប់ឲ្យចាប់ខ្លួន

ដីកាបង្គាប់ឲ្យចាប់ខ្លួន អាចចេញទៅលើជនត្រូវចោទ ឬបុគ្គលដែលមានតម្រុយពិរុទ្ធភាព។ ចៅក្រមស៊ើបសួរអាចធ្វើការចេញដីកានេះបានលុះត្រា ៖

- បទល្មើសដែលចោទប្រកាន់ គឺជាប្រភេទបទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ។[76]

- បុគ្គលដែលជាប់ពាក់ព័ន្ធបានរត់គេចខ្លួនមិនដឹងជាស្ថិតនៅទីកន្លែងណា ឬស្ថិតនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

ជាការពិតណាស់ ទោះបីជាដីកាបានបំពេញតាមលក្ខខណ្ឌខាងលើក៏ពិតមែន ប៉ុន្តែដីកានេះមិនអាចចេញភ្លាមដោយចៅក្រមស៊ើបសួរមិនបានជូនដំណឹង ឬសុំយោបល់ពីព្រះរាជអាជ្ញាទេ មានន័យថាចៅក្រមស៊ើបសួរត្រូវចេញដីកានេះដោយមានចែងពីមូលហេតុក្រោយពីទទួលបានយោបល់ពីព្រះរាជអាជ្ញា។ ហើយហេតុផលពីការសុំយោបល់ពីព្រះរាជអាជ្ញា ពីព្រោះដោយយោងលើហេតុផលក្នុងនាមជាព្រះរាជអាជ្ញា គឺជាម្ចាស់នៃបណ្តឹងអាជ្ញា និងជាបន្ទុកអនុវត្ត ការផ្សព្វផ្សាយដីកាបង្គាប់ឲ្យចាប់ខ្លួនផ្ទាល់តែម្តង។ ការជូនដំណឹងដល់ព្រះរាជអាជ្ញាអំពីការស្នើសុំចាប់ខ្លួនរបស់ចៅក្រមស៊ើបសួរត្រូវធ្វើឡើងតាមរយៈដីកាបញ្ជូនឲ្យឆ្លើយ។ ចំពោះយោបល់នៃការឆ្លើយតបលើការចាប់ខ្លួនរបស់ព្រះរាជអាជ្ញា មិនអាចជាកាតព្វកិច្ចរបស់ចៅក្រមស៊ើបសួរត្រូវអនុវត្តតាមនោះទេ មានន័យថាចៅក្រមស៊ើបសួរមានសិទ្ធិពេញលេញក្នុងការចេញ ដីកាបង្គាប់ឲ្យចាប់ខ្លួនទៅលើជនត្រូវចោទបានដោយមានមូលហេតុ សំអាងហេតុ និងសំអាងច្បាប់ត្រឹមត្រូវ។

[76] មាត្រា ១៩៦, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

សរុបមក ដីកាបង្គាប់ឲ្យចាប់ខ្លួនជាវិធានការដែលបង្គំដោយចៅក្រមស៊ើបសួរចេញដីកានេះដើម្បីឲ្យមន្ត្រីអនុវត្តច្បាប់ចាប់ខ្លួនជនត្រូវចោទ ដើម្បីយកមកបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ។ ការចេញដីកានេះដោយផ្អែកលើស្ថានភាពមួយចំនួន គឺករណីបទល្មើសត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលជាបទល្មើសដែលត្រូវផ្តន្ទាទោសដាក់ពន្ធធនាគារ និងករណីដែលជនត្រូវចោទ ឬជនជាប់ពាក់ព័ន្ធបានរត់គេចមិនដឹងស្ថិតនៅទៅកន្លែងណា។

ចំពោះដីកាបង្គាប់ឲ្យចាប់ខ្លួន ចៅក្រមស៊ើបសួរត្រូវចេញដីកាដោយកំណត់ពីនិទ្ទេសឲ្យបានត្រឹមត្រូវដើម្បីប្រាស់ចាកពីមោឃភាពនៃដីកា។ ហើយនិទ្ទេសទាំងនោះរួមមានដូចខាងក្រោម៖

- កំណត់អត្តសញ្ញាណបុគ្គលដែលពាក់ព័ន្ធ
- កំណត់បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់បង្ក្រាបបទល្មើស
- កំណត់ឈ្មោះ ឋានៈរបស់ចៅក្រមស៊ើបសួរដែលចេញដីកា។
- ដីកាបង្គាប់ឲ្យចាប់ខ្លួនត្រូវមានចុះពីការបរិច្ឆេទ ចុះហត្ថលេខា និងបោះត្រាផង។[77]

**គ. ការអនុវត្តដីកាបង្គាប់ឲ្យចាប់ខ្លួន**

ការអនុវត្តដីកាបង្គាប់ឲ្យចាប់ខ្លួនត្រូវប្រគល់ឲ្យមន្ត្រីនគរបាលយុត្តធម៌។[78] ហេតុដូចនេះដើមដីកាត្រូវប្រគល់ក្នុងរយៈពេលយ៉ាងខ្លីបំផុតទៅឲ្យមន្ត្រីនគរបាលយុត្តធម៌ដែលទទួលបន្ទុកអនុវត្តដីកានេះ។ ក្នុងករណីបន្ទាន់ ដីកាបង្គាប់ឲ្យចាប់ខ្លួនត្រូវផ្សព្វផ្សាយជាសាធារណៈតាមរយៈវិធីសាស្ត្រជាច្រើនរួមមានដូចជា តាមរយៈកាសែត ទូរទស្សន៍ វិទ្យុ ឬប្រព័ន្ធអ៊ីនធើណេតជាអាទិ៍។ ដីកាបង្គាប់ឲ្យចាប់ខ្លួន មិនត្រឹមតែអាចផ្សព្វផ្សាយជាសាធារណៈក្នុងដែនដីព្រះរាជាណាចក្រកម្ពុជាប៉ុណ្ណោះទេ នៅក្នុងករណីចាំបាច់ដីកាបង្គាប់ឲ្យចាប់ខ្លួនអាចជាផ្សព្វផ្សាយជាអន្តរជាតិបានតាមរយៈក្រសួងយុត្តធម៌ដោយប្រើយន្តការនានាផងដែរមានប្រសិទ្ធិភាព។[79] នេះបញ្ជាក់បានថាការអនុវត្តដីកាបង្គាប់ឲ្យចាប់ខ្លួនអាចធ្វើឡើងដែនវិសាលភាពអន្តរជាតិបាន។ ដោយការអនុវត្ត ដីកានេះគឺតម្រូវឲ្យមន្ត្រីនគរបាលយុត្តធម៌នៃព្រះរាជាណាចក្រកម្ពុជាចូលរួមសហការជាមួយប៉ូលីសអន្តរជាតិ ដែលមានសមត្ថកិច្ចដើម្បីស្រាវជ្រាវចាប់ខ្លួនជនត្រូវចោទ ហើយមន្ត្រីនគរបាលយុត្តិធម៌ត្រូវតែនាំខ្លួនជននោះមកកាន់ចំពោះមុខចៅក្រមស៊ើបសួរដើម្បីធ្វើការសាកសួរចម្លើយរកការពិត។

ក្រោយពីមន្ត្រីនគរបាលយុត្តិធម៌ទទួលបានសិទ្ធិចាប់ខ្លួនជនត្រូវចោទ ឬជនដែលជាប់ពាក់ព័ន្ធតាមរយៈដីកាបង្គាប់ឲ្យចាប់ខ្លួនហើយ មន្ត្រីនគរបាលយុត្តិធម៌អាចចូលចាប់ខ្លួនជនដែលមានអត្តសញ្ញាណដូចដែលដីកា

[77] មាត្រា ១៩៨, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[78] មាត្រា ១៩៩, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[79] មាត្រា ២០០, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

បានកំណត់គ្រប់ពេលវេលា ប៉ុន្តែការចាប់ខ្លួនមិនត្រូវបំពានសិទ្ធិលំនៅដ្ឋានបានទេ។ មានន័យថាទោះបីដីកាមានអនុភាពយ៉ាងណាក៏ដោយតែអភ័យឯកសិទ្ធិនៃលំនៅដ្ឋានត្រូវតែគោរព។ មន្ត្រីនគរបាលយុត្តិធម៌មិនអាចចូលទៅក្នុងលំនៅដ្ឋានរបស់បុគ្គលដូចដែលបានកំណត់ឈ្មោះក្នុងដីកាមុនម៉ោង៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំ) ល្ងាចបានឡើយ ហើយត្រូវជូនដំណឹងរាល់ការលំបាករបស់ខ្លួនក្នុងការបំពេញបេសកកម្មទៅកាន់ចៅក្រមស៊ើបសួរ។

ដីកាបង្គាប់ឲ្យចាប់ខ្លួន គឺជាលិខិតបញ្ជាឲ្យឃុំខ្លួនស្របច្បាប់របស់អាជ្ញាធរតុលាការ។[80] ដូចនេះប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនត្រូវទទួល និងឃុំខ្លួនជនត្រូវចោទដែលជាកម្មវត្ថុនៃដីកាបង្គាប់ឲ្យចាប់ខ្លួនដោយតម្រូវឲ្យប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនទុកដើមដីកាឬចុងដីកាដែលមានបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម។ កាលណាបុគ្គលដែលត្រូវបានចាប់ខ្លួនដែលអនុវត្តតាមដីកាបង្គាប់ឲ្យចាប់ខ្លួនត្រូវបានឃុំខ្លួន នោះថិរវេលានៃការឃុំខ្លួនត្រូវបានរាប់បញ្ចូលទៅក្នុងថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នប្រសិនបើមាន។ បុគ្គលដែលពាក់ព័ន្ធត្រូវនាំទៅបង្ហាញនៅចំពោះមុខចៅក្រមស៊ើបសួរ ឬអ្នកជំនួសចៅក្រមស៊ើបសួរក្នុងរយៈពេលខ្លីបំផុតប្រសិនបើស្ថិតក្នុងដំណាក់កាលស៊ើបសួរនៅឡើយ។ ប៉ុន្តែករណីជនត្រូវចោទ ឬជនដែលជាប់ពាក់ព័ន្ធមិនត្រូវបាននាំខ្លួនបង្ហាញទៅចៅក្រមស៊ើបសួរ ឬអ្នកជំនួសចៅក្រមស៊ើបសួរនៅថ្ងៃបន្ទាប់ពីការចាប់ខ្លួន ព្រះរាជអាជ្ញាដែលនៅទីកន្លែងឃុំខ្លួននោះត្រូវទទួលភារកិច្ច ស្តាប់ចម្លើយ ឬសួរយកចម្លើយពិតពីជនត្រូវចោទ ឬជនជាប់ពាក់ព័ន្ធដែលក្នុងដីកាបង្គាប់ឲ្យចាប់ខ្លួនបានកំណត់ឈ្មោះ។ ក្រោយពីធ្វើកិច្ចស៊ើបសួររកចម្លើយដើម្បីបញ្ជាក់ការពិតហើយ ព្រះរាជអាជ្ញាត្រូវធ្វើកំណត់ហេតុស្តីពីការស្តាប់ចម្លើយបញ្ជូនទៅចៅក្រមស៊ើបសួរដែលទទួលបន្ទុកស៊ើបសួរសំណុំរឿង។ ម្យ៉ាងវិញទៀតប្រសិនបើមានការផ្ទេរបុគ្គលពាក់ព័ន្ធទៅពន្ធនាគារផ្សេងទៀត ការផ្ទេរនេះជាតួនាទីរបស់ព្រះរាជអាជ្ញាក្នុងការចាត់ចែង។ ជានីតិវិធីដែលត្រូវសម្គាល់ផងដែរថានៅពេលខ្លះជនត្រូវចោទដែលជាកម្មវត្ថុនៃដីកាបង្គាប់ឲ្យចាប់ខ្លួននោះមិនត្រូវបានបញ្ជូនទៅបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរទេ។ មូលហេតុព្រោះថានៅពេលចៅក្រមស៊ើបសួរចេញដីកាបង្គាប់ឲ្យចាប់ខ្លួនហើយ គាត់បានសម្រេចបិទបញ្ចប់ការស៊ើបសួររបស់គាត់ដោយបញ្ជូនសុំណុំរឿងនោះមកជំនុំជម្រះ ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់យុត្តាធិកាជំនុំជម្រះ (ចៅក្រមស៊ើបសួរ)។ ក្នុងករណីនេះ បុគ្គលនោះត្រូវតែបញ្ជូនខ្លួនទៅចំពោះមុខចៅក្រមជំនុំជម្រះដើម្បីបើកសវនាការអង្គសេចក្តីជំនុំជម្រះសម្រេចអំពីរឿងឃុំខ្លួន ឬមិនឃុំខ្លួនជននោះប្រសិនបើពុំទាន់ដល់ការកំណត់នៃសវនាអង្គសេចក្តី។

[80] គម្រូនៃដីកាបង្គាប់ឲ្យចាប់ខ្លួន មានកំណត់ក្នុងឧបសម្ព័ន្ធទី១៦

*ឧទាហរណ៍៖* បទឃាតកម្ម (ទោសដាក់ពន្ធនាគារពី ១០ឆ្នាំ ទៅ ១៥ឆ្នាំ) បទលួច (ទោសដាក់ពន្ធនាគារពី ៦ខែ ទៅ ៣ឆ្នាំ) គឺជាបទល្មើសដែលអាចជាកម្មវត្ថុនាំឲ្យមានការចេញដីកាបង្គាប់ឲ្យចាប់ខ្លួន។ ក៏ប៉ុន្តែបទបរិហារកេរ្តិ៍ជាសាធារណៈគឺជាបទល្មើសដែលមានត្រឹមតែជាការផ្តន្ទាទោសពិន័យជាប្រាក់ប៉ុណ្ណោះដូច្នេះមិនអាចជាកម្មវត្ថុនៃការចេញដីកាបង្គាប់ឲ្យចាប់ខ្លួនបានឡើយ។

*ឧទាហរណ៍៖* ក្រោយពីបានប្រព្រឹត្តបទល្មើសរួច លោក ក បានរួចគេចខ្លួនចេញពីលំនៅដ្ឋាន។ ដូច្នេះប្រសិនបើមានភស្តុតាង លោក ក បានរត់គេចខ្លួនដូច្នេះមែន (ជាទូទៅភស្តុតាងនេះបញ្ជាក់ឲ្យនគរបាលយុត្តធម៌) នោះចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឲ្យចាប់ខ្លួនបាន។ ដូចគ្នាដែរ នៅក្នុងករណីមានភស្តុតាងជនត្រូវចោទស្ថិតនៅក្រៅប្រទេសក៏ចៅក្រមស៊ើបសួរអាចចេញដីកានេះបានដែរ។[81]

### កថាខណ្ឌទី៤៖ ដីកាបង្គាប់ឲ្យឃុំខ្លួន

#### ក. អត្ថន័យនៃដីកាបង្គាប់ឲ្យឃុំខ្លួន

ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឲ្យឃុំខ្លួនបាន។[82] ដីកាបង្គាប់ឲ្យឃុំខ្លួន គឺជាបញ្ជាដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឲ្យទទួល និងឃុំខ្លួនជនត្រូវចោទ។ ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឲ្យឃុំខ្លួនបានលុះត្រាតែបន្ទាប់ពីចេញដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្ន។[83]

#### ខ. លក្ខខណ្ឌនៃការចេញដីកាបង្គាប់ឲ្យឃុំខ្លួន

ចៅក្រមស៊ើបសួរ សម្រេចចេញដីកាបង្គាប់ឲ្យឃុំខ្លួនលុះត្រាតែជនត្រូវចោទជាកម្មវត្ថុនៃដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្ន។ បានន័យថាលក្ខខណ្ឌនៃការចេញដីកាបង្គាប់ឲ្យឃុំខ្លួន គឺអាចប្រព្រឹត្តទៅបានបន្ទាប់ពីចៅក្រមស៊ើបសួរបានសម្រេចធ្វើការឃុំខ្លួនជនណាម្នាក់តាមរយៈដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្ន។ ផ្ទុយទៅវិញចៅក្រមស៊ើបសួរមិនអាចចេញដីកាបង្គាប់ឲ្យឃុំខ្លួន ជនត្រូវចោទមុនការសម្រេចឃុំខ្លួនបណ្តោះអាសន្នបានទេ។ ហើយចៅក្រមស៊ើបសួរ អាចសម្រេចចេញដីកាបង្គាប់ឲ្យឃុំខ្លួនបានដោយកំណត់ពីនិទ្ទេសដែលត្រូវចុះក្នុងដីកាបង្គាប់ឲ្យឃុំខ្លួនដូចខាងក្រោម ៖

- លេខ ថ្ងៃ ខែ ឆ្នាំ សំណុំរឿង
- អត្តសញ្ញាណរបស់ជនត្រូវចោទ
- ប្រភេទបទល្មើសដែលបានចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស

[81] វុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត, "នីតិវិធីព្រហ្មទណ្ឌ", (មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៤, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១៧), ៤៥។

[82] មាត្រា ២១៩, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[83] មាត្រា ២២០, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា

- ដីកាត្រូវមានចុះលេខនៃការចេញដីកាស្របតាមលំដាប់លេខរៀងនៃសៀវភៅចុះលេខដីកាបង្គាប់ឲ្យឃុំខ្លួន។ ដីកាបង្គាប់ឲ្យឃុំខ្លួនត្រូវចុះកាលបរិច្ឆេទនិងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរនិងមានបោះត្រាផង។[84]

### គ. ការអនុវត្តដីកាបង្គាប់ឲ្យឃុំខ្លួន

ចំពោះការអនុវត្តដីកាបង្គាប់ឲ្យចាប់ខ្លួនដីកានេះត្រូវយកទៅអនុវត្តដោយប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួននៅកន្លែងដែលបុគ្គលនោះឃុំខ្លួន។ ប៉ុន្តែក្នុងលក្ខខណ្ឌដែលបុគ្គលដែលត្រូវឃុំខ្លួនកំពុងស្ថិតនៅក្រោមការឃុំខ្លួនរបស់មន្ត្រីនគរបាលយុត្តិធម៌នៅឡើយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការបញ្ជូនជនត្រូវចោទ ឬជនជាប់ពាក់ព័ន្ធនោះទៅកាន់ពន្ធនាគារ ឬមណ្ឌលឃុំខ្លួនដូចមានបញ្ជាក់ចង្អុលបង្ហាញតាមរយៈដីកាបង្គាប់ឲ្យឃុំខ្លួន។[85]

ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនត្រូវទទួល និងឃុំខ្លួនបុគ្គលដែលមានដីកាបង្គាប់ឲ្យឃុំខ្លួនរហូតទាល់តែមានការទទួលដំណឹងអំពីការដោះលែងឲ្យមានសេរីភាពវិញ។[86] ម្យ៉ាងវិញទៀតប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនត្រូវរក្សាទុកដើមដីកាបង្គាប់ឲ្យឃុំខ្លួន ឬចុងដីកានេះដែលបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់។

## ផ្នែកទី២៖ ការកំណត់សិទ្ធិទៅកាន់ជនត្រូវចោទ

ការកំណត់សិទ្ធិទៅជនត្រូវចោទ គឺជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរក្នុងដំណាក់ កាលស៊ើបសួរស្វែងរកការពិត។ ជាក់ស្តែងចៅក្រមស៊ើបសួរមានសិទ្ធិអំណាចពេញលេញដើម្បីរកជនត្រូវចោទជូនតុលាការឲ្យចាត់វិធានការ និងអនុវត្តឲ្យស្របច្បាប់នឹងច្បាប់នៃដែនដីព្រះរាជាណាចក្រកម្ពុជាតាមរយៈការឃុំខ្លួនបណ្តោះអាសន្ន ការដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ និងការធានាជនត្រូវចោទឲ្យនៅក្រៅឃុំ។

ចំពោះការឃុំខ្លួនបណ្តោះអាសន្ន គឺជាការដកហូតនូវសិទ្ធិសេរីភាពក្នុងការដើរហើរដោយជនត្រូវចោទត្រូវបានឃុំខ្លួនក្នុងមណ្ឌលឃុំខ្លួន ឬពន្ធនាគារ។

ការត្រួតពិនិត្យតាមផ្លូវតុលាការ គឺសម្តៅលើករណីដកហូតសិទ្ធិខ្លះតែប៉ុណ្ណោះដោយជនត្រូវចោទមានសេរីភាពនៅក្រៅឃុំ ប៉ុន្តែជននោះត្រូវមានកាតព្វកិច្ចត្រូវបំពេញមួយចំនួន។

ការធានាជនត្រូវចោទឲ្យនៅក្រៅឃុំ គឺជាដីកាសម្រេចមិនឃុំខ្លួនជនត្រូវចោទ ប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថាលក្ខខណ្ឌនៃការឃុំខ្លួនមិនមែនជាវិធានការចាំបាច់។

---

[84] មាត្រា ២២១, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[85] គម្រូនៃដីកាបង្គាប់ឲ្យឃុំខ្លួន មានកំណត់ក្នុងឧបសម្ព័ន្ធទី១៧

[86] មាត្រា ២២២, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

**កថាខណ្ឌទី១៖ ការឃុំខ្លួនបណ្តោះអាសន្ន**

បុគ្គលគ្រប់រូបសុទ្ធតែមានសិទ្ធិសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន។ គ្មានជនណាម្នាក់ត្រូវបានចាប់ខ្លួន ឬឃុំខ្លួនតាមអំពើចិត្តបានឡើយ មានន័យថាគ្មានបុគ្គលណាម្នាក់ត្រូវបានដកហូតសេរីភាពបានឡើយលើកលែងតែមានហេតុផលត្រឹមត្រូវ និងស្របតាមនីតិវិធីដែលមានចែងក្នុងច្បាប់។ ប៉ុន្តែការឃុំខ្លួនបណ្តោះអាសន្នគឺជាករណីពិសេសហើយមានអំណាចធំបំផុត ដែលក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់សិទ្ធិនេះជូនចៅក្រមស៊ើបសួរដើម្បីអនុវត្តច្បាប់។ ដីកាក្នុងការសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្នដើម្បីធានារក្សានូវកិច្ចស៊ើបសួរស្វែងរកការពិតនៃរឿងព្រហ្មទណ្ឌ ប៉ុន្តែអាចអនុវត្តក្នុងការឃុំខ្លួនជនដែលជាកម្មវត្ថុនៃការសម្រេចឃុំខ្លួនជនដែលជាកម្មវត្ថុនៃការសម្រេចឃុំខ្លួនបណ្តោះអាសន្នបានលុះត្រាតែចៅក្រមស៊ើបសួរចេញដីកាបង្គាប់ឲ្យឃុំខ្លួនមួយផ្សេងទៀត។

**ក. លក្ខខណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្ន**

ការឃុំខ្លួនបណ្តោះអាសន្នអនុវត្តបានតែក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលច្បាប់កំណត់ឲ្យផ្តន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១ (មួយ) ឆ្នាំ[87]។ ហើយដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្នចៅក្រមស៊ើបសួរអាចសម្រេចបានដោយយោងតាមហេតុផលដូចខាងក្រោម៖

- ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតជាថ្មី។ *ឧទាហរណ៍៖* បុរស ក ធ្លាប់បានប្រព្រឹត្តបទល្មើសច្រើនដងមកហើយដូច្នេះការឃុំខ្លួនបុរស ក មានគោលដៅដើម្បីបង្ការកុំឲ្យបុរស ក ទៅប្រព្រឹត្តបទល្មើសថ្មីទៀត។

- ដើម្បីរារាំងកុំឲ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីទប់ស្កាត់កុំឲ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកផ្សំគំនិត។ *ឧទាហរណ៍៖* មានភស្តុតាងបញ្ជាក់ថា មានអ្នកសមគំនិតដែលកំពុងតែរត់គេចខ្លួនមិនទាន់ចាប់ខ្លួនបាននៅឡើយ។ ដូច្នេះមូលហេតុទីពីរនេះអាចជាមូលហេតុនាំឲ្យមានការឃុំខ្លួនបណ្តោះអាសន្នបាន។

- ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ។ *ឧទាហរណ៍៖* នៅក្នុងសំណុំរឿងនៃបទឃាតកម្ម កាំភ្លើងដែលជនត្រូវចោទបានប្រើប្រាស់ដើម្បីសម្លាប់ជនរងគ្រោះមិនទាន់បានរកឃើញនៅឡើយ ហើយជនត្រូវចោទក៏ពុំព្រមប្រាប់ពីទីកន្លែងលាក់លាក់កាំភ្លើងនោះដែរ។

- ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី។ *ឧទាហរណ៍៖* ជនត្រូវចោទពុំមានទីលំនៅច្បាស់លាស់ ឬពិតប្រាកដ។ ដូច្នេះប្រសិនបើមិនឃុំខ្លួនបណ្តោះអាសន្នទេ មានការលំបាកនឹងតាមរកជនត្រូវចោទឲ្យមកបង្ហាញខ្លួនចំពោះមុខតុលាការសម្រាប់ពេលសវនាការនៅពេលក្រោយទៀត។ ចំណុចនេះក្នុងការ

[87] មាត្រា ២០៤, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

អនុវត្តជាក់ស្តែង មូលហេតុនេះត្រូវបានយកមកប្រើប្រាស់ញឹកញាប់ជាងគេពីព្រោះថាប្រសិនបើជនត្រូវចោទត្រូវបានចោទប្រកាន់ពីបទល្មើសណាមួយ (ធ្ងន់ធ្ងរ) នោះភាគច្រើនជនត្រូវចោទប្រាកដជារត់គេចមិនចូលមកបង្ហាញខ្លួននៅចំពោះមុខតុលាការទៀតទេ។

- ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈ កុំឲ្យច្របូកច្របល់ដែលបណ្តាលមកពីបទល្មើស។[88] *ឧទាហរណ៍៖* ជនត្រូវចោទបានប្រព្រឹត្តបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងបានប្រើប្រាស់អាវុធ (បាញ់ទៀង) បណ្តាលឲ្យមានការភ្ញាក់ផ្អើលដល់មនុស្សជាច្រើននាក់។ ដូច្នេះការឃុំខ្លួនជនត្រូវចោទរូបនេះអាចមានគោលដៅដើម្បីធានាឲ្យមានការច្របូលច្របល់ដល់សណ្តាប់ធ្នាប់សាធារណៈ។

ខាងលើនេះ ជាមូលហេតុចាំបាច់ដែលចៅក្រមស៊ើបសួរសម្រេចធ្វើការឃុំខ្លួនជនត្រូវចោទ។

ជាគោលការណ៍ ចៅក្រមស៊ើបសួរអាចសម្រេចឃុំខ្លួនបណ្តោះអាសន្នចំពោះជនត្រូវចោទ ឬជនដែលបានប្រព្រឹត្តបទល្មើសទៅតាមនីតិវិធីនៃច្បាប់។ ប៉ុន្តែមានករណីមួយដែលចៅក្រមស៊ើបសួរមិនអាចធ្វើការសម្រេចប្រកាសទោសទណ្ឌកម្មទៅលើអនីតិជនដែលមានអាយុតិចជាង ១៤ (ដប់បួន) ឆ្នាំបានទេ បានន័យថាតុលាការអាចប្រកាសទោសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំឡើងទៅប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈតម្រូវ។ ហេតុដូចនេះ ចំពោះអនីតិជនដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ មិនទទួលខុសត្រូវព្រហ្មទណ្ឌចំពោះទង្វើរបស់ខ្លួនឡើយបានទេ។ ចៅក្រមស៊ើបសួរអាចសម្រេចប្រគល់អនីតិជននេះឲ្យឪពុកម្តាយ ឬអាណាព្យាបាល ឬប្រគល់ទៅមណ្ឌលអប់រំកែប្រែក្នុងករណីគ្មានអាណាព្យាបាលដើម្បីរក្សាបណ្តោះអាសន្នរង់ចាំសេចក្តីសម្រេចរបស់តុលាការ។

ក្នុងករណីជនត្រូវចោទមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំឡើងទៅ ចៅក្រមស៊ើបសួរអាចចេញដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្នបាន[89] ប៉ុន្តែតម្រូវឲ្យមាននិទ្ទេសសំខាន់ៗដូចខាងក្រោម៖

- ឈ្មោះចៅក្រមស៊ើបសួរ
- ឈ្មោះក្រឡាបញ្ជី
- លេខ ថ្ងៃ ខែ ឆ្នាំ សំណុំរឿង
- កាលបរិច្ឆេទនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ
- អត្តសញ្ញាណនៃជនត្រូវចោទ ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត លំនៅដ្ឋានរបស់ជនត្រូវចោទ ប្រសិនបើមានពិរុទ្ធកម្មត្រូវប្រកាស (ធ្លាប់មានទោស ឬគ្មាន)

---

[88] មាត្រា ២០៥, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[89] គម្រូនៃដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្ន មានកំណត់ក្នុងឧបសម្ព័ន្ធទី១៨

- លេខ និងកាលបរិច្ឆេទនៃដីកា។

ក្រៅពីបញ្ជាក់ពីមូលហេតុពីការឃុំខ្លួនបណ្ដោះអាសន្នខាងលើ ចៅក្រមស៊ើបសួរត្រូវតែកំណត់ឲ្យបានច្បាស់នូវមាត្រានៃនីតិវិធីព្រហ្មទណ្ឌដែលចែងពីថិរវេលាអតិបរិមានៃការឃុំខ្លួនបណ្ដោះអាសន្ន ដែលថិរវេលានេះអាស្រ័យលើចរិកលក្ខណៈនៃបទល្មើស និងអាយុរបស់ជនត្រូវចោទ។

បន្ទាប់ពីមូលហេតុខាងលើ ចៅក្រមស៊ើបសួរក៏អាចសម្រេចឃុំខ្លួនជនត្រូវចោទបណ្ដោះអាសន្នបានដែរ ប្រសិនបើជនត្រូវចោទព្យាយាមគេចវេះដោយចេតនានៃកាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការ។ កាលណាចៅក្រមស៊ើបសួរសម្រេចថានឹងឃុំខ្លួនបណ្ដោះអាសន្នដោយមូលហេតុខាងលើនេះ ចៅក្រមស៊ើបសួរត្រូវចាត់នីតិវិធីដូចមានចែងក្នុងមាត្រា ២០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌដោយត្រូវជូនដំណឹងដល់ជនត្រូវចោទដើម្បីទទួលការកត់សម្គាល់របស់ជននេះ និងមធ្យោបាយការពារខ្លួនដែលធ្វើឡើងដោយមេធាវីរបស់ជននោះ។ ចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនជនត្រូវចោទតាមដីកាដែលមានសំអាងហេតុផលច្បាស់លាស់។ ដីកានេះត្រូវជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។ ករណីចៅក្រមស៊ើបសួរអាចសម្រេចឃុំខ្លួនបណ្ដោះអាសន្នមិនឲ្យលើសពី ៤ (បួន) ខែ ចំពោះនីតិជន និង ២ (ពីរ) ខែ ចំពោះអនីតិជន។

### ខ. នីតិវិធីនៃការឃុំខ្លួនបណ្ដោះអាសន្ន

ចៅក្រមស៊ើបសួរ អាចសម្រេចអំពីវិធាននៃការឃុំខ្លួនបណ្ដោះអាសន្ននេះដោយគំនិតរបស់ខ្លួនផ្ទាល់ ឬតាមសេចក្ដីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា។ មុននឹងសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ចៅក្រមស៊ើបសួរត្រូវជូនដំណឹងដល់ជនត្រូវចោទហើយទទួលការកត់សម្គាល់នានារបស់ជនត្រូវចោទ។[90] បន្ទាប់ពីចៅក្រមស៊ើបសួរចេញដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន គឺត្រូវចេញដីកាមួយទៀតហៅថាដីកាបង្គាប់ឲ្យឃុំខ្លួន។ ដីកានេះគឺបញ្ជាក់ដល់ប្រធានពន្ធធនាគារ ឬមណ្ឌលឃុំខ្លួនឲ្យទទួល និងឃុំខ្លួនជនត្រូវចោទដែលមានកំណត់ក្នុងដីកាសម្រេចឲ្យឃុំខ្លួនបណ្ដោះអាសន្ន។

ការឃុំខ្លួនបណ្ដោះអាសន្នអាចធ្វើឡើងតាមសេចក្ដីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ករណីនេះបន្ទាប់ពីទទួលបណ្ដឹងតាមសេចក្ដីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាសុំឲ្យឃុំខ្លួនបណ្ដោះអាសន្ន។ ប្រសិនបើចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនបណ្ដោះអាសន្នជនត្រូវចោទតាមការស្នើសុំរបស់ព្រះរាជអាជ្ញានោះ ចៅក្រមស៊ើបសួរត្រូវចាត់វិធានការតាមនីតិវិធីដូចមានចែងក្នុងមាត្រា ២០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។ ប៉ុន្តែបើចៅក្រមស៊ើបសួរមិនព្រមសម្រេចឃុំខ្លួនបណ្ដោះអាសន្នតាមការស្នើសុំនេះ ចៅក្រមត្រូវចេញដីកាសម្រេចមិនឃុំខ្លួនក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ដោយមិនចាំបាច់មានសំអាងហេតុទេ ហើយត្រូវជូនដំណឹងនេះជាបន្ទាន់ដល់ព្រះរាជអាជ្ញា។

[90] មាត្រា ២០៦, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

ក្នុងករណីចៅក្រមស៊ើបសួរ សម្រេចថានឹងឃុំខ្លួនបណ្ដោះអាសន្នដោយគំនិតផ្ដើមរបស់ខ្លួនគាត់ត្រូវជូនដំណឹងអំពីការឃុំខ្លួននេះភ្លាមដល់ព្រះរាជអាជ្ញា និងប្រាប់ទៅជនត្រូវចោទដែលត្រូវធ្វើឡើងតាមរយៈកំណត់ហេតុស្ដីពីការពិភាក្សាដេញដោលចំពោះមុខ។ ការជូនដំណឹងទៅកាន់ព្រះរាជអាជ្ញាត្រូវធ្វើឡើងក្នុងកំឡុងពេល៥ (ប្រាំ) ថ្ងៃយ៉ាងយូរបំផុត។

### គ. ចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន

ចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ត្រូវបានបញ្ញត្តិនៅក្នុងក្រមនីតិវិធីនៃក្រមព្រហ្មទណ្ឌដែលមានលក្ខណៈខុសគ្នាអាស្រ័យទៅលើប្រភេទនៃបទល្មើស (បទឧក្រិដ្ឋ ឬបទមជ្ឈិម) ហើយជនត្រូវចោទគឺស្ថិតនៅអាយុប៉ុន្មាន? តើគាត់គឺជានីតិជន ឬអនីតិជន? ចំពោះអនីតិជនដែលមានអាយុតិចជាង ១៤ (ដប់បួន) ឆ្នាំ ចៅក្រមស៊ើបសួរមិនអាចសម្រេចចេញដីកាបង្គាប់ឲ្យឃុំខ្លួនបណ្ដោះអាសន្នបានទេ។ ករណីនេះចៅក្រមស៊ើបសួរត្រូវសម្រេចប្រគល់គាត់ទៅកាន់ឪពុកម្ដាយ ឬអាណាព្យាបាល ឬមណ្ឌលអប់រំថែរក្សាបណ្ដោះអាសន្នដើម្បីធ្វើការរងចាំសេចក្ដីសម្រេចរបស់តុលាការ។

**ករណីជនត្រូវចោទជានីតិជនត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ[91]**

ចំពោះនីតិជនដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៦ (ប្រាំមួយ) ខែបានឡើយ។ ប៉ុន្តែបន្ទាប់ពីចិរវេលានោះ ចៅក្រមស៊ើបសួរអាចពន្យារការឃុំខ្លួនបណ្ដោះអាសន្នបានម្ដងរយៈពេល ៦(ប្រាំមួយ)ខែដោយមានដីកាសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់ដែលដីកាសុំពន្យារពេលនោះហៅថា (ដីកាសម្រេចឲ្យពន្យារពេលឃុំខ្លួនបណ្ដោះអាសន្ន)។[92] ការសុំពន្យារពេលនៃការឃុំខ្លួនបណ្ដោះអាសន្ននេះចៅក្រមស៊ើបសួរអាចសម្រេចពន្យារឃុំខ្លួនបានតែចំនួន ២ (ពីរ) ដងប៉ុណ្ណោះ។

**ករណីជនត្រូវចោទជានីតិជនត្រូវបានចោទប្រកាន់ពីបទមជ្ឈិម[93]**

ចំពោះនីតិជនដែលត្រូវបានចោទប្រកាន់ពីបទមជ្ឈិម ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៤ (បួន) ខែបានឡើយ។ នៅក្នុងចិរវេលានេះ ចៅក្រមស៊ើបសួរអាចធ្វើការសម្រេចពន្យារពេលនៃការឃុំខ្លួនបណ្ដោះអាសន្នបានម្ដងគត់មិនឲ្យលើសពី ២ (ពីរ) ខែ ដោយមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់នៅក្នុងដីកានេះ។ ចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ននេះមិនអាចលើសពីពាក់កណ្ដាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់ឡើយ។ ចំពោះដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នក្នុងករណីនេះមិនមែនជាការឃុំខ្លួនដែលកើតចេញពីអនុភាពផ្ទាល់នៃដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នទៅវិញ។

[91] មាត្រា ២០៨, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[92] គម្រូនៃដីកាសម្រេចឲ្យពន្យារពេលឃុំខ្លួនបណ្ដោះអាសន្ន មានកំណត់ក្នុងឧបសម្ព័ន្ធទី១៩

[93] មាត្រា ២០៩, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

**ករណីជនត្រូវចោទត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ប្រល័យពូជសាសន៍ និងបទឧក្រិដ្ឋកម្មសង្គ្រាម[94]**

ប្រសិនបើមានការចោទប្រកាន់ពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិក្តី ប្រល័យពូជសាសន៍ក្តី និងបទឧក្រិដ្ឋកម្មសង្គ្រាមក្តី ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ១ (មួយ)ឆ្នាំ បានទេចំពោះបទល្មើសទាំងនេះ។ ក្រោយពីផុតចិរវេលាការឃុំខ្លួនបណ្តោះអាសន្ននេះប្រសិនបើចៅក្រមស៊ើបសួរមានសំអាងហេតុត្រឹមត្រូវនិងច្បាស់លាស់នោះចៅក្រមរូបនេះអាចធ្វើការពន្យារការឃុំខ្លួនបណ្តោះអាសន្នម្តងបាន ១ (មួយ) ឆ្នាំ ហើយដីកាបង្គាប់ឲ្យពន្យារពេលឃុំខ្លួនបណ្តោះអាសន្ន[95] នេះបានតែ ២ (ពីរ) ដងគត់។

**ករណីជនត្រូវចោទជាអនីតិជនត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ[96]**

ចំពោះអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ ចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នគឺ៖

- ដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ៤ (បួន) ខែបានទេកាលណាអនីតិជននោះមានអាយុតិចជាង ១៦ (ដប់ប្រាំមួយ) ឆ្នាំ។

- ដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ៦ (ប្រាំមួយ) ខែបានទេកាលណាអនីតិជននោះមានអាយុពី ១៦ (ដប់ប្រាំមួយ) ឆ្នាំដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ។

ចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នខាងលើនេះ មិនត្រូវលើសពីពាក់កណ្តាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់សម្រាប់អនីតិជនឡើយ។

**ករណីជនត្រូវចោទជាអនីតិជនត្រូវបានចោទប្រកាន់ពីបទមជ្ឈិម[97]**

ចំពោះអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ត្រូវបានចៅក្រមស៊ើបសួរចេញដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្នពីបទមជ្ឈិម ហេតុនេះចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នគឺ៖

- ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ២ (ពីរ) ខែបានទេកាលណាអនីតិជននោះមានអាយុតិចជាង ១៦ (ដប់ប្រាំមួយ) ឆ្នាំ។

- ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី៤ (បួន) ខែទេកាលណាអនីតិជនមានអាយុចាប់ពី១៦ (ដប់ប្រាំមួយ) ឆ្នាំដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ។

[94] មាត្រា ២១០, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[95] គម្រូនៃដីកាបង្គាប់ឲ្យពន្យារពេលឃុំខ្លួនបណ្តោះអាសន្ន មានកំណត់ក្នុងឧបសម្ព័ន្ធទី២០

[96] មាត្រា ២១៣, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[97] មាត្រា ២១៤, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

ចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នខាងលើ មិនត្រូវលើសពីពាក់កណ្តាលអប្បបរមានៃទោសដែលច្បាប់បានកំណត់សម្រាប់អនីតិជនឡើយ។

**ឃ. ការធានាជនត្រូវចោទឲ្យនៅក្រៅឃុំ**

ចៅក្រមស៊ើបសួរមានសិទ្ធិអំណាចយ៉ាងពេញលេញក្នុងការសម្រេចចិត្តបង្គាប់ឲ្យដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំបានគ្រប់ពេលវេលានៅក្នុងដំណាក់កាលស៊ើបសួរ។[98] ការដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំ អាចតាមរយៈបណ្តឹងរបស់ព្រះរាជអាជ្ញារបស់ជនត្រូវចោទ ឬតាមគំនិតរបស់ចៅក្រមស៊ើបសួរផ្ទាល់។ ជាទូទៅការចេញដីកាសម្រេចធានាជនត្រូវចោទឲ្យនៅក្រៅឃុំ មិនចាំបាច់តម្រូវឲ្យចៅក្រមស៊ើបសួរបញ្ជាក់ពីមូលហេតុនោះទេ។ ប៉ុន្តែតាមរយៈការអនុវត្តជាក់ស្តែងចៅក្រមស៊ើបសួរចេញដីកាសម្រេចមិនធ្វើការឃុំខ្លួនជនណាម្នាក់គឺដោយសារតែមិនមានមូលហេតុចាំបាច់នៃការឃុំខ្លួនបណ្តោះអាសន្ន ដូចមានចែងក្នុងមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ នៅពេលចៅក្រមស៊ើបសួរសម្រេចចេញដីកាធានាជនត្រូវចោទឲ្យនៅក្រៅឃុំ ចៅក្រមស៊ើបសួរត្រូវបំពេញនិទ្ទេសដែលត្រូវចុះក្នុងដីកាសម្រេចដូចតទៅ៖

- ឈ្មោះរបស់ចៅក្រមស៊ើបសួរ
- ឈ្មោះក្រឡាបញ្ជី
- លេខ ថ្ងៃ ខែ ឆ្នាំ សំណុំរឿង
- អត្តសញ្ញាណរបស់ជនត្រូវចោទ
- ប្រភេទនៃបទល្មើសដែលបានចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស

ដីកានេះ ត្រូវចុះលេខរៀង កាលបរិច្ឆេទ ហត្ថលេខារបស់ចៅក្រមស៊ើបសួរ និងក្រឡាបញ្ជី និងមានបោះត្រាផង។[99]

ការដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំតាមបណ្តឹងរបស់ជនត្រូវចោទ។[100] ចំពោះពាក្យសុំឲ្យដោះលែងនៅក្រៅឃុំដែលធ្វើឡើងដោយជនត្រូវចោទ គឺចៅក្រមស៊ើបសួរត្រូវបញ្ជូនពាក្យសុំនោះភ្លាមទៅកាន់ព្រះរាជអាជ្ញាដើម្បីផ្តល់យោបល់ និងបញ្ជូនសំណុំរឿងទៅកាន់ព្រះរាជអាជ្ញាធ្វើការពិនិត្យ។ ព្រះរាជអាជ្ញាត្រូវធ្វើការផ្តល់យោបល់ក្នុងរយៈពេលយ៉ាងឆាប់រហ័សបំផុត។ ហើយចៅក្រមស៊ើបសួរត្រូវសម្រេចយ៉ាងយូរបំផុតរយៈពេល ៥ (ប្រាំ) ថ្ងៃបន្ទាប់ពីមានការបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។ ប៉ុន្តែប្រសិនបើពាក្យសុំដោះលែងនៅក្រៅឃុំនេះជាពាក្យសុំដែលធ្វើឡើងសាជាថ្មីទៅកាន់ចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរក្នុងរយៈពេល ១ (មួយ) ខែបន្ទាប់ពីមាន

---

[98] មាត្រា ២១៥, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[99] គម្រូនៃដីកាសម្រេចដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំ មានកំណត់ក្នុងឧបសម្ព័ន្ធទី២១

[100] មាត្រា ២១៧, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

សេចក្ដីបដិសេធពាក្យសុំលើកមុនចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរត្រូវសម្រេចលើពាក្យសុំជាថ្មីក្នុងរយៈក្នុងរយៈពេល៥ (ប្រាំ) ថ្ងៃបន្ទាប់ពីបានទទួលពាក្យសុំ។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល៥ (ប្រាំ) ថ្ងៃទេជនត្រូវចោទអាចធ្វើការដាក់ពាក្យសុំទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។

ការដោះលែងឲ្យនៅក្រៅឃុំតាមបណ្ដឹងព្រះរាជអាជ្ញា។[101] ចំពោះព្រះរាជអាជ្ញាវិញ គឺព្រះរាជអាជ្ញាក៏អាចសុំឲ្យចៅក្រមស៊ើបសួរដោះលែងជនត្រូវចោទបានគ្រប់ពេលវេលាផងដែរតាមរយៈបណ្ដឹងសុំដោះលែងឲ្យនៅក្រៅឃុំ។ ក្រោយពេលទទួលបានពាក្យបណ្ដឹងសុំដោះលែងឲ្យនៅក្រៅឃុំ ចៅក្រមត្រូវសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃទេព្រះរាជអាជ្ញាអាចប្ដឹងសុំតាមរយៈពាក្យសុំទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។

ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ជនត្រូវចោទត្រូវបានរក្សាទុកក្នុងពន្ធនាគាររហូតដល់ផុតរយៈពេលសម្រាប់ប្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា លើកលែងតែព្រះរាជអាជ្ញាយល់ព្រមឲ្យដោះលែងជនត្រូវចោទនោះភ្លាមតាមរយៈលាយលក្ខណ៍អក្សរ។ ក្នុងករណីមានបណ្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាអំពីដីកាដោះលែងឲ្យនៅក្រៅឃុំ ជនត្រូវចោទដែលនៅជាប់ឃុំត្រូវរក្សានៅក្នុងពន្ធនាគាររហូតទាល់តែសភាស៊ើបសួរបានសម្រេចអំពីបណ្ដឹងឧទ្ធរណ៍។ ប៉ុន្តែការអនុវត្តជាក់ស្ដែង កាលណាជនត្រូវចោទបានបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ នោះចៅក្រមស៊ើបសួរនឹងសម្រេចថាឃុំខ្លួន ឬមិនឃុំខ្លួន។ ករណីដែលចៅក្រមស៊ើបសួរចេញដីកាសម្រេចមិនឃុំខ្លួនមានន័យថាចៅក្រមស៊ើបសួរធានាជនត្រូវចោទឲ្យរស់នៅក្រៅឃុំ។ ដីកានេះនិងត្រូវយកទៅប្រតិបត្តិផ្ទាល់ដោយមន្ត្រីនគរបាលយុត្តិធម៌ដែលបានឃាត់ខ្លួនបុគ្គលត្រូវចោទ។ នៅក្នុងពេលទទួលដីកានេះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវដោះលែងជនត្រូវចោទឲ្យត្រឡប់ទៅលំនៅដ្ឋានវិញភ្លាម ដោយមិនអាចបន្តការឃាត់ខ្លួនជនត្រូវចោទទៀតនោះទេ ទោះបីជាបណ្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ទៅចំពោះមុខសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ក៏ដោយ។

### កថាខណ្ឌទី២៖ ការត្រួតពិនិត្យតាមផ្លូវតុលាការ

ចៅក្រមស៊ើបសួរអាចធ្វើការសម្រេចដោយចេញដីកាសម្រេចដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការក្នុងលក្ខខណ្ឌដែលជនត្រូវចោទត្រូវបានចោទប្រកាន់ពីបទល្មើសដែលត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារ និងករណីជនត្រូវចោទត្រូវបានចៅក្រមស៊ើបសួរសម្រេចមិនឃុំខ្លួន។ វិធានការនេះគឺអនុញ្ញាតឲ្យជនត្រូវចោទមានសេរីភាពរស់នៅក្រៅឃុំប៉ុន្តែត្រូវបំពេញកាតព្វកិច្ចមួយចំនួនដែលតុលាការបានកំណត់ឲ្យបំពេញ។

[101] មាត្រា ២១៦, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

### ក. លក្ខខណ្ឌសម្រេចដាក់ឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

ចៅក្រមស៊ើបសួរ អាចសម្រេចដាក់ជនត្រូវចោទរូបណាឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដោយតាមរយៈគំនិតផ្ទាល់របស់ខ្លួន ឬតាមរយៈដីកាសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា។

ចៅក្រមស៊ើបសួរ អាចសម្រេចដាក់ជនត្រូវចោទណាម្នាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានក្នុងលក្ខខណ្ឌដែលជនត្រូវចោទត្រូវបានចោទប្រកាន់អំពីបទល្មើស ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ និងករណីដែលជននេះត្រូវបានចៅក្រមស៊ើបសួរសម្រេចមិនឲ្យនៅក្រៅឃុំ។ បានន័យថាចៅក្រមស៊ើបសួរមិនអាចជ្រើសរើស យកវិធានការដាក់ឲ្យជនត្រូវចោទស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានឡើយក្នុងករណីបណ្តឹងអាជ្ញាមិនត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ដែលត្រូវបានកំណត់ផ្តន្ទាទោសដាក់ពន្ធនាគារ។ លើសពីនេះ ចៅក្រមស៊ើបសួរក៏មិនអាចចេញដីកាសម្រេចដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការចំពោះអនីតិជនដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ។[102]

នៅក្នុងដីកានេះចៅក្រមស៊ើបសួរត្រូវចុះពីនិទ្ទេស និងបញ្ជាក់ពីកាតព្វកិច្ចជាចាំបាច់ហើយច្បាស់លាស់ដើម្បីឲ្យជនត្រូវចោទអនុវត្ត។ ចំពោះនិទ្ទេសដែលចៅក្រមត្រូវចុះមុនពេលសម្រេចដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការរួមមានៈ

- ឈ្មោះចៅក្រមស៊ើបសួរ
- ឈ្មោះក្រឡាបញ្ជី
- លេខ ថ្ងៃ ខែ ឆ្នាំ សំណុំរឿង
- លេខ ថ្ងៃ ខែ ឆ្នាំ នៃដីកាបញ្ជូនរឿងឲ្យស៊ើបសួរ
- លេខ ថ្ងៃ ខែ ឆ្នាំ នៃដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន
- អត្តសញ្ញាណរបស់ជនត្រូវចោទ
- សំអាងហេតុ
- ប្រភេទនៃបទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ស្តីពីការកំណត់ និងបង្ក្រាបបទល្មើស
- ផ្នែកនៃសេចក្តីសម្រេចរបស់ដីកា

ក្នុងដីកានេះ ត្រូវបញ្ជាក់អំពីចំណាត់ការបន្តលើការឃុំខ្លួនជនត្រូវចោទប្រសិនបើជនត្រូវចោទបានគេចវេសមិនគោរពកាតព្វកិច្ចដែលបានកំណត់ក្នុងសេចក្តីសម្រេចនៃដីកា។

[102] មាត្រា ២២៤, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

ចំពោះកាតព្វកិច្ចដែលចៅក្រមស៊ើបសួរ មានអនុភាពបង្គាប់ឲ្យជនត្រូវចោទដែលស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការគឺ៖

- មិនត្រូវចេញក្រៅពីព្រំដែនដីកំណត់ដោយចៅក្រមស៊ើបសួរ។

- មិនត្រូវផ្លាស់ប្តូរទីលំនៅឋានដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។

- តមិនត្រូវទៅកាន់ទីកន្លែងខ្លះដែលកំណត់ដោយចៅក្រមស៊ើបសួរ។

- ត្រូវចូលបង្ហាញខ្លួនតាមការកំណត់នៅអង្គភាពនគរបាល ឬកងរាជអាវុធហត្ថដែលចាត់តាំងដោយចៅក្រមស៊ើបសួរ។

- ប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីគ្រប់ឯកសារបញ្ជាក់អំពីអត្តសញ្ញាណ។

- មិនអនុញ្ញាតឲ្យបើកបររថយន្ត។

- មិនត្រូវទទួល ឬជួបជាមួយបុគ្គលដែលចង្អុលបង្ហាញដោយចៅក្រមស៊ើបសួរ។

- ដាក់ប្រាក់ធានាដែលចំនួនប្រាក់ធានា និងថិរវេលាបង់ប្រាក់នេះត្រូវកំណត់ដោយចៅក្រមស៊ើបសួរតាមការផ្អែកលើធនធានរបស់ជនត្រូវចោទ។

- មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ។ ត្រូវប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីនូវអាវុធដែលជនត្រូវចោទកាន់កាប់។

- មិនត្រូវធ្វើសកម្មភាពវិជ្ជាជីវៈខ្លះ។ ករណីចៅក្រមស៊ើបសួរមិនអាចហាមឃាត់ការអនុញ្ញាតនូវអាណត្តិបោះឆ្នោតសកម្មភាពសហជីពបានទេ។[103]

ដីកានេះត្រូវចុះកាលបរិច្ឆេទ ចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងក្រឡាបញ្ជី និងបោះត្រាផង។

### ខ. នីតិវិធីនៃការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

បន្ទាប់ពីមន្ត្រីនគរបាលយុត្តិធម៌បានធ្វើការបញ្ជូនជនសង្ស័យមកកាន់ចៅក្រមស៊ើបសួរដើម្បីធ្វើការស៊ើបសួរស្វែងរកការពិត។ ចៅក្រមស៊ើបសួរត្រូវធ្វើសម្រេចចិត្តថាគួរឃុំខ្លួន ឬមិនឃុំខ្លួន? ប្រសិនបើចៅក្រមសម្រេចមិនឃុំខ្លួន នោះចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការដែលជាវិធានជំនួសឲ្យការឃុំខ្លួនបណ្តោះអាសន្ន ហើយជាវិធានការមួយនេះមិនសូវជាបិទសិទ្ធិសេរីភាពរបស់ជនត្រូវចោទទាំងស្រុងនោះទេ ប្រសិនបើចៅក្រមយល់ឃើញថាក្នុងករណីនេះមិនចាំបាច់ត្រូវធ្វើការឃុំខ្លួនបណ្តោះអាសន្ន។

[103] មាត្រា ២២៣, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

កាលណាចៅក្រមស៊ើបសួរ យល់ឃើញថាត្រូវចេញដីកាសម្រេចដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការត្រូវជូនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។

ករណីប្រសិនបើ ចៅក្រមស៊ើបសួរបានទទួលបណ្ដឹងរបស់ព្រះរាជអាជ្ញាសម្រេចសុំដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការប៉ុន្តែមិនសម្រេចតាមការសុំនេះទេ ចៅក្រមស៊ើបសួរត្រូវចេញដីកាបដិសេធក្នុងរយៈពេល៥ (ប្រាំ)ថ្ងៃ។ ដីកាសម្រេចនេះ ត្រូវជូនដំណឹងក្នុងរយៈពេលខ្លីបំផុតទៅកាន់ព្រះរាជអាជ្ញា។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃទេ ព្រះរាជអាជ្ញាអាចធ្វើការដាក់ពាក្យប្ដឹងទៅកាន់សភាស៊ើបសួរដើម្បីសម្រេចជំនួស។[104]

នៅពេលចេញដីកានេះ ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យជនត្រូវចោទអនុវត្តកាតព្វកិច្ចទាំងអស់ដែលចៅក្រមបានដាក់ឲ្យ ហើយក្រឡាបញ្ជីត្រូវសរសេរបង្កាន់ដៃទទួលសំណុំឯកសារទាំងនោះ ដែលបានកំណត់ដោយចៅក្រមស៊ើបសួរដោយមានហត្ថលេខារួមដោយប្រធានតុលាការ ព្រះរាជអាជ្ញា និងក្រឡាបញ្ជី។

ក្នុងករណីជនត្រូវចោទគេចវេសពីកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ ចៅក្រមស៊ើបសួរអាចសម្រេចកែប្រែវិធានការខាងលើមកជំនួសដោយវិធានការឃុំខ្លួនបណ្ដោះអាសន្នវិញបាន។

កាលណាចៅក្រមស៊ើបសួរ សម្រេចថានឹងឃុំខ្លួនបណ្ដោះអាសន្នដោយមានមូលហេតុខាងលើនេះ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងដល់ជនត្រូវចោទ និងទទួលការកត់សំគាល់របស់ជននេះ។ ប្រសិនបើជនត្រូវចោទមានមេធាវីអមនោះមេធាវីត្រូវជូនមធ្យោបាយការពារកូនក្ដីរបស់ខ្លួន។

ការសម្រេចរបស់ចៅក្រមស៊ើបសួរអាចកែប្រែខ្លឹមសារនៃកាតព្វកិច្ច ឬអាចលុបចោល ឬបន្ថែមកាតព្វកិច្ចថ្មីបានគ្រប់ពេលវេលា។ ហើយចៅក្រមស៊ើបសួរក៏អាចបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការបានដែរប្រសិនបើយល់ឃើញថាជាការគួរ។

### គ. ការអនុវត្តនីតិវិធីដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

យោងតាមសារាចរ ០១ កយ.សរ/១៤ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤ ស្ដីអំពីការអនុវត្តបទប្បញ្ញត្តិដាក់ជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានបញ្ជាក់ដូចខាងក្រោម៖

ចៅក្រមស៊ើបសួរមានតួនាទីធានាឲ្យបាននូវការអនុវត្តតាមគោលការណ៍នេះ ដោយយកចិត្តទុកដាក់ឲ្យបានហ្មត់ចត់អំពីកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់ជនត្រូវចោទឲ្យបានសមស្រប និងឲ្យមានតុល្យភាពទៅនឹងស្ថានភាពសង្គមក្នុងការសម្រេចមិនឃុំខ្លួនជនត្រូវចោទ ហើយដាក់ជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។[105]

[104] មាត្រា ២២៦, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[105] គម្រូនៃដីកាសម្រេចដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ មានកំណត់ក្នុងឧបសម្ព័ន្ធទី២២

ចៅក្រមស៊ើបសួរ ត្រូវតែគិតអំពីវិធានការនៃការត្រួតពិនិត្យតាមផ្លូវតុលាការ និងឃ្លាំមើលដើម្បីធានាថាជនត្រូវចោទនឹងអនុវត្តកាតព្វកិច្ចដូចមានចែងក្នុងមាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានត្រឹមត្រូវ។ ករណីនេះចៅក្រមស៊ើបសួរគប្បីចាត់តាំងបុគ្គលណាម្នាក់ដែលមានសមត្ថភាពអាចជួយតាមឃ្លាំមើល និងធ្វើរបាយការណ៍ជូនព្រះរាជអាជ្ញាតាមការកំណត់។

ក្នុងករណីចាំបាច់ដើម្បីធានាដល់ការឃ្លាំមើលជនត្រូវចោទ ចៅក្រមស៊ើបសួរគួរតែគប្បីដាក់កាតព្វកិច្ចឲ្យជនត្រូវចោទចូលបង្ហាញខ្លួនតាមការកំណត់នៅក្នុងអង្គភាពនគរបាល ឬកងរាជអាវុធហត្ថដែលស្ថិតនៅជិតលំនៅដ្ឋានស្នាក់នៅជាក់លាក់ណាមួយរបស់ជនត្រូវចោទ។

ចៅក្រមស៊ើបសួរ ត្រូវផ្តល់ដីកាសម្រេចដាក់ជនត្រូវចោទនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការឲ្យយកដីកាសម្រេចនេះទៅបង្ហាញដល់ប្រធានអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ឬបុគ្គលដែលត្រូវបានចាត់តាំងក្នុងមូលដ្ឋានដែលខ្លួនរស់នៅ។

ចៅក្រមស៊ើបសួរត្រូវពិចារណាលើរបាយការណ៍ ឬព័ត៌មានរបស់អង្គភាព ឬបុគ្គលដែលត្រូវបានចាត់តាំងពាក់ព័ន្ធនឹងជនត្រូវចោទដើម្បីជាមូលដ្ឋានក្នុងការសម្រេចតាមបញ្ញត្តិនៃ មាត្រា២២៧ មាត្រា២២៨ មាត្រា២២៩ និងមាត្រា២៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

### ឃ. តួនាទីចៅក្រមស៊ើបសួរក្នុងដំណាក់កាលត្រួតពិនិត្យតាមផ្លូវតុលាការ

នៅក្នុងដំណាក់កាលការដាក់ឲ្យជនត្រូវចោទ ឬជនដែលពាក់ព័ន្ធស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ចៅក្រមស៊ើបសួរអាចកែប្រែខ្លឹមសារនៃកាតព្វកិច្ចអាចលុបចោល ឬបញ្ចូលកាតព្វកិច្ចថ្មីបានគ្រប់ពេលវេលា ហើយក៏អាចបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការបានដែរ។[106] ក្នុងករណីនេះចៅក្រមស៊ើបសួរសម្រេចតាមដីកាដែលត្រូវជូនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។

ជាការពិតណាស់ ក្នុងអំឡុងពេលដាក់ជនត្រូវចោទឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនោះចៅក្រមស៊ើបសួរយល់ឃើញថា ជនត្រូវចោទគោរពកាតព្វកិច្ចបានត្រឹមត្រូវមានការកែប្រែខ្លួនក្លាយជាពលរដ្ឋល្អវិញនោះ គឺចៅក្រមចៅស៊ើបសួរអាចសម្រេចការលុបចោល ឬដកកាតព្វកិច្ចដែលដាក់លើជនត្រូវចោទបាន។ ប៉ុន្តែក៏មានករណីផ្សេងទៀតដែលចៅក្រមស៊ើបសួរយល់ឃើញថាមានកាតព្វកិច្ចខ្លះ ចៅក្រមមិនបានហាមឃាត់ហើយចៅក្រមស៊ើបសួរចង់បន្ថែមកាតព្វកិច្ចនោះដើម្បីឲ្យជនត្រូវបំពេញ ដូច្នេះជនត្រូវចោទត្រូវតែអនុវត្តតាមការសម្រេចរបស់ចៅក្រមស៊ើបសួរដាច់ខាត។

---

[106] មាត្រា ២២៧, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

ក្នុងករណីព្រះរាជអាជ្ញាសុំឲ្យលើកលែង ឬកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការ។ ចៅក្រមស៊ើបសួរត្រូវតែសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ។ ដីកាសម្រេចនេះ ត្រូវជូនដំណឹងរយៈពេលខ្លីបំផុតជូនព្រះរាជអាជ្ញា។ ប៉ុន្តែប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃទេ ព្រះរាជអាជ្ញាអាចធ្វើការដាក់ពាក្យដើម្បីឲ្យសភាស៊ើបសួរសម្រេចជំនួសចៅក្រមស៊ើបសួរ។ គួរបញ្ជាក់ផងដែរថារាល់ដីកាសម្រេចមិនព្រមធ្វើតាមពាក្យបណ្ដឹងសុំរបស់ព្រះរាជអាជ្ញាត្រូវតែមានសំអាងហេតុ។[107]

ចំពោះជនត្រូវចោទវិញក៏អាចស្នើសុំតាមរយៈការធ្វើពាក្យសុំឲ្យលើកលែង ឬកែប្រែការដាក់ឲ្យត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា។ ចៅក្រមស៊ើបសួរត្រូវបញ្ជូនរឿងនេះភ្លាមទៅកាន់ព្រះរាជអាជ្ញាដើម្បីសុំយោបល់ និងបញ្ជូនសំណុំរឿងឲ្យព្រះរាជអាជ្ញាពិនិត្យ។ ចៅក្រមស៊ើបសួរសម្រេចដីកានេះយ៉ាងយូរបំផុត ៥ (ប្រាំ) ថ្ងៃគិតពីថ្ងៃបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។ ប៉ុន្តែប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃបានទេ ជនត្រូវចោទអាចធ្វើការដាក់ពាក្យដើម្បីឲ្យសភាស៊ើបសួរសម្រេចជំនួសចៅក្រមស៊ើបសួរ។[108] ដីកាសម្រេចមិនព្រមធ្វើតាមពាក្យបណ្ដឹងរបស់ជនត្រូវចោទត្រូវតែមានសំអាងហេតុ។

ប្រសិនបើជនត្រូវចោទគេចវេសដោយចេតនាពីកាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការ ចៅក្រមស៊ើបសួរអាចសម្រេចឃុំខ្លួនបណ្ដោះអាសន្នបានទោះបីទោសជាប់ពន្ធនាគារដែលរងនោះមានថិរវេលាប៉ុន្មានក៏ដោយ។[109] ហើយទោះបីជនត្រូវចោទត្រូវបានឃុំខ្លួនបណ្ដោះអាសន្នអស់រយៈពេលអតិបរិមាដែលមានចែងក្នុងមាត្រា ២០៨ មាត្រា២០៩ មាត្រា២១០ មាត្រា២១៣ មាត្រា២០១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌក៏ដោយ។ ករណីនេះចៅក្រមស៊ើបសួរសម្រេចថានឹងធ្វើការឃុំខ្លួនបណ្ដោះអាសន្នដោយមូលហេតុខាងលើ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងទៅជនត្រូវចោទ។ ប្រសិនបើជនត្រូវចោទមានមេធាវីអមនោះ មេធាវីត្រូវរកមធ្យោបាយការពារកូនក្ដីរបស់ខ្លួន។ ចំពោះការឃុំខ្លួនបណ្ដោះអាសន្នត្រូវតែមានសំអាងហេតុ។ ដីកាសម្រេចនេះត្រូវជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។ ការឃុំខ្លួនបណ្ដោះអាសន្នក្នុងករណីនេះ គឺមានថិរវេលាមិនលើសពី៤ (បួន) ខែចំពោះនីតិជន និង២ (ពីរ) ខែចំពោះនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ទៅដល់ ១៨ (ដប់ប្រាំ បី) ឆ្នាំ។

[107] មាត្រា ២២៨, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។
[108] មាត្រា ២២៩, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។
[109] មាត្រា ២៣០, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

# ជំពូកទី៣
# ការបើកការស៊ើបសួរ

# ជំពូកទី៣
# ការបិទការស៊ើបសួរ

ប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថា ដំណាក់កាលស្រាវជ្រាវរបស់ខ្លួនមានលក្ខណៈគ្រប់គ្រាន់សមស្របសម្រាប់បញ្ចប់នោះ ចៅក្រមស៊ើបសួរនឹងធ្វើការបិទការស៊ើបសួរដើម្បីបិទសំណុំរឿងក្រោមកិច្ចមួយហៅថាដីកាដំណោះស្រាយ។ តាមរយៈដីកានេះជាដីកាបញ្ជូនទៅពិនិត្យ ឬដីកាលើកលែងការចោទប្រកាន់។ ចំពោះដីកាលើកលែងការចោទប្រកាន់តុលាការត្រូវជូនដំណឹងជូនគូក្តីដើមរយៈពេល ២៤ (ម្ភៃបួន) ម៉ោងមុនលើកលែងការចោទប្រកាន់។

## ផ្នែកទី១៖ នីតិវិធីនៃការបិទការស៊ើបសួរ

ចំពោះនីតិវិធីនៃការបិទការស៊ើបសួរ ត្រូវធ្វើឡើងដោយមានទំនាក់ទំនងរវាងព្រះរាជអាជ្ញាចៅក្រមស៊ើបសួរជនត្រូវចោទដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីព្រមទាំងត្រូវឆ្លងកាត់ការបញ្ជូនសំណុំរឿងទៅវិញទៅមកដើម្បីបញ្ជាក់ពីការស្រាវជ្រាវកន្លងមកប្រកបដោយភាពយុត្តិធម៌ និងសុច្ចរិត។

គួរឲ្យកត់សំគាល់នីតិវិធីនៃការជូនព័ត៌មានដោយចៅក្រមស៊ើបសួរ និងការបញ្ជូនសំណុំរឿងដោយព្រះរាជអាជ្ញាត្រូវបានយកមកអនុវត្តដើម្បីធ្វើការបិទសំណុំរឿងជម្រះក្តី។

### កថាខណ្ឌទី១៖ ការជូនព័ត៌មានដោយចៅក្រមស៊ើបសួរ

កាលណាបើចៅក្រមស៊ើបសួរយល់ឃើញថាការស៊ើបសួរត្រូវបញ្ចប់ នោះចៅក្រមស៊ើបសួរមានតួនាទីបញ្ជូនព័ត៌មាននេះដល់ព្រះរាជអាជ្ញាជនត្រូវចោទដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីឲ្យបានដឹង។[110] ការជូនដំណឹងនេះ គឺដើម្បីឲ្យព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីជ្រាបជាដំណឹងថាការស៊ើបសួររបស់ខ្លួនត្រូវបានបញ្ចប់សព្វគ្រប់។

ជាក់ស្តែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ពុំបានបញ្ជាក់អំពីបែបបទនៃការផ្តល់ព័ត៌មានទាំងនេះទេ។ ករណីនេះជាទូទៅចៅក្រមស៊ើបសួរត្រូវតម្រូវឲ្យមានលិខិតជូនដំណឹងដោយភ្ជាប់ជាមួយនឹងការចុះលេខក្នុងសំណុំរឿង។[111]

រយៈពេល២ (ពីរ) ថ្ងៃក្រោយមកចៅក្រមស៊ើបសួរនឹងបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីពិនិត្យ។

### កថាខណ្ឌទី២៖ ការបញ្ជូនសំណុំរឿងដោយព្រះរាជអាជ្ញា

ក្រោយពេលព្រះរាជអាជ្ញាទទួលបានសំណុំរឿងពីចៅក្រមស៊ើបសួរហើយ ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថាមានកត្តាចាំបាច់ត្រូវធ្វើកិច្ចស៊ើបសួរថ្មីទៀត ព្រះរាជអាជ្ញាមានសិទ្ធិស្នើសុំឲ្យចៅក្រមស៊ើបសួរធ្វើកិច្ច

[110] មាត្រា ២៤៦, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

[111] គម្រូនៃលិខិតជូនព័ត៌មានស្តីពីការបញ្ចប់ការស៊ើបសួរ មានកំណត់ក្នុងឧបសម្ព័ន្ធទី២៣

ស៊ើបសួរបន្ថែមដើម្បីបំពេញការស៊ើបសួរដែលធ្វើរួចទៅតាមមាត្រា ១៣២ (ការស្នើសុំឲ្យបំពេញកិច្ចដោយព្រះរាជអាជ្ញា) នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។[112]

ក្នុងករណីដែលចៅក្រមស៊ើបសួរ មិនព្រមធ្វើតាមសេចក្ដីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាទេចៅក្រមស៊ើបសួរត្រូវចេញដីកាបដិសេធក្នុងចិរវេលា ១៥ (ដប់ប្រាំ) ថ្ងៃបន្ទាប់ពីខ្លួនបានទទួល។[113] ហើយដីកាដែលចៅក្រមស៊ើបសួរសម្រេចចេញត្រូវមានសំអាងហេតុ និងត្រូវជូនដំណឹងជាបន្ទាន់ទៅកាន់ព្រះរាជអាជ្ញា។ ប៉ុន្តែក្នុងករណីដែលចៅក្រមស៊ើបសួរមិនបានធ្វើការសម្រេចនៅក្នុងចិរវេលា ១៥ (ដប់ប្រាំ) ថ្ងៃទេ ព្រះរាជអាជ្ញាមានសិទ្ធិប្ដឹងទៅសភាស៊ើបសួរសម្រេចជំនួស។

ក្រោយពីបានពិនិត្យសំណុំរឿងដែលចៅក្រមស៊ើបសួរបានបញ្ជូនមកចប់សព្វគ្រប់ ព្រះរាជអាជ្ញាមានតួនាទីមួយគឺ ត្រូវបង្វិលសំណុំរឿងទៅកាន់ចៅក្រមស៊ើបសួរវិញ ដោយមានដីកាសន្និដ្ឋានជាស្ថាពរភ្ជាប់ជាមួយ។ ចំពោះការពិនិត្យសំណុំរឿងរបស់ជនត្រូវចោទនៅក្នុងឃុំ គឺមានរយៈពេល ១៥ (ដប់ថ្ងៃ) និងរយៈពេល ១ (មួយ) ខែសម្រាប់ជនត្រូវចោទនៅក្រៅឃុំ។ ចិរវេលានេះត្រូវគិតពីថ្ងៃដែលព្រះរាជអាជ្ញាបានទទួលសំណុំរឿង។ ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញដូចចៅក្រមស៊ើបសួរដែរ ការស៊ើបសួរត្រូវបានបញ្ចប់ព្រះរាជអាជ្ញាត្រូវចេញដីកាជាស្ថាពរជាលាយលក្ខណ៍អក្សរដោយមានសំអាងហេតុដើម្បីបញ្ជូនខ្លួនជនត្រូវចោទទៅកាន់តុលាការជំនុំជម្រះ ឬក៏លើកលែងចោទប្រកាន់។

### ផ្នែកទី២៖ ប្រភេទនៃដីកាដំណោះស្រាយ

ពេលដែលចៅក្រមស៊ើបសួរយល់ឃើញថាការស៊ើបសួររបស់ខ្លួនត្រូវបានបញ្ចប់សព្វគ្រប់ នោះចៅក្រមស៊ើបសួរនឹងចេញដីកាដំណោះស្រាយ។ នៅក្នុងដីកាដំណោះស្រាយ[114]ចៅក្រមស៊ើបសួរត្រូវតែសម្រេចអំពីការប្រគល់សងទៅឲ្យម្ចាស់ដើមនូវរាល់វត្ថុដែលបានចាប់យកទៅកាន់ម្ចាស់ដើមវិញ។[115]

ដីកាដំណោះស្រាយបញ្ចប់ការឃុំខ្លួនបណ្ដោះអាសន្ន ក្នុងករណីនេះការដោះលែងជនត្រូវចោទដែលជាប់ឃុំឲ្យមានសេរីភាពត្រូវយកមកអនុវត្ត។ ប៉ុន្តែចំពោះសេចក្ដីសម្រេចដោយឡែក ទាក់ទងនឹងការឃុំខ្លួនបណ្ដោះអាសន្ននឹងត្រូវត្រួតពិនិត្យតាមផ្លូវតុលាការនៃដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ គឺអាចរក្សាជនត្រូវចោទឲ្យជាប់ឃុំខ្លួនបណ្ដោះអាសន្នរហូតដល់ពេលចូលបង្ហាញខ្លួននៅមុខតុលាការ។ នៅក្នុងដីកានេះចៅក្រមស៊ើបសួរត្រូវយោងតាមលក្ខខណ្ឌដោយបញ្ជាក់ពីមូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្នច្បាស់លាស់។

---

[112] គម្រូនៃដីកាចាត់ឲ្យបំពេញកិច្ចស៊ើបសួរបន្ថែម មានកំណត់ក្នុងឧបសម្ព័ន្ធទី២៤

[113] គម្រូនៃដីកាសម្រេចបដិសេធការស្នើសុំឲ្យបំពេញកិច្ច មានកំណត់ក្នុងឧបសម្ព័ន្ធទី២៥

[114] គម្រូនៃដីកាដំណោះស្រាយ មានកំណត់ក្នុងឧបសម្ព័ន្ធទី២៦

[115] គម្រូនៃដីកាសម្រេចប្រគល់វត្ថុដែលចាប់ឲ្យទៅម្ចាស់ដើមវិញ មានកំណត់ក្នុងឧបសម្ព័ន្ធទី២៧

ហើយសេចក្តីសម្រេចទុកជនត្រូវចោទក្នុងឃុំបណ្តោះអាសន្ននឹងលែងមានអនុភាពក្នុងរយៈពេល៤ (បួន) ខែ។ ប្រសិនបើជនត្រូវចោទមិនបានចូលបង្ហាញខ្លួននៅមុខតុលាការក្នុងរយៈពេល៤ (បួន) ខែនោះទេមានន័យថាជនត្រូវចោទបានដោះលែងឲ្យនៅក្រៅឃុំដោយឯកឯង។ ម្យ៉ាងវិញទៀតតាមរយៈដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរមានសិទ្ធិរក្សាជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ រហូតដល់ពេលចូលបង្ហាញខ្លួននៅចំពោះមុខតុលាការ។[116]

ការចេញដីកាដំណោះស្រាយ គឺជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរផ្តាច់មុខ ក្រោយពេលដែលចៅក្រមស៊ើបសួរទទួលបានសេចក្តីសម្រេចជាស្ថាពរពីអយ្យការ នោះចៅក្រមស៊ើបសួរត្រូវធ្វើចំណាត់ការលើសំណុំរឿងដោយធ្វើសេចក្តីសន្និដ្ឋានតាមរយៈដោយដីកានេះអាចជាដីកាបញ្ជូនទៅជំនុំជម្រះ[117] ឬដីកាលើកលែងការចោទប្រកាន់។[118]

**កថាខណ្ឌទី១៖ ដីកាបញ្ជូនរឿងទៅពិនិត្យរឿងទាំងមូល**

នៅពេលចៅក្រមស៊ើបសួរយល់ឃើញថា ជនត្រូវចោទមានពិរុទ្ធភាពគ្រប់គ្រាន់ស៊ីសង្វាក់នឹងអង្គហេតុក៏ដូចជាភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទដែលអំពើរបស់ជនត្រូវចោទបង្កបានជាបទល្មើសព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរបញ្ជូនសំណុំរឿង និងជនត្រូវចោទទៅជំនុំជម្រះ។

ករណីចៅក្រមស៊ើបសួរ សម្រេចចេញដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះចៅក្រមស៊ើបសួរបញ្ជូនសំណុំរឿង និងភស្តុតាងដែលមានទៅកាន់ប្រធានតុលាការដើម្បីកំណត់ពេលសវនាការជំនុំជម្រះ។[119] ចៅក្រមស៊ើបសួរអាចរក្សាជនត្រូវចោទឲ្យនៅក្រៅឃុំបណ្តោះអាសន្នរហូតដល់ពេលចូលបង្ហាញខ្លួននៅមុខតុលាការ។ នៅក្នុងដីកាបញ្ជូនទៅពិនិត្យរឿងទាំងមូលត្រូវរៀបរាប់អំពីអំពើដែលត្រូវចោទប្រកាន់ និងឈ្មោះបទល្មើសតាមច្បាប់។

**កថាខណ្ឌទី២៖ ដីកាលើកលែងការចោទប្រកាន់**

ប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថា អង្គហេតុដែលមាននៅក្នុងសំណុំរឿងមិនមែនជាបទល្មើសឧក្រិដ្ឋ ឬបទមជ្ឈិម ឬបទល្មើសលហុទេ ឬជនប្រព្រឹត្តបទល្មើសនៅតែគេមិនស្គាល់ ឬប្រសិនបើពុំមានបន្ទុកគ្រប់គ្រាន់ដែលបញ្ជាក់ថាជនត្រូវចោទមានពិរុទ្ធភាព នោះចៅក្រមស៊ើបសួរនឹងសម្រេចលើកលែងការចោទប្រកាន់។ ការលើកលែងការចោទប្រកាន់ត្រូវមានមូលហេតុច្បាស់លាស់ និងត្រូវជូនដំណឹងទៅភាគីទាំងអស់ដើម្បីឲ្យភាគី

---

116 មាត្រា ២៤៩, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

117 គម្រូនៃដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ មានកំណត់ក្នុងឧបសម្ព័ន្ធទី២៨

118 គម្រូនៃដីកាលើកលែងការចោទប្រកាន់ មានកំណត់ក្នុងឧបសម្ព័ន្ធទី២៩

119 មាត្រា ២៥០, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

ដែលមិនសុខចិត្តនឹងការសម្រេចនោះធ្វើការតវ៉ានៅសាលាឧទ្ធរណ៍។ លើសពីនេះទៅទៀត ចៅក្រមស៊ើបសួរអាច លើកលែងចោទប្រកាន់ក្នុងករណីបណ្តឹងអាជ្ញាផុតអាជ្ញាយុកាល និងមរណភាពនៃចារី។

សេចក្តីសម្រេចលើកលែងការចោទប្រកាន់មិនរលត់បណ្តឹងអាជ្ញាទេ ប្រសិនបើលើកលែងការចោទ ប្រកាន់មានហេតុផលមកពីអវត្តមាននៃបន្ទុកគ្រប់គ្រាន់ប្រឆាំងនឹងជនត្រូវចោទ ឬមកពីការមិនស្គាល់ចារី ដូចនេះ ពេលមានបន្ទុកថ្មីកើតឡើង គឺអនុញ្ញាតឲ្យបើកការស៊ើបសួរទៅលើអង្គហេតុនោះជាថ្មីម្តងទៀត។ ហេតុដូច្នេះដើម បណ្តឹងរដ្ឋប្បវេណីដែលមិនសុខចិត្តនឹងសេចក្តីសម្រេចលើកលែងការចោទប្រកាន់នេះ អាចធ្វើការប្តឹងឧទ្ធរណ៍ ចំពោះដីកានេះ។

# សេចក្តីសន្និដ្ឋាន

# និង

# អនុសាសន៍

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការស្រាវជ្រាវយ៉ាងលំអិតទាក់ទងនឹងប្រធានបទស្តីពី **តួនាទីរបស់ចៅក្រមស៊ើបសួរ** រួចមកពិតជាបានឆ្លុះបញ្ចាំងយ៉ាងច្បាស់ថាកិច្ចស៊ើបសួរត្រូវបានអនុវត្ត និងដឹកនាំផ្ទាល់ដោយចៅក្រមស៊ើបសួរដើម្បីប្រមូលភស្តុតាងទាំងអស់ដែលពាក់ព័ន្ធ ដែលបញ្ជាក់ពីការពិតនៃអង្គហេតុព្រហ្មទណ្ឌចាប់តាំងពីការចាប់ផ្តើមស្រាវជ្រាវហូតដល់ការបញ្ចប់កាស៊ើបសួរ។ ចំពោះបទឧក្រិដ្ឋ ការបើការស៊ើបសួរត្រូវធ្វើដោយខានពុំបាន ចំណែកឯបទមជ្ឈិមវិញការស៊ើបសួរអាចធ្វើក៏បាន មិនធ្វើក៏បាន។ ប៉ុន្តែរាល់ការចូលរួមស្រាវជ្រាវរឿងក្តីព្រហ្មទណ្ឌរបស់ចៅក្រមស៊ើបសួរ ក្នុងដំណាក់កាលស៊ើបសួរត្រូវតែរក្សាការសម្ងាត់។ នៅក្នុងដំណាក់កាលចៅក្រមស៊ើបសួរមានតួនាទីបើកការស៊ើបសួរដើម្បីស្វែងរកការពិតទាំងភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុកដើម្បីផ្តល់ភាពយុត្តិធម៌ដល់ជនល្មើស និងជនរងគ្រោះ។ ម្យ៉ាងវិញទៀតកិច្ចការស្រាវជ្រាវនេះមានដូចជាកិច្ចស្រាវជ្រាវចំពោះអង្គហេតុ និងកិច្ចស្រាវជ្រាវនឹងបុគ្គលិកលក្ខណៈរបស់ជនត្រូវចោទ។

ចំពោះដំណាក់កាលបើកការស៊ើបសួរ វិធីសាស្ត្រស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរដើម្បីស្វែងរកការពិតឲ្យបានច្បាស់លាស់ក្នុងនោះរួមមានដូចជា ការជូនដំណឹងអំពីការដាក់ឲ្យនៅក្រោមការត្រួតពិនិត្យ ការសួរចម្លើយជនត្រូវចោទ ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ការស្តាប់ចម្លើយសាក្សី ការឆែកឆេរ ការចាប់យកវត្ថុតាង ការធ្វើកុសលវិច័យ និងការស្តាប់ទូរស័ព្ទ។ ក្នុងនីតិវិធីស៊ើបសួរ ព្រះរាជអាជ្ញា ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី អាចធ្វើការស្នើសុំបំពេញកិច្ចដល់ចៅក្រមស៊ើបសួរណាមួយ ដែលយល់ឃើញថាមានប្រយោជន៍ដើម្បីបង្ហាញពីការពិត។ ប្រសិនបើក្នុងការបំពេញកិច្ចរបស់ខ្លួន មានមូលហេតុមួយចំនួនដែលជាហេតុបណ្តាលឲ្យចៅក្រមស៊ើបសួរមិនអាចបំពេញតួនាទីរបស់ខ្លួនបានដូចជាបញ្ហាជម្ងឺ ឬមានធុរៈចាំបាច់ផ្សេងៗ ការធ្វើដំណើរផ្លូវឆ្ងាយចៅក្រមស៊ើបសួរមានសិទ្ធិពេញលេញសម្រេចចេញដីកាចាត់ឲ្យស៊ើបសួរជំនួស។ ដីកាចាត់ឲ្យស៊ើបសួរជំនួសនេះ គឺជាការសុំរបស់ចៅក្រមស៊ើបសួរដើម្បីឲ្យចៅក្រមស៊ើបសួរផ្សេង ឬមន្ត្រីនគរបាលយុត្តិធម៌ ឬអង្គភាពនគរបាលយុត្តិធម៌បំពេញកិច្ចមួយចំនួនតាមរយៈដីកាចាត់ឲ្យស៊ើបសួរជំនួស។ ហើយក្នុងដីកាចាត់ឲ្យស៊ើបសួរជំនួសត្រូវបញ្ជាក់អំពីប្រភេទនៃកិច្ចដែលត្រូវធ្វើ ដែលកិច្ចនោះត្រូវមានទំនាក់ទំនងដោយផ្ទាល់ជាមួយបទល្មើសដែលបានចោទប្រកាន់។

ចំពោះវិធានការនិរន្តរាយ សម្តៅទៅដល់ការចេញដីកាឲ្យចាប់ខ្លួន ការចោទប្រកាន់ ការឃុំខ្លួន ឬការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការដោយចៅក្រមស៊ើបសួរ។ វិធានការនេះត្រូវបានចៅក្រមស៊ើបសួរអនុវត្តដើម្បីជាការងាយស្រួលស្វែងរកភស្តុតាងពិតប្រាកដសម្រាប់ដាក់បន្ទុក និងដោះបន្ទុកនៅក្នុងរឿងក្តីព្រហ្មទណ្ឌ។ វិធានការនេះចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឲ្យចូលខ្លួន ដីកាបង្គាប់ឲ្យនាំខ្លួន ដីកាបង្គាប់ឲ្យចាប់ខ្លួន និងដីកាបង្គាប់ឲ្យឃុំខ្លួន។ ដោយកម្មវត្ថុនៃដីកាបង្គាប់ឲ្យចូលខ្លួន គឺដើម្បីបញ្ជាដល់បុគ្គលណាម្នាក់ឬច្រើន

នាក់ឲ្យចូលទៅបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ។ ប្រសិនបើជននោះមិនបានបង្ហាញខ្លួនតាមដីកាបង្គាប់ឲ្យចូលខ្លួនទេ នោះចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឲ្យនាំខ្លួន។ ក្នុងករណីជនត្រូវចោទរត់គេចខ្លួន ចៅក្រមស៊ើបសួរនឹងចេញដីកាបង្គាប់ឲ្យចាប់ខ្លួន ដែលជាបញ្ជាបង្គាប់ឲ្យកងកម្លាំងសាធារណៈទាំងអស់ស្រាវជ្រាវចាប់ជនត្រូវចោទមកចំពោះមុខចៅក្រមស៊ើបសួរ។ ហើយចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឲ្យចាប់ខ្លួនបានដែលដីកានេះគឺបញ្ជាដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនទទួល និងឃុំខ្លួនជនត្រូវរចោទ។ ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឲ្យឃុំខ្លួនបានលុះត្រាតែបន្ទាប់ពីចេញដីកាសម្រេចឲ្យឃុំខ្លួនបណ្ដោះអាសន្ន។

បន្ទាប់ពីវិធានការនិរន្ដរាយត្រូវបានអនុវត្ត ចៅក្រមស៊ើបសួរមានសិទ្ធិពេញទីក្នុងការកំណត់សិទ្ធិជនត្រូវចោទក្នុងដំណាក់កាលស៊ើបសួររកការពិត។ ការកំណត់សិទ្ធិនេះដែរ ចៅក្រមស៊ើបសួរអាចសម្រេចចិត្តឃុំខ្លួនជននោះបណ្ដោះអាសន្ន ឬដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ឬធានាជនត្រូវចោទឲ្យនៅក្រៅឃុំ។ ប៉ុន្តែការអនុវត្តនីតិវិធីនេះចៅក្រមស៊ើបសួរត្រូវគោរពនូវសិទ្ធិមនុស្ស និងអាយុរបស់បុគ្គលហើយត្រូវពិនិត្យមើលប្រភេទនៃបទល្មើសដើម្បីកំណត់សិទ្ធិ។

បើចៅក្រមស៊ើបសួរ យល់ឃើញថាដំណាក់កាលស្រាវជ្រាវរបស់ខ្លួនមានលក្ខណៈគ្រប់គ្រាន់សមស្របសម្រាប់បញ្ចប់ នោះចៅក្រមនឹងធ្វើការបិទការស៊ើបសួរដើម្បីបិទសំណុំរឿងក្រោមកិច្ចមួយហៅថា ដីកាដំណោះស្រាយ។ តាមរយៈដីកាបញ្ជូនទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់។

# អនុសាសន៍

ក្នុងនាមយើងខ្ញុំជានិស្សិតបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រយើងខ្ញុំយល់ឃើញថា ដើម្បីបង្ការបទល្មើស និងផ្តល់ភាពយុត្តិធម៌ដល់ជនល្មើស និងជនរងគ្រោះ ក្នុងដំណាក់កាលស៊ើបសួរដែលអនុវត្តដោយចៅក្រមស៊ើបសួរក៏ដូចជាការធានាអនុវត្តក្រមនីតិវិធីព្រហ្មទណ្ឌនេះឲ្យមានប្រសិទ្ធិភាព រដ្ឋគួរតែពង្រឹងកត្តាមួយចំនួនដូចខាងក្រោមនេះ៖

- ត្រូវបន្ត និងបង្កើនការផ្សព្វផ្សាយក្រមនីតិវិធីព្រហ្មទណ្ឌឲ្យបានទូលំទូលាយដល់មជ្ឈដ្ឋានទូទៅទូទាំងប្រទេស។

- ជ្រើសរើសមន្ត្រីតុលាការដែលមានសមត្ថភាពពិតប្រាកដ និងគ្រប់គ្រាន់តាមតម្រូវការជាក់ស្តែង។

- ត្រូវពង្រឹងការអនុវត្តក្រមសីលធម៌វិជ្ជាជីវៈតាមរយៈ ការឃ្លាំមើល និងដាក់ពិន័យ រាល់ការបំពានក្រមសីលធម៌ដល់ចៅក្រម ព្រះរាជអាជ្ញា និងក្រឡាបញ្ជី ឬមេធាវីអតីត។

- ត្រូវគោរពគោលការណ៍សិទ្ធិមនុស្សជាមូលដ្ឋាន ជាពិសេសត្រូវយកចិត្តទុកដាក់លើការគោរពសិទ្ធិទទួលបានការជំនុំជម្រះតាមបែបយុត្តិធម៌ថ្នាក់ជាតិ និងអន្តរជាតិ។

- សូមឲ្យចៅក្រមស៊ើបសួរ គោរពឲ្យបានមត់ចត់នូវការហាមឃាត់ទាំងឡាយដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនេះ ពិសេសគឺរក្សាការសម្ងាត់។

- សូមឲ្យចៅក្រមស៊ើបសួរ គោរពឲ្យបានហ្មត់ចត់នូវគោលការណ៍ទាំងឡាយណាដែលចែងដោយក្រមនីតិវិធីព្រហ្មទណ្ឌ ព្រោះបើមានតែច្បាប់ផ្ទុយទៅវិញគ្មានការអនុវត្តឲ្យបានល្អនោះវានឹងបណ្តាលឲ្យមានភាពអនាធិបតេយ្យ។

ក្រៅពីនេះគួរពន្លឿននីតិវិធី បាននន័យថាចៅក្រមស៊ើបសួរគួរផ្តល់អទិភាពចំពោះសំណុំរឿងព្រហ្មទណ្ឌទាំងឡាយណាដែលជនត្រូវចោទដែលនៅក្នុងការឃុំខ្លួនបណ្តោះអាសន្នជាពិសេស គឺសុំណុំរឿងដែលមានជនត្រូវចោទជាអនីតិជនជាដើម។

# ឯកសារយោង

// # ឯកសារយោង

## ១. ច្បាប់

- រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៣។
- ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន, លេខ នស/រកម/០៧១៦/០០៩, ១៤ កក្កដា ២០១៦។
- ច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤។
- ច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា, លេខ នស/រកម/០៧១៤/០១៦, ១៦ កក្កដា ២០១៤។
- ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩។
- ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។
- ក្រមសីលធម៌ចៅក្រម, ០៥ កុម្ភៈ ២០០៧។

## ២. សៀវភៅ

- រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត. ២០១៧. នីតិវិធីព្រហ្មទណ្ឌ. មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៤. សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច។
- អ៊ុន បូផា. ២០១៦. នីតិភស្តុតាង. បោះពុម្ពលើកទី២។
- ទីស្ដីការគណៈរដ្ឋមន្ត្រី គណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់. ២០១១. សន្ទានុក្រមពាក្យច្បាប់ ខ្មែរ-អង់គ្លេស-បារាំង ផ្នែកព្រហ្មទណ្ឌ។
- សម្ដេច ជួន ណាត. ១៩៦៧. វចនានុក្រមខ្មែរ. ភ្នំពេញ៖ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ។

## ៣. បទសម្ភាស

- កើត រិទ្ធ, បទសម្ភាសដោយពិធីការិនីនៃទូរទស្សន៍ជាតិកម្ពុជា, ទូរទស្សន៍ជាតិកម្ពុជា, ០៨ មករា ២០០៨។

# ឧបសម្ព័ន្ធ

# បញ្ជីរាយនាមឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១ គម្រូនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

ឧបសម្ព័ន្ធទី២ គម្រូនៃកំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូង

ឧបសម្ព័ន្ធទី៣ គម្រូនៃកំណត់ហេតុស្តីពីការពិភាក្សាដេញដោលចំពោះមុខ

ឧបសម្ព័ន្ធទី៤ គម្រូនៃដីកាកោះ (ជនត្រូវចោទ)

ឧបសម្ព័ន្ធទី៥ គម្រូនៃកំណត់ហេតុស្តីពីការសួរចម្លើយជនត្រូវចោទ

ឧបសម្ព័ន្ធទី៦ គម្រូនៃកំណត់ហេតុស្តីពីការសួរចម្លើយតទល់

ឧបសម្ព័ន្ធទី៧ គម្រូនៃដីកាកោះដើមបណ្តឹងរដ្ឋប្បវេណី

ឧបសម្ព័ន្ធទី៨ គម្រូនៃកំណត់ហេតុស្តីការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

ឧបសម្ព័ន្ធទី៩ គម្រូនៃដីកាកោះហៅសាក្សី

ឧបសម្ព័ន្ធទី១០ គម្រូនៃកំណត់ហេតុស្តីការធ្វើសម្បថ

ឧបសម្ព័ន្ធទី១១ គម្រូនៃកំណត់ហេតុស្តីការស្តាប់ចម្លើយសាក្សី

ឧបសម្ព័ន្ធទី១២ គម្រូនៃដីកាចាត់តាំងអ្នកជំនាញ

ឧបសម្ព័ន្ធទី១៣ គម្រូនៃដីកាបង្គាប់ឲ្យស៊ើបសួរជំនួស

ឧបសម្ព័ន្ធទី១៤ គម្រូនៃដីកាបង្គាប់ឲ្យចូលខ្លួន

ឧបសម្ព័ន្ធទី១៥ គម្រូនៃដីកាបង្គាប់ឲ្យនាំខ្លួន

ឧបសម្ព័ន្ធទី១៦ គម្រូនៃដីកាបង្គាប់ឲ្យចាប់ខ្លួន

ឧបសម្ព័ន្ធទី១៧ គម្រូនៃដីកាបង្គាប់ឲ្យឃុំខ្លួន

ឧបសម្ព័ន្ធទី១៨ គម្រូនៃដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្ន

ឧបសម្ព័ន្ធទី១៩ គម្រូនៃដីកាសម្រេចឲ្យពន្យារពេលឃុំខ្លួនបណ្តោះអាសន្ន

ឧបសម្ព័ន្ធទី២០ គម្រូនៃដីកាបង្គាប់ឲ្យពន្យារពេលឃុំខ្លួនបណ្តោះអាសន្ន

ឧបសម្ព័ន្ធទី២១ គម្រូនៃដីកាសម្រេចដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំ

ឧបសម្ព័ន្ធទី២២ គម្រូនៃដីកាសម្រេចដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

ឧបសម្ព័ន្ធទី២៣ គម្រូនៃលិខិតជូនព័ត៌មានស្តីពីការបញ្ចប់ការស៊ើបសួរ

ឧបសម្ព័ន្ធទី២៤ គម្រូនៃដីកាចាត់ឲ្យបំពេញកិច្ចស៊ើបសួរបន្ថែម

ឧបសម្ព័ន្ធទី២៥ គម្រូនៃដីកាសម្រេចបដិសេធការស្នើសុំឲ្យបំពេញកិច្ច

ឧបសម្ព័ន្ធទី២៦ គម្រូនៃដីកាដំណោះស្រាយ

ឧបសម្ព័ន្ធទី២៧  គម្រូនៃដីកាសម្រេចប្រគល់វត្ថុដែលចាប់ឲ្យទៅម្ចាស់ដើមវិញ
ឧបសម្ព័ន្ធទី២៨  គម្រូនៃដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ
ឧបសម្ព័ន្ធទី២៩  គម្រូនៃដីកាលើកលែងការចោទប្រកាន់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធទី១

**អយ្យការអម**
**សាលាដំបូងរាជធានីភ្នំពេញ**
សំណុំរឿងព្រហ្មទណ្ឌលេខ
ចុះថ្ងៃទី ខែ ឆ្នាំ
លេខៈ ..................... អ.យ.គ

## ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

**យើង** **ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ**

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខៈ ចុះថ្ងៃទី ខែ ឆ្នាំ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ ពាក្យបណ្តឹង ចុះថ្ងៃទី ខែ ឆ្នាំ របស់ឈ្មោះ ភេទប្រុស អាយុ ឆ្នាំ បានប្តឹងឈ្មោះ ភេទប្រុស អាយុ ឆ្នាំ និងឈ្មោះ ភេទស្រី អាយុ ឆ្នាំ ពីបទ រំលោភលើទំនុកចិត្ត និងឆបោកប្រាក់។

### ក្រោយពីបានពិនិត្យឯកសារខាងលើ

យល់ឃើញថា មានតម្រុយសន្និដ្ឋានបានថា

១-នាម-គោត្តនាម ភេទប្រុស អាយុ ឆ្នាំ មានអាស័យដ្ឋាននៅ ឃុំ ស្រុក ខេត្ត ។ (ក្រៅឃុំ)

២-នាម-គោត្តនាម ភេទស្រី អាយុ ឆ្នាំ មានអាស័យដ្ឋាននៅ ឃុំ ស្រុក ខេត្ត ។ (ក្រៅឃុំ)

**បានប្រព្រឹត្តអំពើដូចតទៅៈ** កាលពីអំឡុងឆ្នាំ ឈ្មោះ និង បាន ចូលហ៊ុនរកស៊ីទិញលក់ដើមកៅស៊ូនៅខេត្ត ជាមួយ មានឈ្មោះ ជា ហើយបានព្រមព្រៀងគ្នាដោយភាគីឈ្មោះ ទទួលបាន % ចំណែកឯឈ្មោះ និង ទទួលបាន % ការរកស៊ីទិញលក់ដើមកៅស៊ូខាងលើនេះឈ្មោះ និង ជាអ្នកចំណាយប្រាក់ទាំងអស់ រីឯឈ្មោះ គ្រាន់តែឈរឈ្មោះតែប៉ុណ្ណោះ។ បន្ទាប់ពីមានការព្រមព្រៀងគ្នារួចហើយ ឈ្មោះ និង បានផ្ញើប្រាក់អោយទៅ តាមរយៈធនាគារ ដែលមានឈ្មោះ , ឈ្មោះ និងឈ្មោះ ជាអ្នកទទួលសាច់ប្រាក់ដោយផ្ទាល់សរុបចំនួន ដុល្លាអាមេរិក។ ក្រោយពីទទួលប្រាក់រួចហើយឈ្មោះ បានធ្វើការកាប់ដើមកៅស៊ូយកទៅលក់ជាបន្តបន្ទាប់ ប៉ុន្តែមិនបានបង្វិលប្រាក់ដើម និងប្រាក់ចំណេញមកអោយឈ្មោះ ឡើយ។ ហើយពួកគេបានគេចវេស និងគេចខ្លួនរហូត ទើបឈ្មោះ សម្រេចចិត្តដាក់ពាក្យបណ្តឹងមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញដើម្បីចាត់ការតាមនីតិវិធី។

អំពើខាងលើជាបទល្មើស **៖ ឆបោក** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីឆ្នាំ តាមបញ្ញត្តិមាត្រា ៣៧៧ និង ៣៧៨ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

បានឃើញមាត្រា ៨៩ និងមាត្រា ១២៨ ក្រមនីតិវិធីព្រហ្មទណ្ឌ។

**សម្រេច៖**

បើកការស៊ើបសួរលើអង្គហេតុខាងលើ និង

☑ដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ៖

-ឈ្មោះ ... ភេទប្រុស អាយុ ឆ្នាំ។ (ក្រៅឃុំ)

-ឈ្មោះ ភេទស្រី អាយុ ឆ្នាំ។ (ក្រៅឃុំ)

ពីបទ ៖ **ឆបោក** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីឆ្នាំ តាមបញ្ញត្តិមាត្រា ៣៧៧ និង ៣៧៨ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

☑ដាក់ឲ្យស្ថិតនៅក្រោមការឃុំខ្លួនបណ្ដោះអាសន្ន៖ លើឈ្មោះខាងលើ ដើម្បីបង្ការ ឬបញ្ចប់បទល្មើសកុំឲ្យកើតឡើងជាថ្មី និងធានាក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី។

ថ្ងៃ សុក្រ ០១ កើត ខែ កត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៨

**ចៅក្រមស៊ើបសួរ**

**ព្រះរាជអាជ្ញារង**

ឧបសម្ព័ន្ធទី២

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកណ្តាល**

**មន្ទីរស៊ើបសួរអក្សរ "...."**

**សំណុំរឿងលេខ.........អ.ក**

**ចុះថ្ងៃទី...............................**

### កំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូង

(មាត្រា ១៤៣,១៤៤,២៤០ និង ២៤១ បន្តបន្ទាប់នៃក្រមនីតិព្រហ្មទណ្ឌ)

ឆ្នាំពីរពាន់ដប់.................ខែ.................ថ្ងៃទី.................វេលាម៉ោង..................ព្រឹក/រសៀល ។

យើង..............................ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល អមដោយលោក/លោកស្រី.........
.........................ជាក្រឡាបញ្ជី ។

បុគ្គលដែលនៅចំពោះមុខយើង បានផ្តល់នូវព័ត៌មានអំពីអត្តសញ្ញាណដូចខាងក្រោមៈ

